សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
UNIVERSITÉ ROYALE DE DROIT ET DES SCIENCES ÉCONOMIQUES
ROYAL UNIVERSITY OF LAW AND ECONOMICS

# សារណាបញ្ចប់ការសិក្សា

# ការអនុវត្តដោយបង្ខំ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ៖ **កញ្ញា ផន សុភីលាន**
**កញ្ញា ម៉ៅ ច័ន្ទលក្ខិណា**

សាស្ត្រាចារ្យណែនាំ
**លោកជំទាវ ម៉ួយ ធីតា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
**UNIVERSITÉROYALE DE DROIT ET DES SCIENCES ÉCONOMIQUES**
ROYAL UNIVERSITY OF LAW AND ECONOMICS

# សារណាបញ្ចប់ការសិក្សា

# ការអនុវត្តដោយបង្ខំ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ៖ **កញ្ញា ផន សុភីលាន**
**កញ្ញា ម៉ៅ ច័ន្ទលក្ខិណា**

សាស្ត្រាចារ្យណែនាំ
**លោកជំទាវ ម៉ួយ ធីតា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# លិខិតថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ផន សុភីលាន** ជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រ។

## សូមគោរពថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅបំផុតចំពោះ

លោកឪពុក **ពេជ្រ ស៊ុវណ្ណា** និងអ្នកម្តាយ **ឈិន សុខុន** មានគុណទាំងពីរ ដែលបានផ្តល់កំណើត/ជីវិត និងចិញ្ចឹមបីបាច់ថែរក្សានាងខ្ញុំ រួមទាំងបានបញ្ជូននាងខ្ញុំឱ្យបានសិក្សាតាំងពីបឋមសិក្សា រហូតដល់បានបញ្ចប់ការសិក្សានៅថ្នាក់ឧត្តមសិក្សា។

**លោកជំទាវ ម៉ួយ ធីតា** ដែលបានទទួលយល់ព្រមធ្វើជាសាស្ត្រាចារ្យដឹកនាំសារណារបស់នាងខ្ញុំ រួមទាំងការបង្ហាញផ្លូវសម្រាប់ដើរក្នុងការឆ្ពោះទៅរកការតាក់តែងជាអត្ថបទសារណារបស់នាងខ្ញុំ។

**មូលនិធិហាប់ស្វែល (Harpswell Foundation)** និងថ្នាក់ដឹកនាំទាំងអស់ ដែលបានផ្តល់ជាអាហារូបករណ៍ ជាកន្លែងស្នាក់នៅ អាហារហូបចុក ជាទីកន្លែងដែលផ្តល់នូវការអប់រំដ៏ល្អ និងជាទីផ្តល់នូវភាពកក់ក្តៅក្នុងរយៈពេល៤ឆ្នាំ ដល់នាងខ្ញុំ។

**ឯកឧត្តមបណ្ឌិត ប៉ែន ស៊ីម៉ន** ប្រធានគណៈកម្មាធិការទី១០ សមាជិករដ្ឋសភា និងជាប្រធានមូលនិធិសម្រាប់និស្សិតខេត្តកំពត ដែលបានផ្តល់ជាអាហារូបករណ៍ប្រាក់វិភាជន៍ដល់នាងខ្ញុំ រយៈ៤ឆ្នាំ សម្រាប់បង់ថ្លៃការសិក្សានៅសាកលវិទ្យាល័យ។

**Mitsubishi UFJ Foundation** ដែលបានផ្តល់អាហារូបករណ៍ជាទឹកប្រាក់ចំនួន$២៧៥ ដល់នាងខ្ញុំ សម្រាប់ការចំណាយលើការទិញសម្ភារៈសិក្សារយៈពេលមួយឆ្នាំ។

**ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ លុយ ចណ្ណា** និងសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់អាហារូបករណ៍៥០% សម្រាប់រយៈពេល៤ឆ្នាំ ហើយអនុញ្ញាតឱ្យរូបនាងខ្ញុំបានសិក្សាតាំងពីឆ្នាំទី១ រហូតដល់ឆ្នាំទី៤ រួមទាំងបានអនុញ្ញាតឱ្យនាងខ្ញុំបានសរសេរសារណាដើម្បីបញ្ចប់ការសិក្សាផងដែរ។ លោកសាស្ត្រាចារ្យ និងអ្នកស្រីសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការបង្ហាត់បង្រៀនរូបនាងខ្ញុំ អស់ពីកម្លាំងកាយចិត្តក្នុងការផ្ទេរចំណេះដឹងដែលមានទាំងប៉ុន្មានមកកាន់នាងខ្ញុំ រួមទាំងសិស្សនិស្សិតទាំងអស់ផងដែរ។

ជាចុងក្រោយ យើងខ្ញុំមានតែលើកម្រាមដៃដប់ ថ្លែងអំណរអរគុណ ចំពោះអ្នកមានគុណទាំងអស់ ដែលបានផ្តល់ជាការទំនុកបម្រុងសព្វគ្រប់បែបយ៉ាងសម្រាប់ខ្ញុំក្លាយជាបុគ្គលដែលមានសក្តានុពល និងជាទំពាំងស្នងឬស្សីជំនាន់ក្រោយសម្រាប់សង្គមជាតិ។ នាងខ្ញុំសូមជូនពរដល់អ្នកមានគុណ ជួបពុទ្ធិពរទាំងបួនប្រការគឺ មានអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ សូមអរគុណ!

# លិខិតថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ម៉ៅ ច័ន្ទលក្ខិណា** ជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រ ។

## សូមគោរពថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅបំផុតចំពោះ

លោកឪពុក **អ៊ុខ ទូច** និងអ្នកម្តាយ **រស់ សោភា** មានគុណទាំងពីរ ដែលបានផ្តល់កំណើត/ជីវិត និងចិញ្ចឹមបីបាច់ថែរក្សានាងខ្ញុំ រួមទាំងបានបញ្ជូននាងខ្ញុំឱ្យបានសិក្សាតាំងពីបឋមសិក្សា រហូតដល់បានបញ្ចប់ការសិក្សានៅថ្នាក់ឧត្តមសិក្សា។

**លោកជំទាវ ម៉ិយ ធីតា** ដែលបានទទួលយល់ព្រមធ្វើជាសាស្ត្រាចារ្យដឹកនាំសារណារបស់នាងខ្ញុំ រួមទាំងការបង្ហាញផ្លូវសម្រាប់ដើរក្នុងការឆ្ពោះទៅរកការតាក់តែងជាអត្ថបទសារណារបស់នាងខ្ញុំ។

**ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ លុយ ចណ្ណា** និងសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឱ្យរូបនាងខ្ញុំបានសិក្សាតាំងពីឆ្នាំទី១ រហូតដល់ឆ្នាំទី៤ រួមទាំងបានអនុញ្ញាតឱ្យនាងខ្ញុំបានសរសេរសារណា ដើម្បីបញ្ចប់ការសិក្សាផងដែរ។ លោកសាស្ត្រាចារ្យ និងអ្នកស្រីសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការបង្ហាត់បង្រៀនរូបនាងខ្ញុំ អស់ពីកម្លាំងកាយចិត្តក្នុងការផ្ទេរចំណេះដឹងដែលមានទាំងប៉ុន្មានមកកាន់នាងខ្ញុំ រួមទាំងសិស្សនិស្សិតទាំងអស់ផងដែរ។

ជាចុងក្រោយ យើងខ្ញុំមានតែលើកម្រាមដៃដប់ ថ្លែងអំណរអរគុណ ចំពោះអ្នកមានគុណទាំងអស់ ដែលបានផ្តល់ជាការទំនុកបម្រុងសព្វគ្រប់បែបយ៉ាងសម្រាប់ខ្ញុំក្លាយជាបុគ្គលដែលមានសក្តានុពល និងជាទំពាំងស្នងឬស្សីជំនាន់ក្រោយសម្រាប់សង្គមជាតិ។ នាងខ្ញុំសូមជូនពរដល់អ្នកមានគុណ ជួបពុទ្ធិពរទាំងបួនប្រការគឺ មានអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ សូមអរគុណ!

# អារម្ភកថា

ចាប់ពីដើមឆ្នាំ២០២០មក ប្រទេសកម្ពុជា ក៏ដូចជាបណ្ដាប្រទេស បានជួបប្រទះនូវបញ្ហាជម្ងឺរាតត្បាតដ៏សាហាវ គឺជម្ងឺកូវីដ-១៩ ដែលវាបានបំផ្លាញសុខភាពរបស់មនុស្ស និងបានឆក់យកជីវិតមនុស្សមានការកើនឡើងជារៀងរាល់ថ្ងៃ ជាពិសេសនៅក្នុងព្រឹត្តការណ៍២០ កុម្ភៈ ២០២១។ កត្តានេះហើយ បានជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបាន ប្រកាសឱ្យបិទគ្រឹះស្ថានឧត្ដមសិក្សាសាធារណៈ និងឯកជនទូទាំងប្រទេស ដែលជាហេតុធ្វើឱ្យនិស្សិតទាំងអស់ត្រូវសិក្សាពីចំងាយតាមរយៈប្រព័ន្ធអនទ្បាយ។ ចំពោះសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច បានដាក់ដំណើរការការបង្រៀនតាមអនទ្បាញដោយប្រើប្រាស់កម្មវិធី Microsoft Team សម្រាប់និស្សិតដែលកំពុងបន្តការសិក្សាជាពិសេសក្នុងឆ្នាំសិក្សា ២០២០- ២០២១។ ចំពោះនិស្សិតដែលនឹងបញ្ចប់ការសិក្សា ក៏ត្រូវប្រឡងញ្ចប់ និងតាក់តែងសារណាដើម្បីការពារផងដែរ។ ប៉ុន្តែដោយសារកត្តាបញ្ហាជម្ងឺកូវីដ-១៩ ទើបធ្វើឱ្យការធ្វើសារណារបស់នាងខ្ញុំទាំងពីរ មានផលលំបាកជាខ្លាំង ពីព្រោះសាលាបិទ ហើយពួកយើងពុំសូវមានឯកសារក្នុងការសិក្សាស្រាវ។

ការសិក្សាស្រាវជ្រាវប្រធានបទ «**ការអនុវត្តដោយបង្ខំ**» ដែលមានកំណត់នៅក្នុងគន្ថីទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។ នៅក្នុងការតាក់តែងសៀវភៅសារណានេះឡើងបាន នាងខ្ញុំទាំងពីរនាក់បានស្វែងរកនូវឯកសារមួយចំនួនដែលទាក់ទងនឹងប្រធានបទ ដើម្បីធ្វើជាយាននាំផ្លូវក្នុងការសរសេរសារណានេះឡើង។ គោលបំណងធំរបស់នាងខ្ញុំទាំងពីរ ក្នុងការសរសេរសារណានេះ គឺដើម្បីសិក្សាឱ្យកាន់តែស៊ីជម្រៅលើប្រធានបទ«ការអនុវត្តដោយបង្ខំ»នេះ ពីព្រោះតែនាងខ្ញុំទាំងពីរពុំសូវសិក្សាបានច្រើនពីនីតិវិធីរដ្ឋប្បវេណីដោយសារកូវីដ-១៩ និងដើម្បីដាក់សារណាជូនសាស្រ្តាចារ្យពិនិត្យ ផ្ដល់ជាអនុសាសន៍ និងឈានទៅដំណាក់កាលការពារដោយគណៈកម្មការការពារសារណាក្នុងការវាយតម្លៃក៏ដូចជាធ្វើការដាក់ពិន្ទុលើសារណារបស់នាងខ្ញុំទាំងពីរផងដែរ។ មិនតែប៉ុណ្ណោះ សៀវភៅសារណាស្ដីពីការអនុវត្តដោយបង្ខំ ដែលនាងខ្ញុំទាំងពីរបានចងក្រងនេះ ក៏អាចធ្វើជាឯកសារគោលក្នុងការឱ្យនិស្សិតទាំងអស់បានអាន និងសិក្សាស្វែងយល់បន្ថែមឲ្យកាន់តែច្បាស់ទៅលើនីតិវិធីនៃការអនុវត្តដោយបង្ខំ ដែលជាប្រធានបទមួយ គួរឲ្យចាប់អារម្មណ៍បំផុតនៅក្នុងវិស័យច្បាប់។ សូមបញ្ជាក់ផងដែរថា រាល់ខ្លឹមសារដែលមាននៅក្នុងសារណានេះសុទ្ធតែជាខ្លឹមសារដែលយើងខ្ញុំទាំងពីរនាក់បានធ្វើការសិក្សាស្រាវជ្រាវពីឯកសារបទដ្ឋានគតិយុត្តជាធរមាន និងឯកសារផ្លូវការដទៃទៀតដែលមានប្រភពជាផ្លូវការច្បាស់លាស់។ ទោះបីជាយ៉ាងណាក៏ដោយ សៀវភៅសារណាមួយក្បាលនេះក៏នៅតែមានភាពខ្វះចន្លោះដោយខានពុំបាន ។

នាងខ្ញុំទាំងពីរ ពិតជាមានមោទនភាពណាស់ដែល**លោកជំទាវ ម៉ៃ ធីតា** បានទទួលធ្វើជាសាស្រ្តាចារ្យក្នុងការដឹកនាំសារណារបស់នាងខ្ញុំទាំងពីរនាក់។ ជាចុងក្រោយ ក្រុមយើងខ្ញុំសូមអរគុណចំពោះលោកជំទាវសាស្រ្តាចារ្យ និងទទួលយកនូវការកែលម្អពីសំណាក់សាស្រ្តាចារ្យដែលជាគណៈកម្មការដាក់ពិន្ទុ នៅក្នុងដំណើរការនៃការការពារសារណា ដើម្បីយកដំបូន្មានទាំងនោះ មកអភិវឌ្ឍន៍ខ្លួនឯងឲ្យបានរីកចម្រើនឆ្ពោះទៅអនាគត។

# មាតិកា

ទំព័រ


**សេចក្ដីផ្ដើម** ............................................................ **១**

## ជំពូកទី១

## សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំ

**១.១. បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ** ........................................ ៣

**១.២. គោលគំនិត** ............................................................ ៣

**១.៣. តាគីនៃការអនុវត្តដោយបង្ខំ** ............................................................ ៤

**១.៤. កម្មវត្ថុនៃការអនុវត្តដោយបង្ខំ** ............................................................ ៤

**១.៤.១. ការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់** ........................................ ៤

ក. ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ............................................................ ៤

ខ. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ............................................................ ៥

គ. ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ............................................................ ៧

ង. ការអនុវត្តដោយបង្ខំចំពោះនាវា ............................................................ ៧

**១.៤.២. ការអនុវត្តសិទ្ធិប្រាតិភោគ** ............................................................ ៩

ក. ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ............................................................ ៩

ខ. ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធលើបំណុល ............................................................ ១០

គ. ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ............................................................ ១១

ឃ. ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា ............................................................ ១២

**១.៤.៣. ការអនុវត្តដោយបង្ខំដែលពុំមានគោលបំណងឱ្យសងជាប្រាក់** ........................................ ១៣

ក. ការអនុវត្តសិទ្ធិទាមទារឱ្យប្រគល់វត្ថុ ............................................................ ១៣

ក.១. ការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ ឬនាវា ឬវត្ថុផ្សេងទៀត ........................................ ១៣

ក.២. ការអនុវត្តដោយបង្ខំឲ្យប្រគល់ចលនវត្ថុក្រៅពីអចលនវត្ថុ ................................................. ១៤

ក.៣. ការអនុវត្តដោយបង្ខំឲ្យប្រគល់ ក្នុងករណីវត្ថុដែលជាកម្មវត្ថុ ត្រូវបានកាន់កាប់ដោយតតិយជន.. ១៤

ខ.ការអនុវត្តជំនួស ................................................................................................ ១៤

គ. វិធានបង្ខំដោយប្រយោល ........................................................................................ ១៥

ឃ. ការចាត់ទុកថាបានបង្ហាញឆន្ទៈ .................................................................................... ១៦

**១.៥. ប្រភេទការអនុវត្តដោយបង្ខំ**..............................................................................១៦

**១.៥.១. ការអនុវត្តបែបបុគ្គលភាព និងការអនុវត្តបែបសម្ភារៈ** .............................................១៦

**១.៥.២. ការអនុវត្តដើម និងការអនុវត្តសងជំនួស** ..................................................... ១៧

**១.៥.៣. ការអនុវត្តដោយផ្ទាល់ វិធានបង្ខំដោយប្រយោល និងការអនុវត្តជំនួស** ................ ១៧

**១.១.៤. ការអនុវត្តជាចម្បង និងការអនុវត្តជាបណ្ដោះអាសន្ន** .......................................១៨

**១.៥.៥. ការអនុវត្តដោយឡែក និងការអនុវត្តជាទូទៅ** ..................................................១៩

**១.៦. លក្ខខណ្ឌទម្រង់នៃពាក្យសុំអនុវត្តដោយបង្ខំ**..........................................................១៩

**១.៧. ស្ថាប័នអនុវត្តដោយបង្ខំ និងដែនសមត្ថកិច្ច និងការសម្រេចសេចក្ដីរបស់តុលាការ**
.................................................................................................................... ២០

**១.៧.១ តុលាការអនុវត្ត** ................................................................................... ២០

ក. វិធានទូទៅសម្រាប់នីតិវិធីនៃការអនុវត្តដោយតុលាការអនុវត្ត..........................................២២

ខ. វិធីឧបាស្រ័យ.......................................................................................................២២

**១.៧.២ អាជ្ញាសាលា** .......................................................................................២៣

ក. តួនាទីរបស់អាជ្ញាសាលា.........................................................................................២៣

ខ. ឋានៈរបស់អាជ្ញាសាលា នៅក្នុងការអនុវត្តដោយបង្ខំ......................................................២៤

ខ.១. ទំនាក់ទំនងជាមួយនឹងម្ចាស់បំណុល ..................................................................២៤

ខ.២. ទំនាក់ទំនងជាមួយនឹងកូនបំណុល និងតតិយជន ........................................................ ២៥

ខ.៣. ទំនាក់ទំនងជាមួយនឹងតុលាការអនុវត្ត........................................................................ ២៥

ខ.៤. ការដកហូត.................................................................................................................. ២៥

គ. វិធានទូទៅសម្រាប់នីតិវិធីនៃការអនុវត្តដោយបង្ខំដោយអាជ្ញាសាលា........................................... ២៦

គ.១. ការយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ ............................................................................ ២៦

គ.២. ការអនុវត្តសិទ្ធិផែកឆេរ.................................................................................................. ២៦

គ.៣. ការបំបាត់នូវការប្រឆាំង ................................................................................................. ២៦

គ.៤. អ្នកសង្កេតការណ៍......................................................................................................... ២៦

គ.៥. ការអនុវត្តនៅថ្ងៃសម្រាក ឬពេលយប់ ............................................................................ ២៧

គ.៦. ការធ្វើកំណត់ហេតុ......................................................................................................... ២៧

គ.៧. វិធីឧបាស្រ័យ ................................................................................................................. ២៧

**១.៨.លិខិតអនុវត្ត................................................................................................................. ២៧**

**១.៩.ប្រភេទនៃលិខិតអនុវត្តដោយបង្ខំ ........................................................................................ ២៨**

**១.៩.១ សាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្ដល់តាវការលិកចូលជាស្ថាពរ** ................................... ២៨

**១.៩.២ សាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្ដល់តាវការលិក ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន** ........................................................................................................ ២៩

**១.៩.៣ ដីកាសម្រេចបង្គាប់ឱ្យផ្ដល់តាវការលិក**.................................................................... ២៩

**១.៩.៤ ដីកាសម្រេចដាស់តឿន ដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តបណ្ដោះអាសន្ន**............... ៣០

**១.៩.៥ ការចាត់ចែងរបស់ក្រឡាបញ្ជី** ..................................................................................... ៣០

**១.៩.៦ លិខិតយថាភូតដែលធ្វើដោយសារការី**....................................................................... ៣០

**១.៩.៧ សាលក្រមអនុវត្តសាលក្រម ឬសាលដីការបស់តុលាការបរទេស** ................................ ៣០

**១.៩.៨ សេចក្ដីសម្រេចមជ្ឈត្តករ** ......................................................................................... ៣១

**១.៩.៩ កំណត់ហេតុ** ............ ៣៣

**១.១០.រូបមន្តអនុវត្តដោយបង្ខំ** ............ ៣៣

## ជំពូកទី២

## នីតិវិធីនៃការអនុវត្តដោយបង្ខំ

**២.១. លំហូរនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ** ............ ៣៥

**២.១.១. ការសរសេរពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ** ............ ៣៦

**២.១.២. ឯកសារភ្ជាប់មកជាមួយនឹងពាក្យសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុ** ............ ៣៦

**២.១.៤. ការដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ** ............ ៣៦

**២.១.៥. ការពិនិត្យពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ** ............ ៣៧

**២.១.៦. ការរឹបអូសចលនវត្ថុ** ............ ៣៨

ក. ការចាប់ផ្តើមអនុវត្តដោយការរឹបអូស ............ ៣៨

ខ. គោលការណ៍សំខាន់ៗនៃការរឹបអូសអចលនវត្ថុ ............ ៣៨

គ. ចលនវត្ថុដែលហាមឃាត់មិនឲ្យរឹបអូស ............ ៣៩

ឃ. ការហាមឃាត់មិនឲ្យរឹបអូសហួសប្រមាណ ............ ៣៩

ង. ការហាមឃាត់មិនឲ្យរឹបអូស ក្នុងករណីដែលប៉ាន់ប្រមាណឃើញថាគ្មានចំនួនសេសសល់ ............ ៣៩

ច. ការរឹបអូសអចលនវត្ថុកាន់កាប់ដោយកូនបំណុល ............ ៣៩

**២.១.៧. ការរឹបអូសចលនវត្ថុកាន់កាប់ដោយម្ចាស់បំណុល** ............ ៤១

**២.១.៨. ការថែរក្សាចលនវត្ថុដែលត្រូវបានរឹបអូស** ............ ៤១

**២.១.៩. អានុភាពនៃការរឹបអូសចលនវត្ថុ** ............ ៤២

**២.១.១០. ការលក់ចលនវត្ថុដែលត្រូវបានរឹបអូស** ............ ៤២

ក. វិធីលក់ ............ ៤៣

ក.១.ការលក់ឡាយឡុងដោយផ្ទាល់មាត់..........................................................................................៤៣
ក.២. ការឡាយឡុងដោយស្រោមសំបុត្រ......................................................................................៤៣
ក.៣. វិធីលក់ផ្សេងៗទៀត..................................................................................................................៤៣
ខ. បុគ្គលដែលមិនអនុញ្ញាតិឲ្យដាក់សំណើទិញ.....................................................................................៤៣
គ. ការលក់.........................................................................................................................................៤៤
**២.១.១១. ការចែកចំណែក**.........................................................................................................៤៥
ក. ការបែងចែកដោយអាជ្ញាសាលា......................................................................................................៤៥
ខ. ការបែងចែកចំណេកដោយសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ.......................................................៤៦
**២.២. លំហូរនៃការអនុវត្តបង្ខំចំពោះអចលនវត្ថុ**...................................................................................៤៦
**២.២.១. លក្ខខណ្ឌនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ**..................................................................៤៦
ក. វិធីអនុវត្ត.......................................................................................................................................៤៧
ខ. យន្តការនៃការចុះបញ្ជីរឹបអូសអលចនវត្ថុ.........................................................................................៤៧
គ. ដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ..........................................................................................៤៧
ឃ. ការដាក់ពាក្យសុំឲ្យលក់ដោយបង្ខំ...................................................................................................៤៨
ង. ការបញ្ជូនពាក្យសុំទៅក្រឡាបញ្ជី....................................................................................................៤៨
**២.២.២. ករណីអចលនវត្ថុចុះបញ្ជី**....................................................................................................៤៨
**២.២.៣. ការរឹបអូសអចលនវត្ថុ**.........................................................................................................៤៨
**២.២.៤. ការលក់ដោយបង្ខំនូវអចនវត្ថុ**...............................................................................................៥០
ក. សមត្ថកិច្ចអនុវត្តការលក់...............................................................................................................៥០
ខ. វិធីលក់.........................................................................................................................................៥០
គ. ការកំណត់អ្នកស្នើរទិញក្នុងតម្លៃអតិបរមា.........................................................................................៥១

ឃ. អានុភាពនៃការលក់ ..... ៥២
**២.២.៥. នីតិវិធីចែកចំណែក** ..... ៥២
**សេចក្តីសន្និដ្ឋាន** ..... ៥៤
**អនុសាសន៍** ..... ៥៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ដែលបានដាក់ឲ្យអនុវត្តនៅឆ្នាំ២០០៧ ជាច្បាប់ទូទៅដែលបញ្ញត្តិអំពីនីតិវិធីរដ្ឋប្បវេណីដែលអនុវត្តនៅព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងនីតិរដ្ឋ នីតិវិធីរដ្ឋប្បវេណី ដែលអនុវត្តដោយតុលាការត្រូវអនុលោមតាមច្បាប់ ដែលត្រូវបានអនុម័តដោយសភាដែលជាអង្គការនីតិបញ្ញត្តិ និងមានអំណាចនីតិបញ្ញត្តិ នេះដោយផ្អែកទៅលើគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ។ នៅពេលតុលាការ នៅប្រទេសកម្ពុជាអនុវត្តនីតិវិធីរដ្ឋប្បវេណីជាគោលការណ៍តុលាការត្រូវអនុលោមតាមបញ្ញត្តិនានាដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។ ប៉ុន្តែប្រសិនបើ មានបញ្ញត្តិពិសេសអំពីនីតិវិធីនៃបណ្តឹងចំពោះរឿងក្តីប្រភេទណាពិសេស ដែលបានកំណត់ដោយច្បាប់ពិសេស តុលាការត្រូវអនុលោមតាមបញ្ញត្តិពិសេសនោះ ដើម្បីអនុវត្តនីតិវិធីនៃរឿងក្តីប្រភេទនោះនៅក្នុងទំហំដែលបានកំណត់។ ការអនុវត្តដោយបង្ខំ មានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី២។

ការអនុវត្តដោយបង្ខំ គឺជានីតិវិធីតាមផ្លូវតុលាការ ក្នុងការសម្រេចនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគ ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ឬច្បាប់ផ្សេងទៀត អាចទាមទារឲ្យសម្រេចសិទ្ធិនោះដោយការអនុវត្តដោយបង្ខំ តាមបញ្ញត្តិនៃគន្ថីទី៦ នៃក្រមនិតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ដោយប្រើអំណាចរបស់រដ្ឋ។ ប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី មានគោលបំណងផ្តល់ឱ្យភាគីឯកជនដែលមានសិទ្ធិដែលបានកំណត់ដោយច្បាប់ នូវការការពារសិទ្ធិទាំងនោះ។[1] ដើម្បីការពារដល់សិទ្ធិទាមទារ និងសិទ្ធិប្រាតិភោគដែលបានកំណត់នៅក្នុងនីតិឯកជននោះ ត្រឹមតែការកំណត់ដោយតុលាការ អំពីអត្ថិភាពនៃសិទ្ធិទាំងនោះ នៅក្នុងសាលក្រម សាលដីកា នៅមិនគ្រាន់គ្រប់គ្រាន់ទេ។ បន្ថែមពីលើនេះ ត្រូវមានការផ្តល់តាវកាលិកជាអាទិ៍ ដែលជាកម្មវត្ថុនៃសិទ្ធិទាមទារ ឬការផ្តល់តាវកាលិកជាប្រាក់ ដែលជាគោលបំណងនៃសិទ្ធិទាមទារឱ្យសងជាប្រាក់ ដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគយ៉ាងជាក់ស្តែងផងដែរ។

ទាក់ទងទៅនឹងការពារសិទ្ធិរបស់មនុស្ស ឬសិទ្ធិរបស់ប្រជាពលរដ្ឋ ក៏មានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ នៅក្នុងរដ្ឋធម្មនុញ្ញបានបញ្ជាក់យ៉ាងច្បាស់ថា ប្រជាពលរដ្ឋទាំងពីរភេទមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់។ ទោះបីស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ទោះបីក្លាយជាជនរងគ្រោះ ឬជាជនល្មើស ក៏ពួកគេត្រូវបានទទួលនូវសិទ្ធិក្នុងការការពារដែរ ប៉ុន្តែទំហំនៃការពារមានលក្ខណៈខុសគ្នាតែប៉ុណ្ណឹង។ ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់សិទ្ធិ នៅក្នុងប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី ដែលមានគោលបំណងការពារសិទ្ធិ

[1] មាត្រា៣៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

របស់បុគ្គលឯកជន ចាំបាច់ត្រូវមានការរៀបចំនូវនីតិវិធីសម្រាប់អនុវត្តដោយបង្ខំ ក្នុងករណីដែលបុគ្គលឯកជន ឬកូនបំណុល មិនព្រមអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនដោយស្ម័គ្រចិត្ត ក្នុងគោលដៅសម្រេចឱ្យបាននូវការអនុវត្តកាតព្វកិច្ច ដែលជាកម្មវត្ថុនៃសិទ្ធិទាមទារឬសិទ្ធិប្រាតិភោគ តាមរយៈការប្រើការសុំជំនួយអន្តរាគមន៍ពីស្ថាប័នអនុវត្តមានដូចជាតុលាការអនុវត្ត ឬអាជ្ញាសាលាជាអាទិ៍ និងការចូលរួមអនុវត្តពីសំណាក់មន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធដទៃផ្សេងទៀត។ អ្វីដែលត្រូវបានរៀបចំឡើង ដើម្បីបំពេញភាពចាំបាច់នេះ គឺការអនុវត្តដោយបង្ខំ។

នៅមុនពេលស្ថាប័នអនុវត្ត (តុលាការអនុវត្ត និងអាជ្ញាសាលា) ធ្វើការអនុវត្តដោយបង្ខំទៅលើកូនបំណុលនៃការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្ត ត្រូវដាក់ពាក្យសុំអនុវត្តដោយបង្ខំទៅស្ថាប័នអនុវត្តជាមុនសិន។ ប៉ុន្តែ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត មានការស្ម័គ្រចិត្ត ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនស្របតាមការព្រមព្រៀងដោយការចរចាណាមួយនោះ ស្ថាប័នអនុវត្តមិនមានកាតព្វកិច្ចក្នុងការអនុវត្តដោយបង្ខំចំពោះកូនបំណុលនៃការអនុវត្តឡើយ។ ប៉ុន្តែប្រសិនបើ ការចរចានោះមិនអាចប្រព្រឹត្តទៅបានទេ នោះស្ថាប័នអនុវត្ត អាចប្រើប្រាស់សមត្ថកិច្ចរបស់ខ្លួន ធ្វើការអនុវត្តដោយបង្ខំលើកូនបំណុលនៃការអនុវត្តតាមពាក្យសុំអនុវត្តដោយបង្ខំ របស់ម្ចាស់បំណុលនៃការអនុវត្តបាន។ នៅក្នុងដំណើរការនៃការអនុវត្តដោយបង្ខំ ស្ថាប័នអនុវត្ត មានតួនាទីសំខាន់ណាស់ ក្នុងការដោះស្រាយបញ្ហាដែលកើតមានឡើងរវាងម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ព្រោះប្រសិនគ្មានតុលាការអនុវត្ត និងអាជ្ញាសាលា ធ្វើការដោះស្រាយក្នុងរឿងក្តីទេនោះ ម្ចាស់បំណុលនៃការអនុវត្តនឹងពុំអាចទទួលបានភាពយុត្តិធម៌ពេញលេញនោះទេ។ មួយវិញទៀតការអនុវត្តរបស់ស្ថាប័នអនុវត្ត ក៏មិនអាចប្រព្រឹត្តទៅបានដែរ ប្រសិនបើប្រទេសកម្ពុជាយើងពុំបានបង្កើតច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តនានាឡើង។ នេះសរបញ្ជាក់ឱ្យឃើញថា ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត ដូចរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧ និងច្បាប់ដទៃផ្សេងៗទៀត ពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការធ្វើឱ្យប្រទេសកម្ពុជាយើងមានសណ្តាប់ធ្នាប់សង្គម និងមានការអភិវឌ្ឍន៍តាមបែបជឿនលឿន ព្រោះថាច្បាប់ទាំងនោះគ្រប់គ្រងទៅលើការប្រព្រឹត្តរបស់បុគ្គលម្នាក់ៗ មានន័យថា ប្រសិនបើបុគ្គលណាម្នាក់បានបំពានទៅលើច្បាប់ ឬមិនគោរពអ្វីទៅតាមដែលច្បាប់បានចែង ឬកំណត់នោះ បុគ្គលនោះនឹងប្រឈមមុខនឹងផ្លូវច្បាប់ជាក់ជាមិនខានឡើយ។

ដូច្នេះ យើងងាកមកមើលប្រធានបទ «ការអនុវត្តដោយបង្ខំ» វិញដែលមានចែងនៅក្នុងគន្ថីទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ វិញ ថាតើការអនុវត្តដោយបង្ខំ ត្រូវប្រព្រឹត្តទៅយ៉ាងដូចម្តេចនោះ យើងខ្ញុំនឹងធ្វើការសិក្សាទៅលើពីរជំពូកគឺ **សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំ**(ជំពូកទី១) និង**នីតិវិធីអនុវត្តដោយបង្ខំ** (ជំពូកទី២)។

# ជំពូកទី១

# សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំ

នៅក្នុងជំពូកទី១ នេះយើងនឹងធ្វើការសិក្សាទៅលើសញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំ។ ទាក់ទងនឹងសញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំនេះ យើងនឹងធ្វើការបកស្រាយទាក់ទងនឹងបទដ្ឋានគតិយុត្ត គោលគំនិត ភាគីនៃការអនុវត្តដែលមានម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត កម្មវត្ថុនៃការអនុវត្ត ការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់ និងមិនសងជាប្រាក់ ការអនុវត្តសិទ្ធប្រាតិភោគ ប្រភេទនៃការអនុវត្តដោយបង្ខំ ល័ក្ខខ័ណ្ឌនៃការដាក់ពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ស្ថាប័នអនុវត្តដែលមានតុលាការអនុវត្ត និងអាជ្ញាសាលាជាដើម។ មិនតែប៉ុណ្ណោះ យើងក៏បានសិក្សាពីប្រភេទនៃលិខិតអនុវត្តដោយបង្ខំរួមទាំងរូបមន្តអនុវត្តដោយបង្ខំផងដែរ។

## ១.១. បទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ

**ប្រព័ន្ធនៃការអនុវត្តដោយបង្ខំ** គឺជាប្រព័ន្ធមួយដែលធ្វើសម្រេចដោយបង្ខំនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគ របស់បុគ្គលឯកជន ដោយប្រើប្រាស់អំណាចរដ្ឋ ដើម្បីផ្តល់ការការពារដល់បុគ្គលឯកជនដែលជាម្ចាស់សិទ្ធិទាំងនោះ ហើយនីតិវិធីនេះ គឺជាផ្នែកមួយដ៏សំខាន់នៃប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ផងដែរ។ ហេតុនេះហើយបានជាបទប្បញ្ញត្តិជាច្រើន ដែលពាក់ព័ន្ធទៅនឹងនីតិវិធីនៃការអនុវត្តដោយបង្ខំក៏ដូចជាពាក់ព័ន្ធទៅនឹងស្ថាប័នអនុវត្ត ត្រូវបានចងក្រងជាផ្នែកមួយនៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា គឺនៅក្នុងគន្ថីទី៦ ស្តីពីការអនុវត្តដោយបង្ខំ និងគន្ថីទី៧ ស្តីពីការចាត់ចែងរក្សាការពារ។ នៅក្នុងអត្ថន័យជាទម្រង់ ច្បាប់ពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ ត្រូវសំដៅទៅលើគន្ថីទី៦ និងគន្ថីទី៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីនេះ។

## ១.២. គោលគំនិត

បុគ្គលដែលមានសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ឬច្បាប់ផ្សេងទៀតអាចទាមទារឱ្យសម្រេចសិទ្ធិនោះដោយការអនុវត្តដោយបង្ខំ តាមបញ្ញត្តិទី៦ ស្តីពីការអនុវត្តដោយបង្ខំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង។[2] មិនតែប៉ុណ្ណោះ បញ្ញត្តិពីគន្ថីទី២ ស្តីពីនីតិវិធីនៃការជំនុំជម្រះក្តីលើកទី១ ដល់គន្ថីទី៤ ដែលចែងពីការជំនុំជម្រះសារជាថ្មី នៃក្រមនិតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការអនុវត្តដោយបង្ខំ លើកលែងតែមានបញ្ញត្តិពិសេស។[3]

[2] មាត្រា៣៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[3] មាត្រា៣៣៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

## ១.៣. ភាគីនៃការអនុវត្តដោយបង្ខំ

ភាគីដែលបានដាក់ពាក្យសុំ ឱ្យអនុវត្តដោយបង្ខំ ត្រូវហៅថា **ម្ចាស់បំណុលនៃការអនុវត្ត** រីឯភាគីម្ខាងទៀត ត្រូវហៅថា **កូនបំណុលនៃការអនុវត្ត។**[4] នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំក៏បានលើកឡើងពីអ្នកតំណាងដោយអាណត្តិផងដែរ។[5]

## ១.៤. កម្មវត្ថុនៃការអនុវត្តដោយបង្ខំ

### ១.៤.១. ការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់

#### ក. ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺជាការអនុវត្តដោយបង្ខំដែលធ្វើឡើងតាមវិធីដែលអាជ្ញាសាលារឹបអូសយកចលនវត្ថុ ដែលមានគោលបំណងឲ្យសងជាប្រាក់ទៅម្ចាស់បំណុល នៃការអនុវត្តដែលសិទ្ធិទាមទារនេះមានកំណត់នៅក្នុងលិខិតអនុវត្ត។ ចលនវត្ថុ នៅទីនេះរួមមានចលនវត្ថុតាមក្រមរដ្ឋប្បវេណី និងផលធម្មជាតិដែលមិនទាន់បំបែកដីនៅឡើយហើយដែលអាចនឹងទទួលផលយ៉ាងច្បាស់នៅក្នុងអំឡុងពេល ១ (មួយ)ខែ។[6] ម្យ៉ាងវិញទៀត ចលនវត្ថុនៅទីនេះ ក៏រួមបញ្ចូលផងដែរនូវរូបិយវត្ថុ ដូចជាក្រដាសប្រាក់ និងកាក់ប្រាក់ដែលមិនទាមទារឲ្យមាននីតិវិធីនៃការប្តូរជាប្រាក់នោះទេ។ នីតិវិធីនៃការអនុវត្តដោយបង្ខំ ចំពោះចលនវត្ថុ ចាប់ផ្តើមនៃការរឹបអូសវត្ថុដែលជាកម្មវត្ថុដោយអាជ្ញាសាលា ដោយត្រូវផ្អែកលើពាក្យសុំរបស់ម្ចាស់បំណុល។[7] នៅក្នុងពាក្យសុំឲ្យអនុវត្ត ចំពោះចលនវត្ថុត្រូវសរសេរអំពីទីកន្លែងដែលចលនវត្ថុដែលត្រូវរឹបអូសនោះស្ថិតនៅ។[8] ក៏ប៉ុន្តែ គេមិនចាំបាច់ចង្អុលបង្ហាញពីទំហំនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការរឹបអូសទេ។ នៅទីតាំងនីមួយៗ ដែលបានរៀបរាប់នៅក្នុងពាក្យសុំ ចលនវត្ថុនៅទីនោះនឹងក្លាយជាកម្មវត្ថុនៃការរឹបអូស។ មូលហេតុនៃការកំណត់បែបនេះ គឺព្រោះតែវាមានការលំបាក នៅក្នុងការដែលចង្អុលចំៗនូវចលនវត្ថុតូចៗដែលខុសពីអចលនវត្ថុ និងសិទ្ធិលើបំណុល។ ការកំណត់ចលនវត្ថុនីមួយៗដែលទៅរឹបអូស គឺជាការងាររបស់អាជ្ញាសាលាដែលនឹងមានវត្តមាននៅកន្លែងអនុវត្តដោយបង្ខំ។ ការរឹបអូសចលនវត្ថុត្រូវធ្វើឡើងដោយអាជ្ញាសាលា ដែលនឹងទទួលការកាន់កាប់ចលនវត្ថុដែលកាន់កាប់ដោយកូនបំណុល ម្ចាស់បំណុល ឬតតិយជន។[9]

---

[4] មាត្រា៣៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[5] មាត្រា៣៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[6] មាត្រា៣៨៤ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[7] មាត្រា៣៨៤ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[8] មាត្រា៣៨៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[9] មាត្រា៣៨៥ និងមាត្រា៣៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

### ខ. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល គឺជាការអនុវត្តដោយបង្ខំដើម្បីសម្រេចនូវសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់របស់ម្ចាស់បំណុល តាមរយៈការរឹបអូសសិទ្ធិលើបំណុល ដែលមានកម្មវត្ថុជាការសងប្រាក់ ឬជាការប្រគល់ចលនវត្ថុដែលជារបស់កូនបំណុលហើយប្ដូរជាប្រាក់នៅតម្លៃសេដ្ឋកិច្ចនៃសិទ្ធិលើបំណុលនោះ។[10] សិទ្ធលើបំណុលដែលអាចជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលរួមមាន ***សិទ្ធិទាមទារឲ្យសងជាប្រាក់*** និង***សិទ្ធិទាមទារឱ្យប្រគល់វត្ថុ***។ ក្នុងចំណោមសិទ្ធិទាំងពីរប្រភេទនេះ **សិទ្ធិដែលត្រូវបានអនុវត្តច្រើនជាងគេនៅក្នុងករណីជាក់ស្តែង គឺសិទ្ធិទាមទារឲ្យសងជាប្រាក់**។ ឧទាហរណ៍ គំរូនៃករណីនេះគឺការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ដែលមានកម្មវត្ថុជាការទាមទារឲ្យសងជាប្រាក់បញ្ញើពីធនាគារ។

ការអនុវត្តមួយប្រភេទទៀតពោល គឺការអនុវត្តចំពោះសិទ្ធិលើបំណុល ដែលមានកម្មវត្ថុជាការប្រគល់ចលនវត្ថុ ត្រូវបានគេយកទៅប្រើប្រាស់នៅក្នុងករណីដែលអតិថិជនកាន់កាប់ចលនវត្ថុរបស់កូនបំណុល ហើយបានបដិសេធមិនព្រមប្រគល់ចលនវត្ថុនោះ។ ប្រសិនបើតតិយជន បដិសេធមិនព្រមប្រគល់ចលនវត្ថុទេនោះ គេមិនអាចធ្វើការអនុវត្តដោយបង្ខំចំពោះចលនវត្ថុនោះបានឡើយ។ ហេតុនេះហើយ គេពុំមានជម្រើសអ្វីផ្សេងឡើយក្រោយពីធ្វើការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដោយរឹបអូសសិទ្ធិទាមទារ ឱ្យប្រគល់ចលនវត្ថុរបស់កូនបំណុលនោះ។

លើសពីនេះទៅទៀត ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ក្រៅពីអចលនវត្ថុ នាវា ចលនវត្ថុ និងសិទ្ធិលើបំណុល ត្រូវអនុវត្តតាមវិធីអនុវត្តចំពោះសិទ្ធិលើបំណុល។[11] លើកលែងតែការបញ្ជាក់ផ្ទុយពីនេះ ការពន្យល់ចាប់ពីត្រឹមនេះតទៅ គឺស្ថិតក្នុងប្រភេទនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់។

ពាក្យសុំអនុវត្តចំពោះសិទ្ធិលើបំណុលត្រូវដាក់ទៅតុលាការអនុវត្ត។[12] តុលាការអនុវត្តនៅទីនេះ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលលំនៅដ្ឋាន ឬការិយាល័យជាអាទីរបស់កូនបំណុលស្ថិតនៅ ហើយប្រសិនបើគ្មានកន្លែងបែបនេះទេ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលលំនៅឋាន ឬការិយាល័យជាអាទីរបស់កូនបំណុលទី៣ស្ថិតនៅ។[13] នៅក្នុងពាក្យសុំអនុវត្តចំពោះសិទ្ធិលើបំណុល ក្រៅពីចំណុចដែលបានកំណត់នៅក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី២មាត្រា៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ត្រូវបញ្ជាក់អំពីកូនបំណុលទី៣ ផងដែរ។[14] ដោយសារតែចំណុចក នៃកថាខណ្ឌទី២ មាត្រា៣៤៩

[10] មាត្រា៤០២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[11] មាត្រា៤១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[12] មាត្រា៤០៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[13] មាត្រា៤០២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[14] មាត្រា៤០៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ទាមទារឱ្យមានការបញ្ជាក់អំពីសញ្ញាណនៃទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ដូច្នេះក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលចាំបាច់ត្រូវចង្អុលបង្ហាញ និងបញ្ជាក់អំពីសិទ្ធិលើបំណុលដែលត្រូវរឹបអូសផងដែរ។ ប៉ុន្តែ កម្រិតនៃការបញ្ជាក់នៅក្នុងករណីបែបនេះនឹងក្លាយជាបញ្ហា ព្រោះថានៅក្នុងករណីភាគច្រើនស្ថាប័នហិរញ្ញវត្ថុជាអាទិ៍មិនព្រមបង្ហាញព័ត៌មានទេ ដោយយកករណីយកិច្ចត្រូវរក្សាការសម្ងាត់ធ្វើជាមូលហេតុ។ ហេតុនេះហើយ ជាទូទៅវាមានការលំបាកក្នុងការបញ្ជាក់ឲ្យច្បាស់អំពីសិទ្ធិលើបំណុល។ នៅប្រទេសជប៉ុន មានការបកស្រាយថាការចង្អុលបញ្ជាក់អំពីសិទ្ធិលើបំណុលត្រឹមតែកម្រិតដែលធ្វើឲ្យកូនបំណុល ឬកូនបំណុលទី៣ អាចស្គាល់អំពីសញ្ញានៃសិទ្ធិលើបំណុលដែលត្រូវរឹបអូសនៅពេលបានលើដីកាសម្រេចរឹបអូសនោះជាការគ្រប់គ្រាន់ហើយ ហើយគេមិនចាំបាច់ទាមទារឲ្យបញ្ជាក់អំពីមូលហេតុនៃការបង្កើតសិទ្ធិលើបំណុលនិងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនោះទេ។

តុលាការអនុវត្ត ដែលបានទទួលពាក្យសុំឲ្យចេញដីកាសម្រេចដកហូតត្រូវពិនិត្យមើលថាតើវិធីនៃការដាក់ពាក្យសុំមានភាពត្រឹមត្រូវដែរឬទេ ហើយផ្នែកនៃការទាមទារនោះត្រូវបានហាមឃាត់ដែរឬទេ និងថាតើមានការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណដែរឬទេ។[15] តុលាការអនុវត្ត មិនពិនិត្យទៅលើអតិភាព ឬនត្ថិភាពនៃសិទ្ធិលើបំណុលដែលត្រូវរឹបអូសនោះទេ។ ម្យ៉ាងទៀត នៅមុនពេលចេញដីកាសម្រេចរឹបអូស តុលាការអនុវត្តមិនសួរកូនបំណុល និងកូនបំណុលទី៣ ទេ[16] ព្រោះថាបើសួរកូនបំណុល ឬកូនបំណុលទី៣ នៅមុនពេលចេញដីកាសម្រេចរឹបអូស កូនបំណុលនោះនឹងអាចមើលដឹងអំពីការរឹបអូសនៅមុនពេលចេញដីកាសម្រេចរឹបអូស ហើយអាចនឹងបញ្ចៀសការអនុវត្តដោយបង្ខំឲ្យប្រមូលសិទ្ធិលើបំណុល ដែលត្រូវប្តូរ ឬធ្វើការចាត់ចែងសិទ្ធិលើបំណុលនោះ ដូចជាការធ្វើអនុប្បទានជាអាទិ៍។ ដីការសម្រេចរឹបអូសដែលមានកម្មវត្ថុជាសិទ្ធិលើបំណុល ដែលពុំមានអត្ថិភាព នៅតែមានអានុភាពជាដីកាសម្រេចរឹបអូសហើយការកំណត់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិលើបំណុលត្រូវធ្វើតាមរយៈបណ្តឹងទាមទារប្រមូលបំណុល។[17]

ចំពោះសិទ្ធិលើបំណុលណាមួយ បើទោះបីជាវាមានតម្លៃលើសពីចំនួនទឹកប្រាក់នៃសិទ្ធិទាមទារឲ្យសងជាប្រាក់ ដែលបានកំណត់នៅក្នុងលិខិតអនុវត្ត និងសោហ៊ុយសម្រាប់ការអនុវត្តក៏ដោយ ក៏តុលាការអនុវត្តអាចដកហូតរបស់នោះទាំងអស់បាន[18] ដើម្បីសងបំណុលរបស់ម្ចាស់បំណុលឲ្យបានគ្រប់ ប្រសិនបើមានម្ចាស់បំណុលដទៃទៀតទាមទារឲ្យចែកចំណែកដែរ។ ប្រសិនបើ តម្លៃនៃសិទ្ធិលើបំណុល ដែលបានរឹបអូសមានលើសពីចំនួនទឹកប្រាក់សរុបនៃសិទ្ធិលើបំណុល ដែលបានកំណត់នៅក្នុងលិខិតអនុវត្ត និងសោហ៊ុយសម្រាប់ការអនុវត្ត នោះតុលាការអនុវត្តមិនត្រូវរឹបអូសិទ្ធិលើបំណុលផ្សេងទៀតឡើយ។[19] នេះគឺជាការហាមឃាត់ មិនឱ្យធ្វើការរឹប

[15] មាត្រា៥០៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[16] មាត្រា៥០៣ កថាខណ្ឌទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[17] មាត្រា៥១២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[18] មាត្រា៥០៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[19] មាត្រា៥០៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

អូសហួសប្រមាណដែលមានហេតុផលដូចគ្នាទៅនឹងករណី នៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដូចមាត្រា ៣៩១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ដែរ។ ចំពោះសេចក្តីសម្រេច អំពីពាក្យសុំឲ្យចេញដីកាសម្រេចរឹបអូស អាចប្តឹងជំទាស់បាន។[20]

### គ. ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

អចលនវត្ថុ ដែលអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុរួមមាន ដីអាគារដែលត្រូវបានចុះបញ្ជី ចំណែកកម្មសិទ្ធិអវិភាគ ឬដីអាគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍ដែលត្រូវបានចុះបញ្ជី ផលុបភោគដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិជួលអចិន្ត្រៃយ៍និងផលុបភោគនោះដែរ ដែលជាសិទ្ធិរួមសិទ្ធិអវិភាគមាត្រា។[21] ការចាត់ទុកថា អាគារ គឺជាអចលនវត្ថុឯករាជ្យអំពីដី ឬយ៉ាងណានោះវាអាស្រ័យទៅលើគោលនយោបាយនីតិកម្មរបស់ប្រទេសនីមួយៗ។ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវធ្វើតាមវិធីលក់ដោយបង្ខំ។[22]

ការលក់ដោយបង្ខំដែលជាវិធីអនុវត្តចំពោះអចលនវត្ថុ គឺជាវិធីអនុវត្តដែលតាមរយៈនោះតុលាការអនុវត្តរឹបអូសអចលនវត្ថុ ដែលជាកម្មសិទ្ធិរបស់កូនបំណុល រួចលក់អចលនវត្ថុនោះដោយបង្ខំ ហើយទើបយកប្រាក់ដែលបានមកពីការលក់នោះទៅសម្រេចសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់របស់ម្ចាស់បំណុល។ ការលក់ដោយបង្ខំ ចាប់ផ្តើមដោយដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ ដែលតុលាការអនុវត្ត ចេញតាមពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ របស់ម្ចាស់បំណុលនៃការអនុវត្តមាត្រា។[23] នៅក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុស្ថាប័នអនុវត្ត គឺតុលាការអនុវត្ត។[24]

### ខ. ការអនុវត្តដោយបង្ខំចំពោះនាវា

នាវា សំដៅទៅជលយានដែលមានចំណុះសរុបជាតោនស្មើនឹង និងលើសពី ២០តោននិងជលយានដែលមានចំណុះសរុបជាតោនក្រោម ២០តោនហើយដែលត្រូវបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាយោងតាមមាត្រា៤៥៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។[25] ចំពោះជលយាន ដែលមានចំណុះសរុបជាតោនស្មើនឹង និងលើសពី ២០តោននោះទោះបីជាមិនត្រូវបានចុះបញ្ជីក៏ដោយក៏ចាត់ទុកថាជានាវាក្នុង នៃក្រមនីតិវិធីរដ្ឋប្បវេណីដែរ។ ចំណុះសរុបជាតោន ដែលអក្សរកាត់ជាភាសាអង់គ្លេសហៅថា GT (Gross Tonnage) គឺជារង្វាស់ទំហំនៃនាវា ដែលគេប្រើច្រើនបំផុតនាពេលបច្ចុប្បន្ននេះ។

---

[20] មាត្រា៤០៣ កថាខណ្ឌទី១១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[21] មាត្រា៤១៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[22] មាត្រា៤១៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[23] មាត្រា៤១៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[24] មាត្រា៤១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[25] គន្ថីទី6 ការអនុវត្តដោយបង្ខំ និងគន្ថីទី៧ ការចាត់ចែងរក្សាការពារ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

មួយវិញទៀត ជលយាន ដែលជាទូក «ថៃវ» ឬ «អ៊ុំ» មិនត្រូវបានរាប់ជានាវាតាមន័យច្បាប់នេះ ទេ គឺត្រូវរាប់ជាចលនវត្ថុ ដែលអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុវិញ យោងតាមបញ្ញត្តិចាប់ពីមាត្រា៣៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។ ចំពោះនាវាដែលកំពុងស្ថិតក្នុងការសាងសង់ ត្រូវអនុលោមទៅតាមវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ។ ប្រដាប់ឧបករណ៍ទាំងឡាយដែលមានភ្ជាប់ជាមួយនឹងនាវា ត្រូវក្លាយជាកម្មវត្ថុនៃការរឹបអូស តែក្នុងករណីដែលឧបករណ៍ទាំងនោះត្រូវបានរឹបអូសជាមួយគ្នានឹងនាវាដែរ។

តាមក្រមរដ្ឋប្បវេណីនាវា គឺជាចលនវត្ថុ។ ក៏ប៉ុន្តែ ដោយសារវាមានតម្លៃប្រហាក់ប្រហែលនឹងអចលនវត្ថុដែរ ហើយម្យ៉ាងទៀត លទ្ធកម្ម ការបាត់បង់ ឬការផ្លាស់ប្តូរនូវកម្មសិទ្ធិលើនាវាដែលធ្វើឡើងតាមការចុះបញ្ជីត្រូវតែប្រកាសជាសាធារណៈ ដូចនេះចំពោះបច្ចេកទេសនៅក្នុងការអនុវត្តដោយបង្ខំ គេចាំបាច់ត្រូវយកវិធានទូទៅសម្រាប់ការអនុវត្តចំពោះអចលនវត្ថុមកអនុវត្តឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ហេតុនេះហើយ បានជានៅក្នុងបញ្ញត្តិច្បាប់ស្តីពីការអនុវត្តដោយបង្ខំ នាវាមិនត្រូវបានចាត់ទុកជាចលនវត្ថុទេ តែជាអ្វីដែលមានលក្ខណៈដូចអចលនវត្ថុទៅវិញ។ នាវាដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះនាវា នៅទីនេះ សំដៅទៅលើនាវាដែលមានរចនាសម្ព័ន្ធជាក់លាក់មួយ និងដែលមានសមត្ថភាពអាចធ្វើដំណើរតាមផ្លូវទឹកដើម្បីដឹកអ្នកដំណើរ ឬវត្ថុផ្សេងៗបាន។ នៅក្នុងករណីនេះពាក្យថា ទឹក រួមបញ្ចូលទាំងលើទឹក និងក្នុងទឹក។ កាប៉ាល់ Hovercraft (ប្រើក្តោង) នឹង Hydrofoil សុទ្ធតែជានាវា។

សញ្ជាតិរបស់នាវា ពុំចោទជាបញ្ហានោះទេ។ ចំពោះនាវាដែលដាក់ទង់ជាតិដើម្បីបង្កភាពងាយស្រួល ពោលគឺនាវាដែលមានសញ្ជាតិផ្សេងពីសញ្ជាតិរបស់ម្ចាស់នាវានោះ ឱ្យតែនាវានោះមានទីតាំងនៅក្នុងរង្វង់អធិបតេយ្យភាពរបស់ព្រះរាជាណាចក្រកម្ពុជា ការអនុវត្តដោយបង្ខំអាចធ្វើឡើងចំពោះចំពោះនាវានោះបាន។ ទោះជាយ៉ាងណាក៏ដោយ ល័ក្ខខ័ណ្ឌដើម្បីក្លាយជានាវារបស់កម្ពុជាត្រូវកំណត់តាមច្បាប់ដោយឡែក។ ចំពោះល័ក្ខខ័ណ្ឌដើម្បីទទួលបាននូវសញ្ជាតិរបស់នាវាប្រទេសនីមួយៗមានការកំណត់ផ្សេងៗពីគ្នា ដោយបូកផ្សំនូវលក្ខណៈមួយចំនួនដូចជា កម្មសិទ្ធិរបស់ពលរដ្ឋនៃប្រទេសខ្លួន ការផលិតដោយពលរដ្ឋនៃប្រទេសខ្លួន និងយានិកជាពលរដ្ឋនៃប្រទេសខ្លួន ជាអាទិ៍។ ការកំណត់អំពីការទទួលសញ្ជាតិនាវារបស់កម្ពុជានឹងធ្វើឲ្យគេអាចបែងចែករវាងនាវាកម្ពុជា និងនាវាបរទេសបាន។

ការអនុវត្តដោយបង្ខំចំពោះនាវាជាមូលដ្ឋាន ត្រូវធ្វើឡើងតាមវិធីដែលស្របទៅតាមវិធីលក់ដោយបង្ខំនៃអចលនវត្ថុ ពោលគឺធ្វើឡើងតាមរយៈការលក់ដោយបង្ខំនូវនាវាដែលជាកម្មវត្ថុមាត្រា។[26] ការគ្រប់គ្រងដោយបង្ខំមិនអាចធ្វើឡើងបានឡើយ ហើយតាមច្បាប់របស់ប្រទេសជប៉ុន ការគ្រប់គ្រងដោយបង្ខំនៅពេលធ្វើការអនុវត្តចំពោះនាវា ក៏មិនត្រូវបានអនុញ្ញាតដែរ។នេះគឺធានាដល់ផលប្រយោជន៍នៃការដឹកជញ្ជូន។ ចំពោះការអនុវត្ត

[26] មាត្រា៤៥៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ដោយបង្ខំចំពោះនាវាសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវាស្ថិតនៅ នៅពេលចេញដោយការចាប់ផ្តើមការលក់ដោយបង្ខំ មានសមត្ថកិច្ចជាតុលាការអនុវត្ត។[27]

នីតិវិធីនៃការលក់ដោយបង្ខំនូវនាវា ត្រូវធ្វើឡើងដោយអនុលោមទៅតាមនីតិវិធីប្រហាក់ប្រហែលគ្នា និងនីតិវិធីលក់ដោយបង្ខំនូវអចលនវត្ថុ។ ខាងក្រោមនេះជាចំណុចពិសេសនៃនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះនាវា៖

- ពាក្យសុំអនុវត្តដោយបង្ខំចំពោះនាវា និងឯកសារភ្ជាប់
- ការរឹបអូស
- ដកហូតយកលិខិតបញ្ជាក់សញ្ជាតិនាវាជាអាទិ៍
- ពេលដែលការរឹបអូសបង្កើតអានុភាព
- ដីកាសម្រេចបង្គាប់ឱ្យប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវាជាអាទិ៍ នៅមុនពេលដាក់ពាក្យសុំអនុវត្តដោយបង្ខំ
- ការជ្រើសតាំងអ្នកថែរក្សាគ្រប់គ្រងជាអាទិ៍
- ការលុបចោលនីតិវិធីលក់បង្ខំ ដោយដាក់ប្រាក់ធានា
- ការអនុញ្ញាតឱ្យនាវាធ្វើដំណើរ
- ការផ្ទេររឿងក្តី
- ម្ចាស់បំណុលដែលមានសិទ្ធិអាចទាមទារឲ្យចែកចំណែកបាន។

### ១.៤.២. ការអនុវត្តសិទ្ធិប្រាតិភោគ

#### ក. ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ

ទោះបីជាក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្ត មិនដាក់លិខិតអនុវត្តដែលបានកំណត់ក្នុងមាត្រា ៤៩៦ ចែងពីលិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ទៅអាជ្ញាសាលាក៏ដោយ បើបានដាក់ចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ឬបានដាក់ឯកសារដែលបញ្ជាក់ថាអ្នកកាន់កាប់ចលនវត្ថុបានយល់ព្រមចំពោះការរឹបអូស ក៏ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុអាចចាប់ផ្តើមបានដែរ។ បើការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុត្រូវបានចាប់ផ្តើមដោយយោងតាមមាត្រា៥០០ស្តីពី លក្ខខ័ណ្ឌនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ កម្មសិទ្ធករនៃចលនវត្ថុ ឬកូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា អាចយកនត្ថិភាព ឬការរលត់នៃសិទ្ធិប្រតិភោគ មកធ្វើជាមូលហេតុក្នុងពាក្យសុំតវ៉ាចំពោះការអនុវត្តនូវការរឹបអូសនោះបាន។ ក្នុងពាក្យសុំឲ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ អ្នកដាក់ពាក្យសុំត្រូវសរសេរនូវចំណុចដូចខាងក្រោម៖

[27] មាត្រា៤៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

- សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធករនៃចលនវត្ថុដែលជាកូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា និងអ្នកតំណាង
- សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា
- សញ្ញាណនៃចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ និងទីកន្លែងនៃចលនវត្ថុនោះ
- ហេតុការណ៍ និងទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិប្រាតិភោគចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានានោះ។

យោងតាមមាត្រា៥០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ចែងពីបញ្ញត្តិស្ដីពីការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ដែលមិនត្រូវអនុវត្តឡើយ ចំពោះនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ មានដូចខាងក្រោមនេះ៖

- ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស[28]
- ការប្ដូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស[29]
- ការហាមឃាត់មិនឱ្យរឹបអូសហួសប្រមាណ[30]

### ខ. ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធលើបំណុល

ក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរនូវចំណុចដូចខាងក្រោមនេះ៖

- សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា កូនបំណុលទី៣ និងអ្នកតំណាង
- សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា
- សញ្ញាណនៃសិទ្ធិលើបំណុលដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ
- ហេតុការណ៍ និងទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិប្រាតិភោគចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានានោះ។

អ្នកដាក់ពាក្យសុំ ត្រូវភ្ជាប់ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលបានកំណត់នៅក្នុងមាត្រា៤៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ជាមួយនឹងពាក្យសុំដែលបានកំណត់ក្នុងមាត្រា៥០៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

---

[28] មាត្រា៣៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[29] មាត្រា៣៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[30] មាត្រា៣៩១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

### គ. ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ

ក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ អ្នកដាក់ពាក្យសុំត្រូវសរសេរនូវចំណុចមួយចំនួនដូចខាងក្រោម[31]៖

- សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធករនៃអចលនវត្ថុដែលជាកូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា និងអ្នកតំណាង
- សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា
- សញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ
- ហេតុការណ៍ និងទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិប្រាតិភោគចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានា។

នៅក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ក្រៅពីឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារដែលបានកំណត់ដូចខាងក្រោម៖

- ករណីដែលអនុវត្តសិទ្ធិប្រាតិភោគផ្សេងពីឯកសិទ្ធិទូទៅ៖ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី
- ករណីដែលអនុវត្តឯកសិទ្ធិទូទៅ៖ ចំពោះអចលនវត្ថុដែលត្រូវបានចុះបញ្ជី ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជី និងក្នុងករណីដែលជនដទៃក្រៅពីកូនបំណុលនៃការអនុវត្ត ត្រូវបានចុះនៅក្នុងសៀវភៅចុះបញ្ជីថា ជាកម្មសិទ្ធិករ គឺឯកសារដែលបញ្ជាក់ថា អចលនវត្ថុនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត។ ចំពោះដីធ្លីដែលមិនត្រូវបានចុះបញ្ជី ឯកសារដែលបញ្ជាក់ថា ដីធ្លីជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត។

សិទ្ធិប្រាតិភោគប្រត្យក្សលើអចលនវត្ថុ សិទ្ធិប្រត្យក្សប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុ និងសិទ្ធិជួលអចលនវត្ថុ ត្រូវបន្តអត្ថិភាព ក្រោយការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគ។ ក្រៅពីសិទ្ធិដែលបានកំណត់នៅក្នុងមាត្រា៥១០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ សិទ្ធិលើអចលនវត្ថុត្រូវរលត់ដោយការលក់។ ការរឹបអូស ការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន និងការអនុវត្តការចាត់ចែងជាបណ្តោះអាសន្នដែលមិនអាចតតាំងនឹងម្ចាស់បំណុលដែលបានធ្វើការរឹបអូសជាបណ្តោះអាសន្ន ដែលទាក់ទងនឹងអចលនវត្ថុ នឹងបាត់បង់អានុភាពដោយការរលត់។ បើអ្នកដែលមានទំនាក់ទំនងផលប្រយោជន៍ បានរាយការណ៍ថា បានធ្វើការព្រមព្រៀង មុនពេលតម្លៃលក់អប្បបរមាត្រូវបានកំណត់ប្រែប្រួលនៃសិទ្ធិលើអចលនវត្ថុ ត្រូវអនុលោមតាមការព្រមព្រៀងនោះ។

[31] មាត្រា៥០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

### ឃ. ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា

ក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរនូវចំណុចមួយចំនួនដូចខាងក្រោម[32]៖

- សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធករនៃនាវាដែលជាកូនបំណុលនៃការអនុវត្តកូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា និងអ្នកតំណាង
- សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា
- សញ្ញាណនៃនាវាដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ
- ទីកន្លែងដែលនាវាស្ថិតនៅព្រមទាំងឈ្មោះរបស់មេបញ្ជាការឬបរិបាលនាវានិងទីកន្លែងដែលមេបញ្ជាការឬបរិបាលនាវានោះនៅនាពេលបច្ចុប្បន្ន
- ហេតុការណ៍ និងទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិប្រាតិភោគចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានា។

នៅក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគ ក្រៅពីឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារដែលបានកំណត់ដូចខាងក្រោម៖

- ករណីដែលអនុវត្តសិទ្ធិប្រាតិភោគផ្សេងពីឯកសិទ្ធិទូទៅ៖ ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជី
- ករណីដែលអនុវត្តឯកសិទ្ធិទូទៅ៖ ចំពោះនាវាដែលត្រូវបានចុះបញ្ជី ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជី និងក្នុងករណីដែលជនដទៃក្រៅពីកូនបំណុលនៃការអនុវត្តត្រូវបានចុះ នៅក្នុងសៀវភៅចុះបញ្ជីថាជាកម្មសិទ្ធិករគឺឯកសារដែលបញ្ជាក់ថា នាវានោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត។ ចំពោះនាវាដែលមិនត្រូវបានចុះបញ្ជីគឺឯកសារដែលបញ្ជាក់ថានាវាជាកម្មសិទ្ធិ របស់កូនបំណុលនៃការអនុវត្ត។

តុលាការអនុវត្តអាចចេញដីកាសម្រេចបង្គាប់ឱ្យអ្នកកាន់កាប់នាវាប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវាជាអាទិ៍ ទៅឱ្យអាជ្ញាសាលា តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តបាន។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះជនដែលត្រូវបានទទួលស្គាល់ថា កំពុងកាន់កាប់ដោយផ្អែកលើមូលហេតុគតិយុត្តនៃសិទ្ធិ ដែលអាចតតាំងនឹងម្ចាស់បំណុលនៃការអនុវត្តបាន។ ចំពោះដីកាសម្រេចអំពីពាក្យសុំ អាចប្ដឹងជំទាស់បាន។ ចំពោះដីកាសម្រេច ទោះជានៅមុនពេលបញ្ជូនទៅឱ្យភាគីម្ខាងទៀតក៏ដោយ ក៏អាចអនុវត្តបានដែរ។

[32] មាត្រា៥២១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

### ១.៤.៣. ការអនុវត្តដោយបង្ខំដែលពុំមានគោលបំណងឱ្យសងជាប្រាក់

#### ក. ការអនុវត្តសិទ្ធិតាមទាមទារឱ្យប្រគល់វត្ថុ

##### ក.១. ការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ ឬនាវា ឬវត្ថុផ្សេងទៀត

ការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ ឬនាវា ឬវត្ថុផ្សេងទៀត ដែលមនុស្សរស់នៅក្នុងនោះ ត្រូវធ្វើតាមនីតិវិធីដែលអាជ្ញាសាលានៃសាលាដំបូង ដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅរំលាយការកាន់កាប់វត្ថុ ដែលជាកម្មវត្ថុរបស់កូនបំណុលនៃការអនុវត្ត ហើយធ្វើឲ្យម្ចាស់បំណុលនៃការអនុវត្តទទួលបាននូវការកាន់កាប់នោះ។ ការអនុវត្តដោយបង្ខំដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះអាចធ្វើបានលុះត្រាតែម្ចាស់បំណុលនៃការអនុវត្ត ឬអ្នកតំណាងរបស់ម្ចាស់បំណុលនៃការអនុវត្តនោះបានបង្ហាញខ្លួននៅកន្លែងអនុវត្ត។ នៅពេលធ្វើការអនុវត្ត ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ អាជ្ញាសាលាអាចចូលទៅក្នុងអចលនវត្ថុ នាវា ឬវត្ថុផ្សេងទៀត ដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត ហើយបើចាំបាច់អាចធ្វើការចាត់ចែងជាចាំបាច់ដើម្បីបើកទ្វារដែលបិទនោះ។ ក្នុងការអនុវត្តដោយបង្ខំដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះអាជ្ញាសាលាត្រូវដកចេញនូវចលនវត្ថុដែលមិនមែនជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំនោះ ហើយត្រូវប្រគល់ចលនវត្ថុទាំងនោះ ទៅឲ្យកូនបំណុលនៃការអនុវត្ត ឬអ្នកតំណាងរបស់កូនបំណុលនោះ ឬញាតិនៅជាមួយ ឬអ្នកបម្រើ ឬអ្នកផ្សេងដែលធ្វើការនៅទីនោះ ដែលមានការយល់ដឹងសមរម្យ។ ក្នុងករណីនេះប្រសិនបើមិនអាចប្រគល់ចលនវត្ថុនោះទៅឲ្យជនទាំងឡាយដែលបានរៀបរាប់ខាងលើនេះបានទេ អាជ្ញាសាលាត្រូវថែរក្សាគ្រប់គ្រងចលនវត្ថុនោះ។ សោហ៊ុយសម្រាប់ថែរក្សាគ្រប់គ្រង ត្រូវចាត់ជាសោហ៊ុយសម្រាប់ការអនុវត្ត។ បើមិនអាចប្រគល់ចលនវត្ថុឱ្យទៅជនដូចបានរៀបរាប់ខាងលើនោះទេ អាជ្ញាសាលាអាចលក់ចលនវត្ថុនោះ តាមវិធីលក់នៃការអនុវត្តចំពោះចលនវត្ថុបាន។ បើបានលក់ចលនវត្ថុ អាជ្ញាសាលាត្រូវដកចេញពីចំនួនទឹកប្រាក់ដែលបានមកពីការលក់នូវសោហ៊ុយដែលបានចំណាយក្នុងការលក់ និងការថែរក្សាគ្រប់គ្រង ហើយត្រូវចាត់ទុកប្រាក់ដែលនៅសេសសល់នោះ នៅសាលាដំបូងដែលខ្លួនស្ថិតនៅ។ បើបានបញ្ចប់ការអនុវត្តដោយបង្ខំ អាជ្ញាសាលាត្រូវជូនដំណឹងនោះទៅឲ្យកូនបំណុលនៃការអនុវត្ត។

##### ក.២. ការអនុវត្តដោយបង្ខំឲ្យប្រគល់ចលនវត្ថុក្រៅពីអចលនវត្ថុ

ការអនុវត្តដោយបង្ខំឲ្យប្រគល់ចលនវត្ថុក្រៅពីអចលនវត្ថុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ នៃមាត្រា៥២៤ ដែលចែងពីការអនុវត្តដោយបង្ខំឲ្យប្រគល់ចលនវត្ថុជាអាទិ៍ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ត្រូវធ្វើតាមនីតិវិធីដែលអាជ្ញាសាលានៃសាលាដំបូង ដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅដកយកចលនវត្ថុពីកូនបំណុលនៃការអនុវត្ត ហើយប្រគល់ចលនវត្ថុនោះ ទៅឲ្យម្ចាស់បំណុលនៃការអនុវត្ត។ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត ឬអ្នកតំណាងពុំបានបង្ហាញខ្លួននៅទីកន្លែងធ្វើការអនុវត្តដោយបង្ខំ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះទេ អាជ្ញាសាលាអាចព្យួរការអនុវត្តដោយបង្ខំនោះបាន បើទទួល

ស្គាល់ថា ពុំអាចជៀសវាងបានដោយគិតពិចារណាលើប្រភេទ និងចំនួនជាអាទិ៍ នៃចលនវត្ថុដែលពាក់ព័ន្ធនោះ។ ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តដោយបង្ខំ ឬអ្នកតំណាងពុំបានបង្ហាញខ្លួននៅទីកន្លែងធ្វើការអនុវត្តដោយបង្ខំឲ្យប្រគល់ចលនវត្ថុទេ បើបានដកយកចលនវត្ថុនោះពីកូនបំណុលនៃការអនុវត្ត អាជ្ញាសាលាត្រូវថែរក្សាគ្រប់គ្រងចលនវត្ថុនោះ។

**ក.៣. ការអនុវត្តដោយបង្ខំឲ្យប្រគល់ ក្នុងករណីវត្ថុដែលជាកម្មវត្ថុ ត្រូវបានកាន់កាប់ដោយតតិយជន**

ការអនុវត្តដោយបង្ខំឲ្យប្រគល់ ក្នុងករណីវត្ថុដែលជាកម្មវត្ថុ ត្រូវបានកាន់កាប់ដោយតតិយជនយោងតាមបញ្ញត្តិមាត្រា៥២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។ ក្នុងករណីដែលតតិយជនកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ហើយតែជននោះមានករណីយកិច្ចត្រូវប្រគល់វត្ថុនោះឲ្យទៅកូនបំណុលនៃការអនុវត្ត ការអនុវត្តដោយបង្ខំឲ្យប្រគល់វត្ថុនេះ ត្រូវធ្វើតាមវិធីដែលតុលាការអនុវត្តរឹបអូសសិទ្ធិទាមទារឱ្យប្រគល់របស់កូនបំណុលនៃការអនុវត្តដែលមានចំពោះតតិយជននោះ ហើយចេញដីកាសម្រេចអនុញ្ញាតឲ្យម្ចាស់បំណុលនៃការអនុវត្ត អនុវត្តសិទ្ធិទាមទារនោះ។

**ខ.ការអនុវត្តជំនួស**

**ការអនុវត្តជំនួស** គឺជាវិធីដែលអនុញ្ញាតឱ្យម្ចាស់បំណុល ឬតតិយជន សម្រេចនូវខ្លឹមសារនៃតាវកាលិកជំនួសកូនបំណុល ហើយប្រមូលសោហ៊ុយនោះ ជាប្រាក់ពីកូនបំណុលវិញ យោងតាមមាត្រា៥២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

ក្នុងករណីដែលកាតព្វកិច្ចមានខ្លឹមសារដែលឲ្យធ្វើសកម្មភាពណាមួយ ហើយឲ្យតែតតិយជនធ្វើជំនួសកូនបំណុលបាន ការអនុវត្តដោយបង្ខំចំពោះកាតព្វកិច្ចនោះ ត្រូវធ្វើតាមវិធីដែលតុលាការអនុវត្តចេញដីកាសម្រេចអនុញ្ញាតឲ្យម្ចាស់បំណុលនៃការអនុវត្ត ឲ្យតែតតិយជនបំពេញសកម្មភាពនោះជំនួស ដោយប្រើសាហ៊ុយរបស់កូនបំណុល នៃការអនុវត្តតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត។ តុលាការអនុវត្ត គឺតុលាការដែលបានកំណត់នៅក្នុងចំណុចនីមួយៗតាមការបែងចែកនូវលិខិតអនុវត្ត ដែលបានកំណត់នៅក្នុងចំណុចក ឬចំណុចគកថាខណ្ឌទី៣មាត្រា៣៦៣ស្តីពីបណ្តឹងតវ៉ាចំពោះការទាមទារ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។ បើចេញដីកាសម្រេច តុលាការអនុវត្តត្រូវសួរកូនបំណុលនៃការអនុវត្ត។ តុលាការអនុវត្តអាចបង្គាប់ឲ្យកូនបំណុលនៃការអនុវត្តបង់សោហ៊ុយដែលត្រូវការចាំបាច់ សម្រាប់បំពេញសកម្មភាពដែលបានកំណត់នៅក្នុងដីកាសម្រេចនោះ ទៅឲ្យម្ចាស់បំណុលនៃការអនុវត្តជាមុនបានតាមពាក្យសុំ។ ចំពោះសេចក្តីសម្រេចអំពីពាក្យសុំឲ្យអនុវត្តដោយបង្ខំ ឬអំពីពាក្យសុំនេះអាចប្តឹងជំទាស់បាន។ ត្រូវយកមកអនុវត្តបានផងដែរ ចំពោះករណីដែលកាតព្វកិច្ចមានខ្លឹមសារដែលមិនឱ្យធ្វើសកម្មភាពណាមួយ ហើយម្ចាស់បំណុលនៃការអនុវត្តទាមទារឲ្យដកចេញ នូវលទ្ធផលនៃ

សកម្មភាពផ្ទុយនឹងករណីកិច្ចមិនត្រូវធ្វើសកម្មភាព ទាមទារឲ្យបង្កើតការសាងសង់ ដើម្បីបង្ការសកម្មភាពផ្ទុយនោះ ឬទាមទារមធ្យោបាយផ្សេងទៀតដែលសមរម្យដោយប្រើឈ្មោះរបស់កូនបំណុលនៃការអនុវត្ត។

### គ. វិធានបង្ខំដោយប្រយោល

ការអនុវត្តដោយបង្ខំចំពោះកាតព្វកិច្ច ដែលមានគោលបំណងឱ្យធ្វើ ឬមិនឱ្យធ្វើសកម្មភាពណាមួយ ក៏អាចធ្វើបានតាមវិធីដែលតុលាការអនុវត្តចេញដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត បង់នូវចំនួនទឹកប្រាក់ជាកំណត់ដែលទទួលស្គាល់ថាសមរម្យដើម្បីធានាការអនុវត្តកាតព្វកិច្ច ទៅឱ្យម្ចាស់បំណុលនៃការអនុវត្តស្របទៅតាមអំឡុងពេលនៃការយឺតយ៉ាវ ឬកំណត់អំឡុងពេលដែលទទួលស្គាល់ថាសមរម្យដើម្បីអនុវត្តអនុវត្តកាតព្វកិច្ច ហើយបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត បង់នូវចំនួនទឹកប្រាក់ជាកំណត់ដែលទទួលស្គាល់ថាសមរម្យដើម្បីធានាការអនុវត្តកាតព្វកិច្ច ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ដោយភ្លាមៗ បើពុំបានអនុវត្តក្នុងអំឡុងពេលនោះ។

តុលាការអនុវត្តដែលបញ្ញត្តិនៅក្នុងមាត្រា៥២៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ គឺតុលាការដែលកំណត់នៅក្នុងចំណុចនីមួយៗ តាមការបែងចែកនៃលិខិតអនុវត្តដែលបានកំណត់ក្នុងចំណុចក ឬចំណុចគ កថាខណ្ឌទី៣ មាត្រា៣៦៣ ស្ដីពីបណ្ដឹងតវ៉ាចំពោះការទាមទារ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។ បើមានការផ្លាស់ប្ដូរស្ថានភាព តុលាការអនុវត្តអាចផ្លាស់ប្ដូរដីកាសម្រេច តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ឬរបស់កូនបំណុលនៃការអនុវត្តបាន បើយោងតាមបញ្ញត្តិមាត្រា៥២៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។ បើចេញដីកាម្រេចដែលយោងតាមបញ្ញត្តិនៃមាត្រា៥២៨ កថាខណ្ឌទី១ ឬទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦នេះ តុលាការអនុវត្តត្រូវសួរភាគីម្ខាងទៀតនៃអ្នកដាក់ពាក្យសុំ។

ក្នុងករណីដែលមានការបង់ប្រាក់ដែលត្រូវបង្គាប់ បើចំនួនទឹកប្រាក់នៃការខូចខាតដែលបានកើតឡើងដោយការមិនអនុវត្តកាតព្វកិច្ច លើសចំនួនទឹកប្រាក់ដែលបានបង់នោះ ម្ចាស់បំណុលនៃការអនុវត្តអាចទាមទារសំណងការខូចខាត ចំពោះចំនួនទឹកប្រាក់ដែលលើសនោះបាន។ ចំពោះសេចក្ដីសម្រេចអំពីពាក្យសុំអនុវត្តដោយបង្ខំ ដែលបានកំណត់នៅក្នុងមាត្រា៥២៨ កថាខណ្ឌទី១ ឬអំពីពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី៣ នៃនៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ អាចប្ដឹងជំទាស់បាន។

### ឃ. ការចាត់ទុកថាបានបង្ហាញឆន្ទៈ

យោងតាមមាត្រា៥២៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ បានចែងអំពីការចាត់ទុកថាបានបង្ហាញឆន្ទៈ។ បើសាលក្រម សាលដីកា ឬដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្តបង្ហាញឆន្ទៈ បានចូលជាស្ថាពរហើយ ឬបើលិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សា ឬការទទួលស្គាល់ដែលមានខ្លឹមសារថា កូនបំណុលនៃការ

អនុវត្តត្រូវបង្ហាញឆន្ទៈ បានបង្កើតអានុភាពឡើង ត្រូវចាត់ទុកថា កូនបំណុលនៃការអនុវត្តបានបង្ហាញឆន្ទៈ នៅពេលនៃការចូលជាស្ថាពរ ឬការបង្កើតអានុភាពនោះ។

ប៉ុន្តែ បើសិទ្ធិទាមទារឱ្យបង្ហាញឆន្ទៈនោះ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ឬពេលកំណត់មិនពិតប្រាកដ ត្រូវចាត់ទុកថា កូនបំណុលនៃការអនុវត្តនោះបានបង្ហាញឆន្ទៈ នៅពេលដែលរូបមន្តអនុវត្តត្រូវបានផ្តល់ តាមបញ្ញត្តិនៃកថាខណ្ឌទី១ នៃមាត្រា៣៥៦ រូបមន្តអនុវត្តពិសេស នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

បើការបង្ហាញឆន្ទៈរបស់កូនបំណុលនៃការអនុវត្ត ត្រូវធ្វើដោយប្តូរជាមួយនឹងតាវកាលិកតប ត្រូវចាត់ទុកថា កូនបំណុលនៃការអនុវត្តនោះបានបង្ហាញឆន្ទៈ នៅពេលដែលរូបមន្តអនុវត្តត្រូវបានផ្តល់។ នៅក្នុងករណីដែលការបង្ហាញឆន្ទៈរបស់កូនបំណុលនៃការអនុវត្ត ត្រូវធ្វើដោយប្តូរជាមួយនឹងតាវកាលិកតបរបស់ម្ចាស់បំណុលនៃការអនុវត្ត រូបមន្តអនុវត្តអាចផ្តល់បាន លុះត្រាតែម្ចាស់បំណុលនៃការអនុវត្តបានដាក់លិខិតបញ្ជាក់ថា ខ្លួនបានផ្តល់ ឬបានស្នើផ្តល់តាវកាលិកតបនោះហើយ។

## ១.៥. ប្រភេទការអនុវត្តដោយបង្ខំ

### ១.៥.១. ការអនុវត្តបែបបុគ្គលភាព និងការអនុវត្តបែបសម្ភារៈ

នេះគឺជាការបែងចែកដោយឈរលើទស្សនវិស័យ នៃកម្មវត្ថុនៃការអនុវត្តដោយបង្ខំ។ កម្មវត្ថុនៃការអនុវត្តបែបបុគ្គលភាព គឺមិនត្រឹមតែជាវត្ថុ ឬទ្រព្យសម្បត្តិដែលកូនបំណុលគ្រប់គ្រងប៉ុណ្ណោះទេ តែរួមទាំងរាងកាយ និងកម្លាំងពលកម្មរបស់កូនបំណុល ដែលអាចយកទៅសម្រេចសិទ្ធិទាមទារផងដែរ។ នៅក្នុងទ្វីបអឺរ៉ុប កាលពីសម័យដើម មានការអនុញ្ញាតឱ្យលើកកូនបំណុលឱ្យទៅធ្វើការជាទាសករ ឬបង្ខាំងកូនបំណុលឱ្យធ្វើការ ដើម្បីដោះបំណុលទៀតផង។ ក៏ប៉ុន្តែ ប្រព័ន្ធច្បាប់ទំនើប ដែលគោរពបុគ្គលភាពឯកជន បានធ្វើការហាមឃាត់ជាគោលការណ៍ មិនឱ្យមានការអនុវត្តតាមវិធីណាមួយដែលរារាំងសេរីភាពរូបកាយរបស់បុគ្គលណាម្នាក់ ដើម្បីអនុវត្តកាតព្វកិច្ចដែលបានកំណត់នៅក្នុងនីតិឯកជនឡើយ។ ក្រមនីតិវិធីនៃព្រះរាជាណាចក្រកម្ពុជា បានកម្រិតកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ត្រឹមតែជាកម្មវត្ថុ ឬទ្រព្យសម្បត្តិរបស់កូនបំណុល (ការអនុវត្តបែបសម្ភារៈ) ហើយបានហាមដាច់ខាតនូវការអនុវត្តបែបបុគ្គលភាព។

### ១.៥.២. ការអនុវត្តដើម និងការអនុវត្តសងជំនួស

ការបែងចែកបែបនេះ គឺផ្អែកទៅលើទម្រង់នៃការអនុវត្តកាតព្វកិច្ច តាមរយៈការអនុវត្ត។ ការអនុវត្តដើមមានន័យថាជាវិធីសម្រេចនូវខ្លឹមសារដើម នៃកាតព្វកិច្ចផ្តល់តាវកាលិក (ការប្រគល់វត្ថុកាតព្វកិច្ចធ្វើសកម្មភាព កាតព្វកិច្ចមិនធ្វើសកម្មភាព) ចំពោះសិទ្ធិទាមទារគ្រប់ប្រភេទ។ ចំពោះការអនុវត្តសងជំនួសវិញ មានន័យថា ក្នុងករណីដែលកូនបំណុលមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយស្ម័គ្រចិត្តទេ នោះតាវកាលិកទាំងអស់នឹងត្រូវប្តូរទៅជាការបង់ជាទឹកប្រាក់វិញ។ នៅក្នុងការសម្រេចសិទ្ធិទាមទារ មិនមែនមានករណីតិចតួចទេ ដែលទោះជាកូន

បំណុល មិនផ្តល់តាវកាលិកក៏ដោយ ប្រសិនបើម្ចាស់សិទ្ធិបានទទួលលទ្ធផលដូចគ្នានឹងការផ្តល់តាវកាលិកនោះ ក៏ជាការគ្រប់គ្រាន់ហើយ។ លើសពីនេះទៀត នៅក្នុងករណីជាច្រើននៃការអនុវត្តតាមវិធីសងជាប្រាក់ ម្ចាស់សិទ្ធិ មិនមានការពេញចិត្តទាំងស្រុងនោះទេ។ ហេតុនេះ ការអនុវត្តដើមគួរតែចាត់ទុកថាជាគោលការណ៍។ ក្រមនីតិវិធី រដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានចាត់ទុកការអនុវត្តដើមជាគោលការណ៍ដែរ។[33] គួរកត់សម្គាល់ថា ដោយឈរលើទស្សនវិស័យនៃច្បាប់សារធាតុ បណ្តឹងទាមទារឱ្យសងជាការខូចខាតជំនួសឱ្យការផ្តល់តាវកាលិក ដើម ដោយសារតែតាវកាលិកនោះ បានក្លាយជាតាវកាលិកដែលមិនអាចអនុវត្តបាន ក៏អាចនឹងកើតមានឡើង បានដែរ។ ប៉ុន្តែ នោះគឺជាបញ្ហាផ្សេងពីការអនុវត្តសងជំនួស ដែលជាទម្រង់មួយនៃការអនុវត្ត នៅក្នុងការពិភាក្សា ទីនេះ។

## ១.៥.៣. ការអនុវត្តដោយផ្ទាល់ វិធានបង្ខំដោយប្រយោល និងការអនុវត្តជំនួស

នេះគឺជាការបែកចែកប្រភេទនៃការអនុវត្តដោយបង្ខំ ដោយឈរលើទស្សនវិស័យនៃវិធីដែលយកទៅប្រើ ប្រាស់សម្រាប់ការអនុវត្ត។ **ការអនុវត្តដោយផ្ទាល់** គឺជាវិធីសម្រេចគោលបំណងនៃតាវកាលិកដោយផ្ទាល់ ដោយ ស្ថាប័នអនុវត្តដែលជាវិធីសមស្របសម្រាប់ការអនុវត្តកាតព្វកិច្ចដូចជា **ការសងប្រាក់** និង**ការប្រគល់វត្ថុ**។ ដោយសារថា វិធីនៃការអនុវត្តបែបនេះ មិនទាមទារជាចាំបាច់នូវការសហការរបស់កូនបំណុលទេនោះ គេមិន ចាំបាច់ដាក់ការគៀបសង្កត់ទៅលើរូបកាយ ក៏ដូចជាឆន្ទៈសេរីរបស់កូនបំណុលឡើយ។ ការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារដែលមានគោលបំណងសងជាប្រាក់ ដូចមានចែងនៅគន្ថី៦ ជំពូកទី២ នៃក្រមនីតិវិធីរដ្ឋ ប្បវេណី២០០៦ និងការអនុវត្តដោយបង្ខំ ឱ្យប្រគល់ចលនវត្ថុ អចលនវត្ថុ ជាអាទិ៍ ដែលមានចែងនៅមាត្រា ៥២៤, ដល់ ៥២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី២០០៦ ជាប្រភេទមួយក្នុងចំណោមការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិទាមទារ ដែលគ្មានគោលបំណងឱ្យសងជាប្រាក់ គឺសុទ្ធតែត្រូវធ្វើឡើងតាមរយៈការអនុវត្តដោយផ្ទាល់នេះ។ ការអនុវត្ត សិទ្ធិប្រាតិភោគ ក៏ជាប្រភេទមួយនៃការអនុវត្តដោយផ្ទាល់ ដែលធ្វើឡើងដើម្បីសម្រេចសិទ្ធិទាមទារប្រាក់ ដែលត្រូវ បានធានាដែរ។

**ការអនុវត្តជំនួស** គឺជាវិធីដែលអនុញ្ញាតឱ្យម្ចាស់បំណុល ឬតតិយជន សម្រេចនូវខ្លឹមសារនៃតាវកាលិក ជំនួសកូនបំណុល ហើយប្រមូលសោហ៊ុយនោះ ជាប្រាក់ពីកូនបំណុលវិញ។[34] វិធីនេះស័ក្តសមសម្រាប់ការអនុវត្ត កាតព្វកិច្ច ដែលមិនសមស្របនឹងឱ្យស្ថាប័នអនុវត្តធ្វើការអនុវត្តដោយផ្ទាល់បាន ប៉ុន្តែកាតព្វកិច្ចនោះមានលក្ខ ណៈមួយដែលថា បើទោះជាកូនបំណុលមិនសម្រេចនូវខ្លឹមសារនៃតាវកាលិកនោះដោយខ្លួនឯងក៏ដោយ ក៏ការ សម្រេចឱ្យបាននូវលទ្ធផលដូចគ្នានោះ ជាការគ្រប់គ្រាន់ដែរសម្រាប់ម្ចាស់បំណុល។ កាតព្វកិច្ចបែបនេះ មានដូច ជាកាតព្វកិច្ចដែលមានគោលបំណងឱ្យធ្វើសកម្មភាពណាមួយដែលអាចជំនួសបានជាអាទិ៍។

[33] មាត្រា៥២៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[34] មាត្រា៥២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

**វិធានបង្ខំដោយប្រយោល** គឺជាវិធីមួយដែលដាក់ការគាបសង្កត់ផ្នែកផ្លូវចិត្ត ទៅលើកូនបំណុល ដើម្បីបង្ខំឱ្យកូនបំណុលនោះ អនុវត្តកាតព្វកិច្ចរបស់ខ្លួន។[35] វិធានការណ៍នៃការគាបសង្កត់នោះមានដូចជា ការបង្គាប់ឱ្យបង់ប្រាក់ជាសំណងសងការខូចខាត ការដាក់ទោសដោយអាជ្ញាធររដ្ឋ ការដាក់ទណ្ឌកម្ម ឬការដាក់ពន្ធនាគារជាដើម។ ដោយសារថា ការបង្ខិតបង្ខំទៅលើរូបរាងកាយ និងឆន្ទៈសេរីរបស់កូនបំណុល មានលក្ខណៈខ្លាំងក្លាជាងការអនុវត្តដោយផ្ទាល់នោះ វិធីនេះ ត្រូវបានយកមកទៅប្រើប្រាស់សម្រាប់ការអនុវត្តកាតព្វកិច្ចដែលមានលក្ខណៈមួយថា មានតែកូនបំណុលតែប៉ុណ្ណោះ ដែលអាចធ្វើសកម្មភាពសម្រេចនូវកម្មវត្ថុនៃតាវកាលិកបាន។ កាតព្វកិច្ចបែបនេះ មានដូចជាកាតព្វកិច្ចដែលមានគោលបំណងឱ្យធ្វើ ឬមិនឱ្យធ្វើសកម្មភាពអ្វីមួយដែលមិនអាចជំនួសបានជាអាទិ៍។ ប៉ុន្តែ ដោយសារថា កាតព្វកិច្ចធ្វើសកម្មភាពដែលអាចជំនួសបាន ក៏អាចអនុវត្តតាមរយៈវិធានបង្ខំដោយប្រយោលដែរនោះ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏ទទួលស្គាល់ការអនុវត្តតាមវិធានបង្ខំប្រយោល ថាជាវិធីអនុវត្តចំពោះកាតព្វកិច្ចធ្វើសកម្មភាពដែលអាចជំនួសបានផងដែរ។

### ១.១.៤. ការអនុវត្តជាចម្បង និងការអនុវត្តជាបណ្តោះអាសន្ន

**ការអនុវត្តជាបណ្តោះអាសន្ន** គឺជាការអនុវត្តមួយបែបដែលធ្វើឡើងដើម្បីរក្សាស្ថានភាពបច្ចុប្បន្នឱ្យនៅដដែល ក្នុងគោលបំណងបង្ការមិនឱ្យមានឧបសគ្គណាមួយលើកឡើងចំពោះការអនុវត្តនៅមុនពេលធ្វើការអនុវត្តដើម្បីសម្រេចសិទ្ធិទាមទារ ជាអាទិ៍ ដែលជាការអនុវត្តជាចម្បង។ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មានចែងអំពីការអនុវត្តរឹបអូសជាបណ្តោះអាសន្ន និងការអនុវត្តចាត់ចែងជាបណ្តោះអាសន្នដែលមានចែងនៅមាត្រា៥៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី២០០៦ តទៅ (ដែលជាប្រភេទនៃការអនុវត្តជាបណ្តោះអាសន្ន។ ដើម្បីធ្វើការអនុវត្តបែបនេះបាន ចាំបាច់ត្រូវតែបានទទួលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន[36] ឬដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន[37]សិន ដែលទាំងនេះ គឺជា**លិខិតអនុវត្តពិសេស**។ នីតិវិធីតុលាការ សម្រាប់ការចេញសេចក្តីបង្គាប់ទាំងនេះ (រឿងក្តី រក្សាការពារ) និងសម្រាប់ការអនុវត្តបន្តពីនោះ ហៅជារួមថា **ការចាត់ចែងរក្សាការពារ** (គន្លឹទី៧)។

### ១.៥.៥. ការអនុវត្តដោយឡែក និងការអនុវត្តជាទូទៅ

**ការអនុវត្តដោយឡែក** គឺជាការអនុវត្តដែលធ្វើឡើងចំពោះទ្រព្យសម្បត្តិដោយឡែកណាមួយរបស់កូនបំណុល ដើម្បីសម្រេចនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគជាក់លាក់ណាមួយ។ ចំណែក**ការអនុវត្តជាទូទៅ** សំដៅទៅលើការអនុវត្តដែលធ្វើឡើងជារួម ចំពោះទ្រព្យសម្បត្តិទាំងអស់របស់កូនបំណុល ដើម្បីសម្រេចនូវសិទ្ធិនៃម្ចាស់បំណុលទាំងអស់របស់កូនបំណុល។ នៅក្នុងច្បាប់សម័យដើម ការអនុវត្តជាទូទៅ ត្រូវបានធ្វើឡើងលើសពីភាពចាំបាច់ ដោយសារគេគិតថា ចរិតលក្ខណៈប្រកបដោយសីលធម៌ និងឋានៈគតិយុត្តទាំងមូល ដែលមានលក្ខណៈ

[35] មាត្រា៥២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[36] មាត្រា៥៤៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[37] មាត្រា៥៤៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ឯកភាព បម្រើឱ្យគោលបំណងនៃការអនុវត្ត។ ប៉ុន្តែ នៅក្នុងច្បាប់ទំនើបវិញ ការអនុវត្តជាទូទៅ ត្រូវបានធ្វើឡើងជាលក្ខណៈនៃនីតិវិធីក្ស័យធន នៅក្នុងករណីដែលទ្រព្យសម្បត្តិរបស់កូនបំណុល មិនគ្រប់គ្រាន់នឹងសងទៅម្ចាស់បំណុលទាំងអស់ តែប៉ុណ្ណោះ។ ការអនុវត្តដោយបង្ខំ ដែលមានចែងនៅក្នុងគន្ថីទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា សុទ្ធសឹងតែជាការអនុវត្តដោយឡែកទាំងអស់។

## ១.៦. លក្ខខណ្ឌទម្រង់នៃពាក្យសុំអនុវត្តដោយបង្ខំ

របៀបដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។ នៅក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវមានបញ្ជាក់នូវចំណុចដូចខាងក្រោមនេះ ហើយត្រូវភ្ជាប់ជាមួយនឹងលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត[38]៖

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់
- សញ្ញាណនៃលិខិតអនុវត្ត
- សេចក្តីសុំឱ្យអនុវត្ត តាមការបង្ខំដោយផ្ទាល់ ឬការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល
- សញ្ញាណនៃទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំ ដែលម្ចាស់បំណុលនៃការអនុវត្តសុំក្នុងករណី ដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់
- ខ្លឹមសារនៃសេចក្តីសម្រេច ដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំ តាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។

នៅក្នុងករណី ដែលម្ចាស់បំណុលនៃការអនុវត្តសុំឱ្យអនុវត្តដោយបង្ខំ ចំពោះផ្នែកណាមួយនៃសិទ្ធិទាមទារ ដែលបានសរសេរនៅក្នុងលិខិតអនុវត្តដែលបង្គាប់ឱ្យ សងជាប្រាក់ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរបញ្ជាក់អំពីសេចក្តីសុំ និងទំហំនៃសេចក្តីសុំនោះ ក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ។

## ១.៧. ស្ថាប័នអនុវត្តដោយបង្ខំ និងដែនសមត្ថកិច្ច និងការសម្រេចសេចក្តីរបស់តុលាការ

សមត្ថភាព និងអំណាចធ្វើការអនុវត្តដោយបង្ខំ ធ្លាក់ទៅលើស្ថាប័នជាតិ។ ស្ថាប័នដែលទទួលបន្ទុកកាន់អំណាចធ្វើការអនុវត្តដោយបង្ខំ ដែលជាអំណាចរដ្ឋ ហៅថា **ស្ថាប័នអនុវត្ត។**[39] ដោយសារថា នីតិវិធីនៃការអនុវត្តដោយបង្ខំ គឺជានីតិវិធីដាច់ដោយឡែក និងឯករាជ្យពីនីតិវិធីបណ្តឹង ដូច្នេះវាមិនចាំបាច់ដែលតុលាការដែលទទួលពាក្យបណ្តឹង ត្រូវតែជាស្ថាប័នអនុវត្តទេ។ ផ្ទុយទៅវិញ ដោយគិតអំពីតម្រូវការនៃភាពងាយស្រួល និងភាព

[38] មាត្រា៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[39] មាត្រា៣៣៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ឆាប់រហ័ស ការដាក់ការទទួលបន្ទុកទៅឱ្យស្ថាប័នមួយផ្សេងទៀតគឺជាការសមស្រប។ ហេតុដូចនេះហើយបានជាច្បាប់ចែងឱ្យតុលាការអនុវត្ត និងអាជ្ញាសាលា ធ្វើជាស្ថាប័នអនុវត្ត។[40]

តុលាការអនុវត្ត និងអាជ្ញាសាលា គឺជាស្ថាប័នឯករាជ្យនៃអំណាចតុលាការ។ ស្ថាប័នទាំងពីរនេះ មានចរិតលក្ខណៈផ្សេងពីគ្នា ហេតុនេះហើយបានជាច្បាប់ដាក់បន្ទុកការងារផ្សេងគ្នាទៅឱ្យស្ថាប័ននីមួយៗ ដោយអាស្រ័យទៅតាមកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងទៅតាមប្រភេទបែបបទនៃការអនុវត្តជាអាទិ៍។ **ឧទាហរណ៍** ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ដែលតម្រូវឱ្យមានសកម្មភាពជាក់ស្តែងដោយប្រើកម្លាំង ត្រូវបានដាក់បន្ទុកទៅឱ្យអាជ្ញាសាលា។ ចំណែក ការអនុត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលជាទង្វើបញ្ញាមានលក្ខណៈអរូបី និងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ដែលត្រូវធ្វើឡើងតាមនីតិវិធីដ៏មធ្យ័ត ត្រូវបានទម្លាក់ជាបន្ទុកទៅឱ្យតុលាការអនុវត្ត។

## ១.៧.១ តុលាការអនុវត្ត

តុលាការដែលមានភារកិច្ចធ្វើការអនុវត្តដោយបង្ខំ ឬដែលធ្វើការបាក់ព័ន្ធនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ (តុលាការតាមនិយមន័យចង្អៀត) ហៅថា តុលាការអនុវត្ត។ យោងតាមមាត្រា៣៣៦ កថាខណ្ឌទី៣ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ បានចែងថា **សាលាដំបូងដែលត្រូវអនុវត្តដោយបង្ខំតាមបញ្ញត្តិនៃគន្ថីនេះ គឺជាតុលាការអនុវត្ត**។ យោងតាមបញ្ញត្តិនេះ ស្ថាប័នសម្រេចសេចក្តីដែលមានចៅក្រមនៃសាលាដំបូងដែលជាអង្គភាពរដ្ឋ គឺជា តុលាការអនុវត្ត។

ក្នុងករណីដែលតុលាការអនុវត្តដើរតួរនាទី ដើរតួជាស្ថាប័នអនុវត្តដោយផ្ទាល់ ប្រភេទនៃនីតិវិធីនៃការអនុវត្ត ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការនេះរួមមាន៖

- ការអនុវត្តដោយបង្ខំ និងការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត[41]
- ការអនុវត្តដោយបង្ខំ និងការអនុវត្តសិទ្ធិលើប្រាតិភោគ ចំពោះអចលនវត្ថុ[42]
- ការអនុវត្តដោយបង្ខំ និងការអនុវត្តសិទ្ធិលើប្រាតិភោគចំពោះនាវា[43]
- ការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុ ក្នុងករណីវត្ថុដែលជាកម្មវត្ថុត្រូវបានកាន់កាប់ដោយតតិយជន[44]
- ការអនុវត្តដោយបង្ខំចំពោះកាតព្វកិច្ចដែលមានគោលបំណងឱ្យធ្វើ ឬមិនធ្វើសកម្មភាពណាមួយ[45]

[40] មាត្រា៣៣៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[41] មាត្រា៤០២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[42] មាត្រា៤១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[43] មាត្រា៤៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[44] មាត្រា៤២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[45] មាត្រា៥២៧ និងមាត្រា៥២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

សូមកត់សម្គាល់ថា សមត្ថកិច្ចតាមដែនដីនៅក្នុងករណីនីមួយៗ ក៏មិនត្រូវបានកំណត់នៅក្នុងបទប្បញ្ញត្តិទាំងនេះដែរ។[46]

នៅពេលដើរតួនាទីជាស្ថាប័នសម្រាប់ផ្តល់កិច្ចសហការ និងមើលខុសត្រូវលើនីតិវិធីនៃការអនុវត្ត ដែលស្ថិតនៅក្រោមបន្ទុករបស់អាជ្ញាសាលា តុលាការអនុវត្តមានសិទ្ធិអំណាច នៅក្នុងការអនុញ្ញាតឱ្យអនុវត្តនៅថ្ងៃសម្រាក ឬពេលយប់[47] និងការប្តូរទំហំនៃចលនវត្ថុដែលហាមឃាត់មិនឱ្យរឹមអូស[48] ជាអាទិ៍។

ចំពោះហេតុដែលកើតឡើងនៅក្នុងអំឡុងពេលនៃការអនុវត្ត តុលាការអនុវត្តក៏មានសមត្ថកិច្ចលើការសម្រេចក្តីអំពីការតវ៉ាចំពោះការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្ត[49] ជាអាទិ៍ដែរ។ សូមកត់សម្គាល់ថា ការសម្រេចសេចក្តីអំពីការតវ៉ាចំពោះការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា ស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូង ដែលអាជ្ញាសាលានោះស្ថិតនៅ។ នៅក្នុងករណីនេះ ដោយសារថា សាលាដំបូងនោះមិនដើរតួនាទីជាស្ថាប័នអនុវត្ត គេមិនហៅតុលាការនោះថា ជាតុលាការអនុវត្តទេ។[50] សមត្ថកិច្ចរបស់តុលាការអនុវត្ត គឺជាសមត្ថកិច្ចផ្តាច់មុខ។[51]

## ក. វិធានទូទៅសម្រាប់នីតិវិធីនៃការអនុវត្តដោយតុលាការអនុវត្ត

**ទម្រង់នៃសេចក្តីសម្រេច៖** ជាទូទៅ ការចាត់ចែងការអនុវត្តដោយតុលាការអនុវត្ត ធ្វើឡើងក្រោមទម្រង់ជាការសម្រេចសេចក្តី (**សកម្មភាពធ្វើសេចក្តីសម្រេចសេចក្តី**) ហើយទម្រង់នៃសេចក្តីសម្រេចនេះ គឺជា**ដីកាសម្រេច**[52]។ បើយល់ឃើញថាចាំបាច់ នៅពេលចាត់ចែងធ្វើការអនុវត្ត តុលាការអនុវត្តអាចសួរជនដែលទាក់ទងនឹងផលប្រយោជន៍ ឬជនផ្សេងទៀតដែលពាក់ព័ន្ធបាន។[53] វិធានការនៃការអនុវត្តដែលបានកំណត់នៅក្នុងមាត្រា ៣៣៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ បានឆ្លុះបញ្ចាំងនូវទស្សនទានដ៏ទូលំទូលាយ ដែលមិនត្រឹមតែរួមបញ្ចូលនូវសកម្មភាពរបស់តុលាការអនុវត្តដែលបានធ្វើឡើងនៅក្នុងនីតិវិធីនៃការអនុវត្ត ដូចជា ការរឹបអូស ការប្តូរជាប្រាក់ ការចែកចំណែក ជាអាទិ៍ ប៉ុណ្ណោះទេ គឺថែមទាំងរួមបញ្ចូលនូវការចេញដីកាសម្រេចលើកចោលពាក្យសុំឱ្យអនុវត្ត និងសកម្មភាពជាក់ស្តែងផ្សេងទៀត ដែលមិនមែនជាសេចក្តីសម្រេចសេចក្តីផងដែរ។ ជាគោលការណ៍ ក្នុងករណីដែលតុលាការអនុវត្តធ្វើការចាត់ចែងការអនុវត្តក្រោមទម្រង់ជាការសេចដីកាសម្រេច

[46] មាត្រា៣៣៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[47] មាត្រា៣៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[48] មាត្រា៣៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[49] មាត្រា៣៤៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[50] មាត្រា៣៣៦ កថាខណ្ឌទី៤ និងមាត្រា៣៤៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[51] មាត្រា៣៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[52] មាត្រា៣៣៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[53] មាត្រា៣៣៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

តុលាការនោះមានឆន្ទានុសិទ្ធិ នៅក្នុងការកំណត់ថា ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬមិនត្រូវធ្វើ[54]។ ប្រសិនបើ តុលាការមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការអាចសួរភាគីបាន។[55] នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ វិសាលភាពនៃអ្នកដែលតុលាការអាចសួរបាន ត្រូវបានពង្រីក គឺថា**តុលាការអាចសួរជនដែលទាក់ទងនឹងផលប្រយោជន៍ថែមទៀត** បន្ថែមពីលើការសួរភាគី។ ជាងនេះទៅទៀត នៅពេលតុលាការអនុវត្តធ្វើការចាត់ចែងការអនុវត្ត ក្រៅពីការចាត់ចែងទម្រង់ជាការចេញដីកាសម្រេច (ឧទាហរណ៍ ដូចជាការរៀបចំឯកសារកំហិតអំពីវត្ថុដូចមានចែងនៅក្នុងមាត្រា៤៣៤ជាដើម) តុលាការអាចសួរជនទាំងនេះបានប្រសិនបើចាំបាច់។

**ខ. វិធីឧបាស្រ័យ**

វិធីឧបាស្រ័យចំពោះសេចក្ដីសម្រេចសេចក្ដីសម្រេចរបស់តុលាការអនុវត្ត រួមមានបណ្ដឹងជំទាស់ និងការតវ៉ាចំពោះការអនុវត្ត (**កថាភាគទី៤**)។

### ១.៧.២ អាជ្ញាសាលា

**អាជ្ញាសាលា** គឺជាស្ថាប័នយុត្តាធិការឯករាជ្យមួយ ដែលទទួលបន្ទុកធ្វើការបញ្ជូនឯកសារនានាដែលចេញដោយតុលាការ[56] និងធ្វើការអនុវត្តដោយបង្ខំមួយចំនួនដែលច្បាប់បានកំណត់។ ស្ថាប័នយុត្តាធិការនេះ **ស្ថិតនៅក្រោមក្រសួងយុត្តិធម៌ និងមានសមាសភាពជាមន្ត្រីរាជការ** ដែលមានឈ្មោះថាជា **អាជ្ញាសាលាដែលបំពេញការងារ នៅសាលាដំបូងដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បង្គាប់ឱ្យធ្វើការ។**[57]

**អាជ្ញាសាលា** ជាមន្ត្រីរាជការដែលត្រូវតែងតាំងដោយ **ប្រកាសរបស់ក្រសួងយុត្តិធម៌** ចេញពីក្នុងចំណោមបុគ្គលដែលបានបំពេញគ្រប់ល័ក្ខខណ្ឌទាមទារមួយចំនួន។[58] ក៏ប៉ុន្តែ ខុសពីមន្ត្រីរាជការទូទៅ អាជ្ញាសាលាមិនទទួលប្រាក់ខែពីរដ្ឋទេ **គឺទទួលចំណូលជាប្រាក់កម្រៃពីអ្នកដាក់ពាក្យសុំ ចំពោះការអនុវត្តមុខងាររបស់ខ្លួនវិញ** ដែលនេះគឺជា**ចរិតលក្ខណៈពិសេសមួយរបស់អាជ្ញាសាលា។**[59]

**ក. តួនាទីរបស់អាជ្ញាសាលា**

អាជ្ញាសាលា ត្រូវបំពេញមុខនាទីរបស់ខ្លួន នៅតំបន់សមត្ថកិច្ចរបស់សាលាដំបូងដែលខ្លួនបានបំពេញការងារ។[60] ការកម្រិតទៅលើតំបន់នៃការបំពេញមុខនាទីនេះ មានឥទ្ធិពលដោយប្រយោលទៅលើការកំណត់

---

[54] មាត្រា៣៣៥ និងមាត្រា១១៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[55] មាត្រា៣៣៥ និងមាត្រា១១៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[56] មាត្រា២៤៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[57] មាត្រា២ នៃសេចក្ដីព្រាងច្បាប់ស្ដីពីអាជ្ញាសាលា

[58] មាត្រា៤ នៃសេចក្ដីព្រាងច្បាប់ស្ដីពីអាជ្ញាសាលា

[59] មាត្រា៣ នៃសេចក្ដីព្រាងច្បាប់ស្ដីពីអាជ្ញាសាលា

[60] មាត្រា៧ នៃសេចក្ដីព្រាងច្បាប់ស្ដីពីអាជ្ញាសាលា

ដែលសមត្ថកិច្ចរបស់អាជ្ញាសាលា។ នីតិវិធីនៃការអនុវត្តដោយបង្ខំ ដែលអាជ្ញាសាលាជាអ្នកទទួលបន្ទុកដោយឯករាជ្យ ក្នុងនាមស្ថាប័នអនុវត្ត រួមមាន៖

- ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ[61]
- ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ[62]
- ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ[63]
- ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ[64]

នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ ដែលតុលាការជាអ្នកទទួលបន្ទុលក្នុងនាមជាស្ថាប័នអនុវត្ត អាជ្ញាសាលាមានសិទ្ធិអំណាចបន្ទាប់បន្សំលើចំណុចដូចតទៅ៖

- ការថែរក្សាគ្រប់គ្រងអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ[65]
- ការអនុវត្តការលក់[66]
- ការដកហូតលិខិតបញ្ជាក់សញ្ញាតិនាវា ជាអាទិ៍ នៅក្នុងការអនុវត្តដោយបង្ខំចំពោះនាវា[67]ជាដើម។

លើសពីនេះទៅទៀត នៅក្នុងនីតិវិធីនៃការអនុវត្តការអនុវត្តរក្សាការពារ អាជ្ញាសាលា មានសិទ្ធិអំណាចនៅក្នុងថែរក្សាគ្រប់គ្រងអចលនវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ថែមទៀត។[68]

[61] ចាប់ពីមាត្រា៣៨៤ តទៅ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
[62] ចាប់ពីមាត្រា៥០០ តទៅ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
[63] មាត្រា៥២៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
[64] មាត្រា៥២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
[65] មាត្រា៥២៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
[66] មាត្រា៤៣៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
[67] មាត្រា៤៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
[68] មាត្រា៥៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

## ខ. ឋានៈរបស់អាជ្ញាសាលា នៅក្នុងការអនុវត្តដោយបង្ខំ

### ខ.១. ទំនាក់ទំនងជាមួយនឹងម្ចាស់បំណុល

អាជ្ញាសាលា ត្រូវធ្វើសកម្មភាពនៃការអនុវត្តដោយបង្ខំ ដោយផ្អែកលើពាក្យសុំត្រឹមត្រូវតាមច្បាប់ របស់ម្ចាស់បំណុល និងដោយអនុវលោមទៅតាមនីតិវិធីដែលបានកំណត់ដោយច្បាប់។ ទំនាក់ទំនងនេះ គឺជាទំនាក់ទំនងរវាងបុគ្គលឯកជន និងអាជ្ញាធររដ្ឋ នៅក្រោមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ មិនមែនជាទំនាក់ទំនងនៃអាណត្តិនៅក្រោមច្បាប់ឯកជនទេ។ យើងអាចនិយាយម្យ៉ាងទៀតបានថា **អាជ្ញាសាលា គឺជាស្ថាប័នយុត្តាធិការឯករាជ្យ** ហើយបើទោះបីជាប្រព័ន្ធនៃការបង់ប្រាក់កម្រៃ ត្រូវបានអនុវត្តដូចបានរៀបរាប់ខាងលើក៏ដោយ ក៏អាជ្ញាសាលាពុំមែនជាអ្នកតំណាងរបស់ម្ចាស់បំណុលឡើយ។ **អាជ្ញាសាលា ត្រូវធ្វើការអនុវត្តដោយបង្ខំនៅក្នុងឆន្ទានុសិទ្ធិ និងការទទួលខុសត្រូវរបស់ខ្លួន។** ទោះបីជា អាជ្ញាសាលាធ្វើតាមការណែនាំរបស់ម្ចាស់បំណុលក៏ដោយ ប្រសិនបើសកម្មភាពនៃការអនុវត្តដោយបង្ខមនោះខុសច្បាប់ នោះអាជ្ញាសាលាមិនអាចគេចផុតពីការទទួលខុសត្រូវចំពោះសកម្មភាពនោះបានទេ។ អាជ្ញាសាលាអាចគោរពតាមឆន្ទៈរបស់ម្ចាស់បំណុលបាន ចំពោះទំហំ និងកម្រិតនៃការអនុវត្តដោយបង្ខំ ប៉ុន្តែប្រសិនបើការណែនាំ ឬសំណូមពរនោះខុសច្បាប់ អាជ្ញាសាលា មិនត្រូវធ្វើតាមឡើយ។ ដោយសារថាសកម្មភាពរបស់អាជ្ញាសាលា គឺជា**ការប្រើអំណាចអនុវត្តរបស់រដ្ឋ** នោះមន្ត្រីដែលទទួលបន្ទុកការអនុវត្ត ពុំមែនជានិយោជិករបស់ម្ចាស់បំណុល ឡើយ។ ហេតុនេះ ប្រសិនបើអាជ្ញាសាលាបង្កឱ្យមានការខូចខាតដល់កូនបំណុល ឬតតិយជន ដោយសារការធ្វើសកម្មភាពអនុវត្តដោយបង្ខំណាមួយ នោះម្ចាស់បំណុលមិនទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ក្នុងនាមជានិយោជកឡើយ។ ប៉ុន្តែប្រសិនបើម្ចាស់បំណុលឱ្យអាជ្ញាសាលាធ្វើការអនុវត្តដោយបង្ខំមិនត្រឹមត្រូវ ដោយចេតនា ឬដោយការធ្វេសប្រហែស ហើយបង្កឱ្យមានព្យសនកម្មដល់អ្នកដទៃ នោះម្ចាស់បំណុលអាចនឹងមានការទទួលខុសត្រូវ ចំពោះអំពើអនីត្យានុកូលដោយផ្ទាល់ខ្លួន។ **ឧទាហរណ៍៖** ដូចជាករណីដែលម្ចាស់បំណុលកុហកថា អចលនវត្ថុណាមួយជាកម្មសិទ្ធិរបស់កូនបំណុល ហើយឱ្យអាជ្ញាសាលារឹបអូសអចលនវត្ថុនោះ ទាំងដែលខ្លួនដឹងថាវាជាកម្មសិទ្ធិរបស់តតិយជនសោះ។

### ខ.២. ទំនាក់ទំនងជាមួយនឹងកូនបំណុល និងតតិយជន

អាជ្ញាសាលា មានសិទ្ធិប្រើប្រាស់អំណាចបង្ខំ ទៅលើកូនបំណុល និងតតិយជន នៅក្នុងទំហំដែលចាំបាច់ ដើម្បីធ្វើការអនុវត្តដោយបង្ខំ ហើយត្រូវទទួលខុសត្រូវក្នុងការធ្វើសកម្មភាពនេះដោយស្របច្បាប់។

### ខ.៣. ទំនាក់ទំនងជាមួយនឹងតុលាការអនុវត្ត

តុលាការអនុវត្ត និងអាជ្ញាសាលា សុទ្ធតែជាស្ថាប័នឯករាជ្យរបស់រដ្ឋរៀងៗខ្លួន ហើយអាជ្ញាសាលាពុំមែនជាស្ថាប័នជំនួយបន្ថែមរបស់តុលាការអនុវត្តទេ។ ច្បាប់អនុញ្ញាតឱ្យតុលាការអនុវត្តផ្តល់ការណែនាំ ប្រគល់សិទ្ធិ និងបង្គាប់អាជ្ញាសាលា នៅក្នុងករណីជាក់លាក់មួយចំនួន ប៉ុន្តែបទប្បញ្ញត្តិទាំងនេះ ត្រូវបានរៀបចំឡើង ដោយ

យកទំនាក់ទំនងឯករាជ្យរវាងស្ថាប័នទាំងពីរមកជាមូលដ្ឋាន និងដោយគិតពិចារណាទៅលើចរិតលក្ខណៈរបស់ស្ថាប័ននីមួយៗផងដែរ។ ដោយឡែក ចំពោះរដ្ឋបាលយុត្តាធិការវិញ អាជ្ញាសាលាត្រូវទទួលការត្រួតពិនិត្យ ពីសាលាដំបូងដែលខ្លួនស្ថិតនៅ ចំពោះមុខងាររបស់ខ្លួន។[69] ក៏ប៉ុន្តែ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដែលជាអ្នកតែងតាំង មានសិទ្ធិអំណាចដាក់ទណ្ឌកម្មខាងផ្នែកវិន័យ ចំពោះការបំពានមុខងារជាអាទិ៍របស់អាជ្ញាសាលា។

**ខ.៤. ការដកហូត**

នៅក្នុងករណីដែលអាជ្ញាសាលាមានទំនាក់ទំនងញាតិ ឬមានផលប្រយោជន៍ទាក់ទងជាក់លាក់ផ្សេងទៀត ជាមួយនឹងភាគី អាជ្ញាសាលានោះ ត្រូវដកហូតចេញពីការអនុវត្តមុខងាររបស់ខ្លួន ដើម្បីជៀសវាងភាពបន្ទិលសង្ស័យអំពីភាពត្រឹមត្រូវ នៅក្នុងការបំពេញមុខងារនោះ។[70]

**គ. វិធានទូទៅសម្រាប់នីតិវិធីនៃការអនុវត្តដោយបង្ខំដោយអាជ្ញាសាលា**

**គ.១. ការយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណ**

អាជ្ញាសាលា ត្រូវយកតាមខ្លួននូវលិខិតដែលបញ្ជាក់អត្តសញ្ញាណ ឬលក្ខណសម្បត្តិរបស់ខ្លួន ហើយត្រូវបង្ហាញលិខិតនេះ ចំពោះជនដែលទាក់ទងនឹងផលប្រយោជន៍ បើជននោះទាមទារ។[71]

**គ.២. ការអនុវត្តសិទ្ធិនៃការឆែរ**

អាជ្ញាសាលា អាចចូលទៅក្នុងទីកន្លែងរស់នៅរបស់កូនបំណុលនៃការអនុវត្ត ឬកន្លែងផ្សេងទៀតដែលកូនបំណុលនៃការអនុវត្តនោះកាន់កាប់។ នៅក្នុងករណីនេះ ប្រសិនបើមានភាពចាំបាច់ អាជ្ញាសាលាអាចឱ្យកូនបំណុលនៃការអនុវត្ត បើកទ្វារដែលចាក់សោរទូរដែក និងប្រអប់ផ្សេងទៀតបាន ហើយប្រសិនបើកូនបំណុលនៃការអនុវត្ត បដិសេធមិនព្រមធ្វើតាមទេ អាជ្ញាសាលាអាចចាត់វិធានការណ៍ចាំបាច់ ដើម្បីបើករបស់ទាំងនោះដោយប្រើកម្លាំង។[72]

[69] មាត្រា៦ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា

[70] មាត្រា១៣ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា

[71] មាត្រា៣៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[72] មាត្រា៣៨៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

### គ.៣. ការបំបាត់នូវការប្រឆាំង

ប្រសិនបើអាជ្ញាសាលា ជួបប្រទះនឹងការប្រឆាំងនៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលានោះអាចប្រើកម្លាំង ឬអាចសុំជំនួយពីនគរបាល ឬស្ថាប័នរដ្ឋផ្សេងទៀតដែលទទួលខុសត្រូវក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ ដើម្បីបំបាត់នូវការប្រឆាំងនោះបាន។[73]

### គ.៤. អ្នកសង្កេតការណ៍

នៅពេលចូលទៅទីកន្លែងរស់នៅរបស់ជនណាម្នាក់ ដើម្បីបំពេញមុខនាទីរបស់ខ្លួន បើមិនបានជួបនឹងម្ចាស់នៃទីកន្លែងរស់នៅ ឬអ្នកតំណាងរបស់អ្នកនោះ ឬញាតិនៅជាមួយ ឬអ្នកបម្រើ ឬអ្នកផ្សេងដែលធ្វើការនៅទីនោះដែលមានការយល់ដឹងសមរម្យទេ អាជ្ញាសាលា ត្រូវហៅរកអ្នកសង្កេតការណ៍ដែលអាចជាមន្ត្រីឃុំ-សង្កាត់ មន្ត្រីនគរបាល ឬអ្នកដទៃទៀតដែលយល់ឃើញថាសមរម្យអាចធ្វើជាអ្នកសង្កេតការណ៍បាន។ ក្នុងករណីដែលអាជ្ញាសាលាធ្វើការអនុវត្តដោយបង្ខំ ដោយប្រើកម្លាំង ឬដោយមានជំនួយពីនគរបាល ជាអាទិ៍ តាមបញ្ញត្តិមាត្រា ៣៣៨ កថាខណ្ឌទី១ នោះបើទោះបីជាមិនចូលទៅក្នុងទីកន្លែងរស់នៅក៏ដោយ ក៏ចាំបាច់ត្រូវមានអ្នកសង្កេតការណ៍ដែរ។[74] គោលបំណងនៃការកំណត់បែបនេះ គឺដើម្បីសង្កេតទៅលើភាពត្រឹមត្រូវនៅក្នុងការអនុវត្ត និងដើម្បីបង្កើតភស្តុតាងសម្រាប់ពេលអនាគតផង។

### គ.៥. ការអនុវត្តនៅថ្ងៃសម្រាក ឬពេលយប់

ដើម្បីចូលទៅបំពេញមុខនាទីក្នុងទីកន្លែងរស់នៅរបស់ជនណាម្នាក់ នៅថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកដែលច្បាប់បានកំណត់ ឬនៅក្នុងចន្លោះពីម៉ោងប្រាំមួយល្ងាច ដល់ម៉ោងប្រាំមួយព្រឹក អាជ្ញាសាលាត្រូវទទួលការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅ ឬតុលាការអនុវត្តដែលចេញដីកាបង្គាប់។ បន្ថែមពីនេះ នៅពេលបំពេញមុខនាទី អាជ្ញាសាលាត្រូវបង្ហាញលិខិតដែលបញ្ជាក់ថាខ្លួនបានទទួលការអនុញ្ញាតនោះផងដែរ។[75] ការកំណត់បែបនេះ គឺដើម្បីជៀសវាងការបៀតបៀនដល់ភាពស្ងប់សុខ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់កូនបំណុល ដោយពុំមានភាពចាំបាច់។

---

[73] មាត្រា៣៣៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[74] មាត្រា៣៣៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[75] មាត្រា៣៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

### គ.៦. ការធ្វើកំណត់ហេតុ

អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុស្តីពីការបំពេញមុខនាទីរបស់ខ្លួន។[76] អាជ្ញាសាលា ត្រូវរក្សាទុកកំណត់ហេតុអំពីការអនុវត្តដោយបង្ខំ ព្រមទាំងឯកសារផ្សេងៗទៀតដែលពាក់ពន្ធ័នឹងរឿងក្តីដែលមានការអនុវត្តដោយបង្ខំ ដើម្បីធ្វើជាសំណុំរឿងនៃការអនុវត្តដោយបង្ខំ។[77]

### គ.៧. វិធីឧបាស្រ័យ

វិធីឧបាស្រ័យចំពោះការចាត់ចែងការអនុវត្តដោយអាជ្ញាសាលា ត្រូវធ្វើឡើងតាមរយៈការតវ៉ាចំពោះការអនុវត្ត។

## ១.៨.លិខិតអនុវត្ត

ការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើលិខិតអនុវត្ត។ លិខិតអនុវត្ត គឺជាលិខិតដែលបានកំណត់ខាងក្រោមនេះ[78]៖

- សាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ។
- សាលក្រម ឬសាលដីកាបង្គាប់ ឱ្យផ្តល់តាវការលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។
- ដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក។ ប៉ុន្តែ ចំពោះដីកាសម្រេចដែលមិនត្រូវមានអានុភាពបើមិនទាន់ចូលជាស្ថាពរវិញ មានកម្រិតតែដីកាសម្រេចនោះបានចូលជាស្ថាពរហើយ។
- ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។
- ការចាត់ចែងរបស់ក្រឡាបញ្ជីដែលបានកំណត់ នៅក្នុងនីតិវិធីកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្តី។[79]
- លិខិតយថាភូតដែលធ្វើដោយសាការី
- សាលក្រម ឬសាលដីការបស់តុលាការបរទេស ដែលមានសាលក្រមអនុវត្ត ដែលបានចូលជាស្ថាពរ តាមបទប្បញ្ញត្តិស្តីពី សាលក្រមអនុវត្តសាលក្រម ឬសាលដីការរបស់តុលាការបរទេស[80]។

---

[76] មាត្រា២០ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា

[77] មាត្រា៣៧៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[78] មាត្រា៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[79] មាត្រា៦៦.កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[80] មត្រា៣៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

- សេចក្តីសម្រេចមជ្ឈត្តករ ដែលមានដីកាសម្រេចអនុវត្តដែលបានចូលជាស្ថាពរតាមប្បញ្ញត្តិស្តីពី ដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ[81]។
- កំណត់ហេតុដែលបានកំណត់នៅក្នុងមាត្រា២២២ បានចែងអំពីអានុភាពនៃកំណត់ហេតុសះជាជាអាទិ៍ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ និងកំណត់ហេតុផ្សេងទៀតដែលមានអានុភាពដូចសាលក្រម ឬ សាលដីការដែលបានចូលជាស្ថាពរ។

## ១.៩.ប្រភេទនៃលិខិតអនុវត្តដោយបង្ខំ

### ១.៩.១ សាលក្រម ឬសាលដីការបង្គាប់ឱ្យផ្តល់តាវការលិកចូលជាស្ថាពរ

សាលក្រម ឬសាលដីកាដែលចូលជាស្ថាពរអាចអនុវត្តបានចាប់តាំងពីពេលដែលអាជ្ញាអស់ជំនុំកើតឡើង ហើយរាប់បញ្ចូលផងដែរនូវសាលក្រម ឬសាលដីកាព្រហ្មទណ្ឌដែលទទួលស្គាល់ការទាមទារ ផ្នែករដ្ឋប្បវេណី។[82]

### ១.៩.២ សាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្តល់តាវការលិក ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ បានបញ្ញត្តិអំពីការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។[83] ចំពោះសាលក្រមដែលសម្រេចអំពីការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ បើយល់ឃើញថាចាំបាច់ តុលាការអាចប្រកាសថា សាលក្រមនេះអាច អនុវត្តបណ្តោះអសន្នបានដោយ ឱ្យដើមចោទ ដែលឈ្នះក្តីដាក់ប្រាតិភោគ ឬមិនអាចដាក់ប្រាតិភោគ តាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិរបស់ខ្លួន។

មួយវិញទៀត តុលាការអាចប្រកាសថា ភាគីរួចផុតពីការអនុវត្តជាបណ្តោះអាសន្នបាន ដោយឱ្យដាក់ប្រាតិភោគតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន។ ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននេះ ត្រូវចែងនៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម។ ត្រង់ចំណុចនេះ ត្រូវបានគេយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការប្រកាសដែលបានកំណត់នៅក្នុងមាត្រា១៩៦ កថាខណ្ឌទី២ ស្តីពីការប្រកាសឱ្យអនុវត្តជាបណ្តោះអសន្ន នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

ម្យ៉ាងវិញទៀត ក្នុងករណីមិនបានសម្រេចសេចក្តីអំពីពាក្យសុំប្រកាសឱ្យអនុវត្តជា បណ្តោះអាសន្ន ឬក្នុងករណីដែលត្រូវប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នដោយឆន្ទានុសិទ្ធិ តែមិនបានធ្វើ តុលាការត្រូវចេញដីកាសម្រេចបន្ថែមតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិរបស់ខ្លួន។ បញ្ញត្តិនេះ ត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ

[81] មាត្រា៣៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[82] មាត្រា១០៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[83] មាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ចំពោះករណីដែលតុលាការមិនបានចម្រេចសេចក្តីអំពីពាក្យសុំ ដែលបានកំណត់នៅក្នុងមាត្រា១៩៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។ ស្តីពីការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នផងដែរ។

### ១.៩.៣ ដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក

ដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក មានអានុភាពបាន ទាល់តែដីកាសម្រេចនេះបានចូលជាសារពេ។ ដីកាសម្រេចទាំងនោះរួមមាន៖

- ដីកាសម្រេចបង្គាប់ឱ្យប្រគល់នាវា[84]
- ដីកាបង្គាប់ឱ្យប្រគល់អចលនវត្ថុ ដែលកូនបំណុលបានកាន់កាប់ប្រគល់ទៅឱ្យអ្នកទិញតាមពាក្យសុំរបស់អ្នកទិញដែលបានបង់ថ្លៃលក់ហើយ[85]

ជាគោលការណ៍ ដីកាសម្រេចនឹងមានអានុភាព លុះត្រាតែបានជូនដំណឹង តាមនីតិវិធីដែលអាចទទួលស្គាល់ថាសមរម្យ។[86]

### ១.៩.៤ ដីកាសម្រេចដាស់តឿន ដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តបណ្តោះអាសន្ន

ក្រមនីតិវិធីរដ្ឋប្បវេណី ក៏បានចែងពីនីតិវិធីដាស់តឿនផងដែរ។ នៅក្នុងនីតិវិធីដាស់តឿន តុលាការអាចចេញដីកាសម្រេចដាស់តឿន ដោយប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នបាន។[87]

### ១.៩.៥ ការចាត់ចែងរបស់ក្រឡាបញ្ជី

ការចាត់ចែងរបស់ក្រឡាបញ្ជី គឺមាននៅក្នុងនីតិវិធីដើម្បីកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្តី។[88] ចំនួនប្រាក់ប្រដាប់ក្តីដែលត្រូវទទួលបន្ទុកបង់ ត្រូវកំណត់ដោយក្រឡាបញ្ជីរបស់តុលាការនៃការជំនុំជម្រះលើកទី១ តាមពាក្យសុំ នៅក្រោយពេលដែលសេចក្តីសម្រេចអំពីបន្ទុកនោះបានបង្កើតអានុភាពនៃការអនុវត្ត។

### ១.៩.៦ លិខិតយថាភូតដែលធ្វើដោយសារការី

ចំពោះការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់មានកំណត់។ ប៉ុន្តែ មានកម្រិតតែលិខិតដែលបញ្ជាក់សេចក្តីថ្លែងការណ៍ថា កូនបំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ។[89]

[84] មាត្រា៤៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[85] មាត្រា៤៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[86] មាត្រា៤១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[87] មាត្រា៤២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[88] មាត្រា៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[89] មាត្រា៣៥០ កថាខណ្ឌទី២.ចំណុច(ច) នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

### ១.៩.៧ សាលក្រមអនុវត្តសាលក្រម ឬសាលដីការបស់តុលាការបរទេស

ដើម្បីអនុវត្តដោយបង្ខំលើសាលក្រម ឬសាលដីការបស់តុលាការបរទេស[90] ត្រូវទទួលសាលក្រមអនុវត្តពីតុលាការនៃព្រះរាជាណាចក្រកម្ពុជាជាមុនសិន។ បណ្តឹងទាមទារឱ្យចេញសាលក្រមអនុវត្ត ចំពោះសាលក្រម ឬសាលដីការបស់តុលាការបរទេស ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើកន្លែងរបស់កូនបំណុលនៃការអនុវត្ត ដែលបានកំណត់ពីសមត្ថកិច្ចសាលាជម្រះក្តី[91] ដែលបានទៅតាមលំនៅឋានជាអាទិ៍។ នៅក្នុងករណីដែលមិនអាចកំណត់តុលាការដែលមានសមត្ថកិច្ចបាន ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលកម្មវត្ថុនៃការទាមទារ ឬទ្រព្យរបស់កូនបំណុលនៃការអនុវត្តដែលអាចរឹបអូសបានស្ថិតនៅ។

ប្រសិនបើមិនអាចបញ្ជាក់ថាសាលក្រម ឬសាលដីការបស់តុលាការបរទេសបានចូលជាស្ថាពរ ឬប្រសិនបើសាលក្រម ឬសាលដីកានេះមិនបានបំពេញល័ក្ខខ័ណ្ឌនានា ដែលបានកំណត់នៅក្នុងចំនុចនីមួយៗស្តីពី អានុភាពនៃសាលក្រមស្ថាពររបស់តុលាការបរទេស[92]នោះទេ តុលាការត្រូវលើកចោលបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ នៃមាត្រា៣៥២ ស្តីពីសាល ក្រមអនុវត្តសាលក្រម ឬសាលដីការបស់តុលាការបរទេស។ ការចេញសាលក្រមអនុវត្ត ត្រូវធ្វើឡើងដោយមិនស្រាវជ្រាវអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលក្រម ឬសាលដីការបស់តុលាការបរទេសទេ។ នៅក្នុងសាលក្រមអនុវត្ត តុលាការត្រូវប្រកាសអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ តាមសាលក្រម ឬសាលដីការបស់តុលាការបរទេស។

### ១.៩.៨ សេចក្តីសម្រេចមជ្ឈត្តករ

ដើម្បីធ្វើការអនុវត្តដោយបង្ខំ ដោយផ្អែកលើសេចក្តីសម្រេចមជ្ឈត្តករ[93] ទោះបី ជាសេចក្តីសម្រេចមជ្ឈត្តករក្នុងប្រទេសក៏ដោយ សេចក្តីសម្រេចមជ្ឈត្តករបរទេសក៏ដោយ ត្រូវទទួលដីកាសម្រេចអនុវត្តរបស់តុលាការនៅព្រះរាជាណាចក្រកម្ពុជា។ ភាគីដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ ត្រូវដាក់លិខិតដូចខាងក្រោមនេះ៖

- ច្បាប់ដើមនៃសេចក្តីសម្រេចមជ្ឈត្តករដែលត្រូវបានបញ្ជាក់ដោយត្រឹមត្រូវ ឬឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ត្រឹមត្រូវ។
- ច្បាប់ដើមនៃកិច្ចសន្យាមជ្ឈត្តកម្ម ឬឯកសារចម្លងនៃកិច្ចសន្យានោះ ដែលមានសេចក្តីបញ្ជាក់ត្រឹមត្រូវ។

[90] មាត្រា៣៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
[91] មាត្រា៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
[92] មាត្រា១៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
[93] មាត្រា៣៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

តុលាការអាចបដិសេធការអនុវត្តសេចក្តីសម្រេចមជ្ឈត្តករបាន បើភាគីដែលនឹងទទួលការខូចខាតផលប្រយោជន៍ពីការអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ សំអាងបញ្ជាក់ហេតុដូចខាងក្រោម៖

- ភាគីនៃកិច្ចសន្យាមជ្ឈត្តកម្ម គ្មានសមត្ថភាព ឬកិច្ចសន្យាមជ្ឈត្តកម្មនោះ ត្រូវចាត់ទុកជាមោឃៈ តាមបទដ្ឋានគតិយុត្តដែលគូភាគីកំណត់ច្បាប់យោង ឬតាមបទដ្ឋានគតិយុត្តនៃប្រទេសដែលសេចក្តីសម្រេចមជ្ឈត្តករ ត្រូវបានធ្វើឡើង បើគ្មានការកំណត់ដោយគូភាគី។
- ភាគីដែលនឹងទទួលការខូចខាតផលប្រយោជន៍ ពីការអនុវត្តសេចក្តីសម្រេច មជ្ឈត្តករ មិនបានទទួលសេចក្តីជូនដំណឹងសមរម្យអំពីការជ្រើសតាំងមជ្ឈត្តករ ឬនីតិវិធីមជ្ឈត្តកម្ម ឬមិនអាចការពារខ្លួនដោយសារមូលហេតុផ្សេងទៀត។
- សេចក្តីសម្រេចមជ្ឈត្តករ ទាក់ទងនឹងវិវាទដែលមិនបានកំណត់នៅក្នុងចំណុចដែលត្រូវទទួលមជ្ឈត្តកម្ម ឬវិវាទក្រៅទំហំនៃចំនុចនោះ ឬមានសេចក្តីសម្រេចអំពីចំណុចដែលហួសពីទំហំនៃចំណុចដែលត្រូវទទួលមជ្ឈត្តកម្ម។
- ការរៀបចំអង្គភាពវិនិច្ឆ័យនៃមជ្ឈត្តកម្ម ឬនីតិវិធីនៃមជ្ឈត្តកម្ម មិនស្របតាមការព្រមព្រៀងរបស់ភាគី ឬបើគ្មានការព្រមព្រៀងនោះ មិនស្របតាមបទដ្ឋានគតិយុត្តនៃប្រទេសដែលមជ្ឈត្តកម្មត្រូវបានធ្វើឡើង។
- សេចក្តីសម្រេចមជ្ឈត្តករ មិនទាន់មានអានុភាពចងភាគី ឬត្រូវបានលុបចោល ដោយតុលាការនៃប្រទេសដែលសេចក្តីសម្រេចមជ្ឈត្តករនោះត្រូវបានធ្វើឡើង ឬប្រទេសដែលមានបទដ្ឋានគតិយុត្ត ដែលជាមូលដ្ឋាននៃសេចក្តីសម្រេចមជ្ឈត្តករនោះ។

តុលារការអាចបដិសេធការអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ ប្រសិនបើយល់ឃើញថា មានហេតុដូចខាងក្រោមនេះ៖

- ចំនុចដែលជាកម្មវត្ថុនៃវិវាទ មិនអាចដោះស្រាយបាន ដោយមជ្ឈត្តករ
- ការទទួលស្គាល់ ឬការអនុវត្តសេចក្តីសម្រេចមជ្ឈត្តករផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ។

ពាក្យសុំចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករក្នុងប្រទេស ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការ ដែលមានសមត្ថកិច្ចលើកន្លែងរបស់កូនបំណុលនៃការអនុវត្ត ដែលបានកំណត់នៅក្នុងមាត្រា៨ ស្តីពីសមត្ថកិច្ចសាលាជំនុំជម្រះក្តីដែលបានកំណត់ទៅតាមលំនៅឋានជាអាទិ៍ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ក្នុងករណីដែលមិនអាចកំណត់តុលាការដែលមានសមត្ថកិច្ចទេនោះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូង ដែលមានសមត្ថកិច្ចលើកន្លែងដែលកម្មវត្ថុនៃការទាមទារ ឬទ្រព្យរបស់កូនបំណុលនៃការអនុវត្តដែលអាចរឹបអូសបានស្ថិតនៅ។ ពាក្យសុំចេញដីការសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករបទេស ត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍។ ការចេញដីការសម្រេចអនុវត្ត ត្រូវធ្វើឡើងដោយមិនស្រាវជ្រាវអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសេចក្តីសម្រេចមជ្ឈត្តករ លើកលែងតែក្នុងករណី ដែលបានកំណត់នៅក្នុងកថាខណ្ឌទី៣ និងកថាខណ្ឌទី៤ នៃមាត្រា៣៥៣ ស្តីដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។ ក្នុងដីកា

សម្រេចអនុវត្ត តុលាការត្រូវប្រកាសអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ តាមសេចក្តីសម្រេចមជ្ឈត្តករ។ ចំពោះដីកាសម្រេចអំពីពាក្យសុំឱ្យចេញដីកាសម្រេចអនុវត្ត អាចប្តឹងជំទាស់បាន។ ដីកាសម្រេចអនុវត្ត មិនត្រូវមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរទេ។

### ១.៩.៩ កំណត់ហេតុ

អានុភាពនៃកំណត់ហេតុស្តីពីការសះជា ជាអាទិ៍ មានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។[94] ក្នុងករណីដែលមានការសះជា ការលះបង់នូវការទាមទារ ឬការទទួលស្គាល់នូវការទាមទារត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុ កំណត់ត្រានេះ មានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ។

## ១.១០.រូបមន្តអនុវត្តដោយបង្ខំ

នៅក្នុងដំណើរការនីតិវិធីនៃការអនុវត្តដោយបង្ខំ ចាំបាច់ណាស់ត្រូវតែមាន**រូបមន្តអនុវត្ត** និង**ស្ថាប័នផ្តល់រូបមន្តអនុវត្ត**។[95] ការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូត នៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត។

ប៉ុន្តែ ក្នុងករណីដែលយកឯកសារដែលបានកំណត់ដូចខាងក្រោមនេះជាលិខិតអនុវត្តការអនុវត្តដោយបង្ខំ ដោយយកភាគីដែលបានកំណត់ក្នុងលិខិតអនុវត្តនោះ ធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុវត្ត ត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តនោះ៖

- សាលក្រមនៃបណ្តឹងរឿងក្តីទឹកប្រាក់តិចដែលចូលជាស្ថាពរ
- សាលក្រមនៃបណ្តឹងរឿងក្តីទឹកប្រាក់តិចដែលភ្ជាប់ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន
- ដីកាសម្រេចដាស់តឿនដែលភ្ជាប់ការប្រកាសឱ្យអនុវត្តបណ្តោះអាសន្ន។

រូបមន្តអនុវត្ត ត្រូវផ្តល់ដោយក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿងនោះតាមពាក្យសុំ។ ប៉ុន្តែចំពោះលិខិតអនុវត្តដែលមានកំណត់នៅក្នុងចំណុច ច កថាខណ្ឌទី២ នៃមាត្រា៣៥០ ដែលចែងពី លិខិតអនុវត្ត នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវផ្តល់ដោយសាការីដែលរក្សាទុកនូវលិខិតដើមនោះ។[96]

**ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត** ត្រូវធ្វើឡើងដោយលិខិតជាលាយលក្ខណ៍អក្សរ ដែលសរសេរចំណុចដូចខាងក្រោមនេះ[97] ៖

---

[94] មាត្រា២២២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[95] មាត្រា៣៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[96] មាត្រា៣៥៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[97] មាត្រា៣៥៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនឹងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។
- សញ្ញាណនៃលិខិតអនុវត្ត
- ហេតុការណ៍ និងមូលហេតុ បើការទាមទារឱ្យផ្តល់រូបមន្តអនុវត្តធ្វើឡើងតាមបញ្ញត្តិនៃមាត្រា៣៥៦ រូបមន្តអនុវត្តពិសេស ឬកថាខណ្ឌទី១ នៃមាត្រា៣៥៨ ការផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ជាអាទិ៍ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

នៅក្នុងករណី ដែលលិខិតអនុវត្តជាសេចក្តីសម្រេចដែលមិនបានបង្កើតអានុភាពបើមិនចូលជាសាពរទេនោះ ម្ចាស់បំណុលនៃការអនុវត្តត្រូវភ្ជាប់មកជាមួយពាក្យសុំនូវលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសេចក្តីសម្រេចនោះ។[98] ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលច្បាស់លាស់ថាសេចក្តីសម្រេចនោះចូលរជាស្ថាពរហើយ ក្នុងសំណុំរឿង។ បញ្ញត្តិនៃមាត្រា៣៥៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បំណុលនៃការអនុវត្ត ទាមទារឱ្យប្រគល់ថែមទៀតនូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី២ នៃកថាខណ្ឌទី១ មាត្រា៣៥៤ ស្តីពីភាពចាំបាច់នៃរូបមន្តអនុវត្ត និងស្ថាប័នផ្តល់រូបមន្តអនុវត្ត នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។[99]

[98] មាត្រា៣៥៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[99] មាត្រា៣៥៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

# ជំពូកទី២

# នីតិវិធីនៃការអនុវត្តដោយបង្ខំ

នៅក្នុងជំពូកទី២ នេះ យើងនឹងធ្វើការសិក្សាទៅលើលំហូរនៃការអនុវត្តដោយបង្ខំលើចលនវត្ថុ និងលំហូរនៃការអនុវត្តដោយបង្ខំអចលនវត្ថុ។ មុនចាប់ផ្ដើមការអនុវត្តដោយបង្ខំ ម្ចាស់បំណុលនៃការអនុវត្ត តែងតែចង់បានការអនុវត្តដោយស្ម័គ្រចិត្ត ដែលករណីនេះវាមិនអាចនឹងទទួលបាននូវការចំណេញប្រាក់ និងពេលវេលាដោយធ្វើការចរចា។ មិនចាំបាច់ទាមទារ ឲ្យម្ចាស់បំណុលនៃការអនុវត្តធ្វើការស្រាវជ្រាវ អំពីទ្រព្យសម្បត្តិជាចលនវត្ថុរបស់កូនបំណុលនៃការអនុវត្តនោះទេ ពោលគឺ គ្រាន់តែបញ្ជាក់ថាសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត ដោយត្រូវបញ្ជាក់អំពីទីតាំងនៃចលនវត្ថុជាការចាំបាច់ការស្រាវជ្រាវអំពីអត្តសញ្ញាណនៃទ្រព្យសម្បត្តិនេះ គឺជាកាតព្វកិច្ចម្ចាស់បំណុលមិនមែនអាជ្ញាសាលាទេ។ ជាការពិតណាស់ មុនស្ថាប័នអនុវត្តធ្វើការបង្ខំទៅលើកូនបំណុលនៃការអនុវត្ត ឱ្យអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួន ត្រូវឆ្លងកាត់នីតិវិធីនៃការចរចាដោយសន្តិវិធីជាមុនសិន។ ប៉ុន្តែប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្តពុំអាចចរចាគ្នាបានដោយសន្តិវិធីបានទេនោះ ស្ថាប័នអនុវត្ត អាចដំណើរការអនុវត្តនីតិវិធីនៃការអនុវត្តដោយបង្ខំបាន ព្រោះវាជាកាតព្វកិច្ចរបស់ស្ថាប័នអនុវត្ត។

## ២.១. លំហូរនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

ស្ថាប័នអនុវត្តរួមមាន តុលាការអនុវត្ត និងអាជ្ញាសាលា។ ដោយឡែកការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ គឺស្ថិតក្រោមសមត្ថកិច្ចរបស់អាជ្ញាសាលានៃសាលាដំបូងដែលចលនវត្ថុនៃការអនុវត្តដោយបង្ខំនោះស្ថិតនៅ នេះបើយោងតាមមាត្រា៣៣៦ កថាខណ្ឌទី២ និងមាត្រា៣៨៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។ នៅក្នុងនោះដែរ អាជ្ញាសាលាមានសិទ្ធិអំណាចក្នុងការអនុវត្តដូចជា សិទ្ធិប្រើប្រាស់កម្លាំងឬនគរបាល[100] សិទ្ធិឆែកឆេរ[101] សិទ្ធិជាអ្នកសង្កេតការណ៍ សិទ្ធិរកអ្នកវាយតម្លៃ[102] និងសិទ្ធិជ្រើសរើសវត្ថុដែលត្រូវរឹបអូស[103]....។ល។

### ២.១.១. ការសរសេរពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

ត្រូវអនុវត្តតាម ហើយត្រូវដាក់មកស្ថាប័នអនុវត្ត តាមបញ្ញត្តិនៃមាត្រា៤១៧ កថាខណ្ឌទី៣ដែលត្រូវបញ្ជាក់អំពី៖[104]

---

[100] មាត្រា៣៣៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[101] មាត្រា៣៨៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[102] មាត្រា៣៩៥ កថាខណ្ឌទី៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[103] មាត្រា៣៨៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[104] មាត្រា៣៨៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត និង ឈ្មោះនិងអាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់
- សញ្ញាណនៃលិខិតអនុវត្ត
- សញ្ញាណនៃទ្រព្យសម្បត្តិរបស់កូនបំណុល (បញ្ជាក់អំពីទីតាំងនៃចលនវត្ថុដែលត្រូវរឹបអូស)។

### ២.១.២. ឯកសារភ្ជាប់មកជាមួយនឹងពាក្យសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

ជាគោលការណ៍ ពាក្យសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ត្រូវតែភ្ជាប់មកជាមួយនូវឯកសារមួយចំនួន ដូចជា៖

- ឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត មានចែងក្នុងមាត្រា៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
- រូបមន្តអនុវត្ត ចែងក្នុងមា៣៥៤ និងមាត្រា៣៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
- លិខិតបញ្ជាក់ការចូលជាស្ថាពរ នៃលិខិតអនុវត្ត ដែលត្រូវចេញដោយក្រឡាបញ្ជីចែងក្នុងមាតត្រា២៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ក្នុងករណីលិខិតអនុវត្តជាសាលក្រម ឬជាសាលដីកាស្ថាពរដែល ទាមទារឲ្យផ្តល់តាវកាលិក
- រូបមន្តអនុវត្ត និងឯកសារពាក់ព័ន្ធផ្សេងទៀតដែលចេញដោយក្រឡាបញ្ជី ឬសាការី

### ២.១.៤. ការដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

ពាក្យសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ត្រូវយកទៅដាក់នៅការិយាល័យអាជ្ញាសាលា នៃសាលាដំបូង ដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំស្ថិតនៅ គឺសំដៅដល់កន្លែងដែល ចលនវត្ថុនោះស្ថិតនៅ។ នៅក្នុងពាក្យសុំអនុវត្តចំពោះចលនវត្ថុ ត្រូវសរសេរអំពីទីកន្លែងដែលចលនវត្ថុដែលត្រូវរឹប អូសនោះស្ថិតនៅ។ ប៉ុន្តែគេមិនចាំបាច់ចង្អុលបង្ហាញចំៗអំពីទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការរឹបអូសទេ។[105] ក្នុង ករណីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅតុលាការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធចំនួន ១០.០០០ (មួយម៉ឺន) រៀល ទៅតុលាការ។[106] ប៉ុន្តែ នៅក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅអាជ្ញា សាលា ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធ តាមបញ្ញត្តិដែលកំណត់ផ្សេង។[107] ម្ចាស់បំណុល ត្រូវបង់ពន្ធដាក់ ពាក្យសុំទៅអាជ្ញាសាលាចំនួន ៥.០០០ (ប្រាំពាន់) រៀល។[108] នៅក្នុងនោះដែរ ម្ចាស់បំណុលនៃការអនុវត្ត ក៏ត្រូវ បង់សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំផងដែរ។ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវបង់ពន្ធនូវចំនួនទឹកប្រាក់ដែល កំណត់ដោយតុលាការជាសោហ៊ុយចាំបាច់ក្នុងការបញ្ជូនឯកសារ ឬធ្វើសកម្មភាពផ្សេងទៀតដើម្បីនីតិវិធីក្នុងការ

[105] មាត្រា៣៨៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[106] មាត្រា៣៧២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[107] មាត្រា៣៧២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[108] ប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលាឆ្នាំ២០០៧ ប្រការ១៣

អនុវត្តដោយបង្ខំ។[109] ក្រៅពីសោហ៊ុយដែលបានកមណត់នៅក្នុងពន្ធដាក់ពាក្យសុំ និងសោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ សោហ៊ុយដែលតុលាការទទួលស្គាល់ថាចាំបាច់ដើម្បីធ្វើការអនុវត្តដោយបង្ខំ ត្រូវបានចាត់ទុកថាជាសោហ៊ុយភាគី។[110]

នៅពេលដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅតុលាការអនុវត្ត អ្នកដែលដាក់ពាក្យសុំត្រូវបង់ជាមុននូវចំនួនទឹកប្រាក់ដែលតុលាការអនុវត្តកំណត់ថាជាសោហ៊ុយចាំបាច់ ដើម្បីធ្វើនីតិវិធីនៃការអនុវត្តដោយបង្ខំ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីដែលសាហ៊ុយដែលត្រូវបានបង់ជាមុនមានភាពខ្វះហើយតុលាការអនុវត្តបង្គាប់ឲ្យបង់ជាមុននូវសោហ៊ុយដែលខ្វះនោះ។[111] បើអ្នកដាក់ពាក្យសុំមិនបានបង់សោហ៊ុយជាមុនទេ តុលាការអនុវត្តអាចលើកចោលពាក្យសុំអនុវត្តដោយបង្ខំ ឬអាចលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំនោះបាន។[112] ចំពោះដីកាសម្រេចលើកចោលពាក្យសុំ ម្ចាស់បំណុលនៃការអនុវត្តអាចប្ដឹងជំទាស់បាន។[113]

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេនីឆ្នាំ២០០៦ ក៏បានកំណត់អំពីបន្ទុកនៃសោហ៊ុយសម្រាប់ការអនុវត្តដែរ។ ចំពោះសោហ៊ុយសម្រាប់ការអនុវត្ត ជាបន្ទុករបស់កូនបំណុលនៃការអនុវត្ត។[114] ក្នុងករណីដែលអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ សោហ៊ុយសម្រាប់ការអនុវត្ត អាចប្រមូលយកព្រមគ្នាក្នុងនីតិវិធីនៃការអនុវត្តបាន ដោយពុំចាប់បាច់មានលិខិតអនុវត្តទេ។[115]

### ២.១.៥. ការពិនិត្យពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

អាជ្ញាសាលា ត្រូវចាត់ចែងកិច្ចការតាមលំដាប់លំដោយដែលខ្លួនបានទទួល លើកលែងតែក្នុងករណីដែលមានស្ថានភាពពិសេសតែប៉ុណ្ណោះ។ នៅពេលដែលទទួលបានពាក្យសុំ អាជ្ញាសាលាត្រូវពិនិត្យលើចំណុចមួយចំនួនដូចជាៈ តើត្រូវនឹងសមត្ថកិច្ច ដែរឬទេ? តើពាក្យសុំត្រឹមត្រូវតាមការកំណត់នៅក្នុងមាត្រា៣៤៩ ស្ដីពីរបៀបដាក់ពាក្យសុំអនុវត្តដោយបង្ខំ និងមាត្រា៣៨៤ ស្ដីពីការចាប់ផ្ដើមអនុវត្តចំពោះអចលនវត្ថុ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ហើយឬនៅ? តើភាគីត្រឹមត្រូវដូចក្នុងលិខិតអនុវត្ត ដែរឬទេ? តើមានឯកសារភ្ជាប់គ្រប់គ្រាន់ដូចជា មានលិខិតអនុវត្ត មានលិខិតបញ្ជាក់អំពីការចូលជាស្ថាពរនិងមានរូបមន្តអនុវត្ត មានលិខិតបញ្ជាក់សិទ្ធិតំណាង ដែរឬទេ? តើបានបង់ពន្ធដាក់ពាក្យសុំឬទេ? តើបានបញ្ជូនលិខិតអនុវត្តទៅកូនបំណុល នៃការអនុវត្តជាមុនតាមការកំណត់ក្នុងមាត្រា៣៦០ ស្ដីពីការបញ្ជូនលិខិតអនុវត្តជាអាទិ៍ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[109] មាត្រា៣៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[110] មាត្រា៣៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[111] មាត្រា៣៧៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[112] មាត្រា៣៧៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[113] មាត្រា៣៧៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[114] មាត្រា៣៧៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[115] មាត្រា៣៧៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ឬទេ? ការបង់សោហ៊ុយជាមុន? កម្រៃនិងសាហ៊ុយចាំបាច់ មាត្រា៣៥ថ្មី នៃច្បាប់ស្តីពីអាជ្ញាសាលា និងប្រការ១៥ នៃប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា។

### ២.១.៦. ការរឹបអូសចលនវត្ថុ

#### ក. ការចាប់ផ្តើមអនុវត្តដោយការរឹបអូស

ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ត្រូវចាប់ផ្តើមដោយការរឹបអូសចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស ដោយអាជ្ញាសាលា ដោយផ្អែកទៅតាមពាក្យសុំអនុវត្តដោយបង្ខំរបស់ម្ចាស់បំណុលនៃការអនុវត្តនេះ និងលិខិតអនុវត្ត។[116] ប៉ុន្តែគេនៅតែមិនទាន់ចាត់ទុកថា ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ មិនទាន់បានចាប់ផ្តើមដែរ បើទោះបី ជាអាជ្ញាសាលាបានធ្វើការដាស់តឿនឲ្យកូនបំណុលនៃការអនុវត្តការសងដោយស្ម័គ្រចិត្តនៅទីកន្លែងនៃការអនុវត្តក៏ដោយ។[117]

#### ខ. គោលការណ៍សំខាន់ៗនៃការរឹបអូសអចលនវត្ថុ

ការរឹបអូស អាចធ្វើបានចំពោះរូបទ្រព្យ ឬអរូបទ្រព្យដែលធ្លាក់ទៅលើកូនបំណុលនៃការអនុវត្ត លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ឬច្បាប់ផ្សេង។[118] ជាគោលការណ៍ គ្រប់ចលនវត្ថុទាំងអស់ដែលជាកម្មសិទ្ធិ ឬស្ថិតក្រោមការកាន់កាប់របស់កូនបំណុល នៃការអនុវត្តសុទ្ធតែជាកម្មវត្ថុនៃការរឹបអូសទាំងអស់ ដោយពុំចាំបាច់ធ្វើការស្រាវជ្រាវអំពីកម្មសិទ្ធិនៅមុនការរឹបអូសនោះទេ លើកលែងតែមានកំណត់ពិសេសនៅក្នុងច្បាប់។ ចលនវត្ថុ ជាកម្មវត្ថុនៃការរឹបអូសនោះ រួមទាំងផលធម្មជាតិដែលមិនទាន់បំបែកពីដីនៅឡើយ ហើយអាចនឹងទទួលផលបានយ៉ាងច្រើន នៅក្នុងអំឡុងពេល ០១ខែ។[119]

#### គ. ចលនវត្ថុដែលហាមឃាត់មិនឲ្យរឹបអូស

ជាគោលការណ៍ ទ្រព្យសម្បត្តិទាំងអស់របស់កូនបំណុលនៃការអនុវត្ត អាចក្លាយជាម្មវត្ថុនៃការរឹបអូស ប៉ុន្តែដោយមានមូលហេតុពាក់ពន្ធ័ទៅនឹងគោលនយោបាយ ដូច្នេះទ្រព្យសម្បត្តិមួយចំនួនត្រូវបានហាមឃាត់មិនឱ្យរឹបអូសដោយសារមូលហេតុមួយចំនួនដូចតទៅ៖ ធានានិងការពារជីវភាពយ៉ាងទាបបំផុតរបស់កូនបំណុលនៃការអនុវត្ត ធានាការបន្តមុខរបរ នយោបាយផ្នែកវប្បធម៌ និងនយោបាយផ្នែកសង្គម។

[116] មាត្រា៣៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[117] មាត្រា៣៨៤ កថាខណ្ឌទី៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[118] មាត្រា៣៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[119] មាត្រា៣៨៤ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

### ឃ. ការហាមឃាត់មិនឲ្យរឹបអូសហួសប្រមាណ

ជាគោលការណ៍ ការរឹបអូសអចលនវត្ថុ មិនត្រូវធ្វើឲ្យហួសកម្រិតចាំបាច់សម្រាប់សំណងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល នៃការអនុវត្ត និងសោហ៊ុយចាំបាច់សម្រាប់ការអនុវត្តនោះទេ។[120] ករណីនេះ អាចអនុវត្តចំពោះស្ថានភាព ដែលអាជ្ញាសាលាអាចវាយតម្លៃបានភ្លាមៗនូវចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសតែប៉ុណ្ណោះ។ ផ្ទុយមកវិញ ក្នុងករណីដែលចលនវត្ថុនោះ អាជ្ញាសាលាមិនអាចធ្វើការវាយតម្លៃភ្លាមៗនៅនឹងកន្លែងរឹបអូសទេ នោះអាជ្ញាសាលាអាចរឹបអូសមកសិនបន្ទាប់មកបើបានដឹងចលនវត្ថុនោះមានតម្លៃលើសពីកម្រិតចាំបាច់នៃការសងសិទ្ធិលើបំណុលនិងសោហ៊ុយសម្រាប់ការអនុវត្តនោះ អាជ្ញាសាលាអាចធ្វើការលុបចោលការរឹបអូសផ្នែកដែលលើសពីភាពដែលចាំបាច់នោះបាន។

### ង. ការហាមឃាត់មិនឲ្យរឹបអូស ក្នុងករណីដែលប៉ាន់ប្រមាណឃើញថាគ្មានចំនួនសេសសល់

អាជ្ញាសាលាមិនត្រូវរឹបអូសឡើយ ប្រសិនបើប៉ាន់ប្រមាណឃើញថាចំនួនទឹកប្រាក់ដែលបានមកពីការលក់ចលនវត្ថុ ដែលត្រូវបានរឹបអូសនោះគ្មានចំនួនសេសសល់ ក្រោយពីបានបង់សោហ៊ុយសម្រាប់នីតិវិធីហើយ។[121] អាជ្ញាសាលាត្រូវលុបចោលការរឹបអូស ប្រសិនបើប៉ាន់ប្រមាណឃើញថាចំនួនទឹកប្រាក់ដែលបានមកពីការលក់ចនលវត្ថុ ដែលត្រូវបានរឹបអូសនោះគ្មានចំនួនសេសសល់ ក្រោយពីការសងសិទ្ធិលើបំណុលដែលមានអាទិភាពជាងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និងសោហ៊ុយសម្រាប់នីតិវិធីហើយ។[122]

### ច. ការរឹបអូសអចលនវត្ថុកាន់កាប់ដោយកូនបំណុល

អាជ្ញាសាលា ចុះទៅរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្តយកមករក្សាទុក។ បើចាំបាច់អាជ្ញាសាលា អាចបើកទ្វារបិទជិត ឬ អាចបើកទូរដែកបាន។ នៅមុនពេលចាប់ផ្តើមការរឹបអូសចលនវត្ថុ ប្រសិនបើជួបប្រទះកូនបំណុលនៃការអនុវត្តនៅទីកន្លែងដែលត្រូវរឹបអូស អាជ្ញាសាលាត្រូវដាស់តឿនឲ្យកូនបំណុលនៃការអនុវត្តនោះសងដោយស្មគ្រ័ចិត្ត។[123] ករណីនេះ ប្រសិនបើកូនបំណុលយល់ព្រមប្រគល់ប្រាក់សំណងដោយស្មគ្រចិត្ត អាជ្ញាសាលាអាចទទួលយកសំណង និងសោហ៊ុយសម្រាប់ការអនុវត្តបាន។[124] ប៉ុន្តែបើកូនបំណុលនៃការអនុវត្តបដិសេធនោះ អាជ្ញាសាលាត្រូវចាប់ផ្តើមការរឹបអូសចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត ដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត និងសោហ៊ុយសម្រាប់ការអនុវត្ត។

---

120 មាត្រា៣៩១ កថាខណ្ឌទី១០ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

121 មាត្រា៣៩២ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

122 មាត្រា៣៩២ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

123 មាត្រា៣៨៤ កថាខណ្ឌទី៥ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

124 មាត្រា៣៨៤ កថាខណ្ឌទី៦ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ប្រសិនបើ កម្មវត្ថុនៃការរឹបអូសគឺជាប្រាក់ អាជ្ញាសាលាអាចដកហូតយកប្រាក់នោះបាន។[125] ការអនុវត្តប្រភេទនេះ គឺមានលក្ខណៈងាយស្រួលដែលមិនចាំបាច់ទាមទារឲ្យមានការអនុវត្តចាត់ចែងប្តូរជាប្រាក់ម្តងទៀតទេ ពោលគឺអាជ្ញាសាលា អាចបន្តចូលទៅអនុវត្តនីតិវិធីនៃការចែកចំណែកបានម្តងទៀត។ នៅក្នុងករណីរឹបអូសចលនវត្ថុ ដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត អាជ្ញាសាលា អាចរឹបអូសចលនវត្ថុនោះដោយគ្រាន់តែផ្អែកទៅលើរូបភាពខាងក្រៅ នៃការកាន់កាប់របស់កូនបំណុលនៃការអនុវត្តតែប៉ុណ្ណោះ ដោយមិនចាំបាច់ធ្វើការស្រាវជ្រាវអំពីរឿងរ៉ាវ ដែលពាក់ពន្ធ័ជាមួយនឹងកម្មសិទ្ធិអ្វីនោះឡើយ។ មូលហេតុអាជ្ញាសាលា មិនចាំបាច់ធ្វើការស្រាវជ្រាវអំពីកម្មសិទ្ធិនៃចលនា ដែលជាកម្មនៃការរឹបអូសនោះដោយហេតុថា៖

- **ជាគោលការណ៏ច្បាប់៖** ចលនវត្ថុនៅលើដៃអ្នកណា អ្នកនោះត្រូវបានសន្មត់ជាម្ចាស់កម្មសិទ្ធិករ។ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើមើលពីរូបភាពនៃកាន់កាប់ គេអាចដឹងច្បាស់ថា ទ្រព្យនោះជារបស់អ្នកដទៃការរឹបអូសនោះ នឹងមិនត្រូវធ្វើឡើងនោះទេ។ **ឧទាហរណ៍៖** សៀវភៅដែលមានបិទស្លាកខ្ចីបណ្ណាល័យ ម៉ូតូ ឬរថយន្ត ដែលមានស្លាកសញ្ញាអង្គការ.......ជាអាទិ៍ ករណីបែបនេះអាជ្ញាសាលាមិនត្រូវធ្វើការរឹបអូសនោះទេ។
- **ដើម្បីពន្លឿននីតិវិធីនៃការអនុវត្តដោយការបង្ខំ៖**
    - ទោះបីជាមានបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់អំពីការអនុវត្តដោយបង្ខំត្រូវបានធ្វើឡើងក៏ដោយ ក៏អានុភាពនៃការផ្អាកការអនុវត្តមិនត្រូវបានកើតឡើងដោយ
    - ការស្រាវជ្រាវអំពីកម្មសិទ្ធលើចលនវត្ថុ គឺជានីតិវិធីមួយដែលទាមទារឲ្យមានការប្រើប្រាស់ពេលវេលាយូរ ដូច្នេះបើច្បាប់កំណត់ឲ្យអាជ្ញាសាលាត្រូវស្រាវជ្រាវអំពីកម្មសិទ្ធិលើអចលនវត្ថុមុនការរឹបអូសនោះប្រាកដជាមានការលំបាក។
- **ករណីកម្មវត្ថុនៃការរឹបអូសជារថយន្ត ជាអាទិ៏ដែលបានចុះបញ្ជី**
    - ករណីពិសេសចំពោះចលនវត្ថុដែលបានចុះបញ្ជី ប្រសិនបើចលនវត្ថុដែលជាកម្មសិទ្ធនៃការរឹបអូស គឺចលនវត្ថុដែលបានចុះបញ្ជីរួចហើយនោះរួមមានរថយន្ត ជាអាទិ៏ អាជ្ញាសាលាត្រូវផ្ទុកផ្តាក់ទៅស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី សរសេរអំពីហេតុការណ៍នៃការណ៏រឹបអូស ចូលទៅក្នុងសៀវភៅចុះបញ្ជីនោះ ទើបធ្វើឲការរឹបអូសនោះមានអានុភាព។[126]

## ២.១.៧. ការរឹបអូសចលនវត្ថុកាន់កាប់ដោយម្ចាស់បំណុល

ម្ចាស់បំណុលនៃការអនុវត្ត អាចប្រគល់ចលនវត្ថុនោះ មកឲ្យអាជ្ញាសាលា ដោយស្ម័គ្រចិត្តបាន។ នៅក្នុងករណី ដែលម្ចាស់បំណុលនៃការអនុវត្តខ្លួនឯងជាអ្នកកាន់កាប់ចលនវត្ថុរបស់កូនបំណុលអាចប្រគល់ដោយ

[125] មាត្រា៣៨៤ កថាខណ្ឌទី៤ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[126] មាត្រា៣៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ស្ម័គ្រចិត្តនូវចលនវត្ថុនោះ ឱ្យដល់អាជ្ញាសាលាដើម្បីធ្វើការរឹបអូស។[127] **ឧទាហរណ៍** ចំពោះស្ថានភាពបែបនេះ ដូចជាការអនុវត្តកាន់កាប់ចលនវត្ថុរបស់កូនបំណុលក្នុងករណីដែលចលនវត្ថុនោះជាកម្មវត្ថុនៃការបញ្ញើ ឬជាកម្មសិទ្ធនៃការឃាត់ទុក។ល។ អាជ្ញាសាលា អាចរឹបអូសចលនវត្ថុដែលជាកម្មវត្ថុ កាន់កាប់ដោយតតិយជនបាន លុះត្រាតែតតិយជននោះមិនបដិសេធអំពីការរឹបអូស។ នៅក្នុងករណីដែលចលនវត្ថុកាន់កាប់ដោយតតិយជន អាជ្ញាសាលាអាចរឹបអូសចលនវត្ថុនោះបាន លុះត្រាតែតតិយជននោះ មិនដឹងអំពីការប្រគល់ចលនាវត្ថុនោះ។[128] ដោយសារថាអាជ្ញាសាលា មិនអាចធ្វើការរឹបអូសនូវចលនវត្ថុដែលកាន់កាប់ដោយបុគ្គលផ្សេងពីកូនបំណុលនៃការអនុវត្តឡើយ។ ប្រសិនបើ តតិយជនបដិសេធមិនព្រមប្រគល់ចលនាវត្ថុទេនោះ ម្ចាស់បំណុលនៃការអនុវត្តពុំមានជម្រើសអ្វីក្រៅពីធ្វើការរឹបអូសសិទ្ធិទាមទារឱ្យសង ឬសិទ្ធិទាមទារឲប្រគល់វត្ថុ ដែលកូនបំណុលមានចំពោះតតិយជននោះតាមរយៈការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ហើយប្រមូលនិងប្រគល់វត្ថុនោះទៅឲ្យអាជ្ញាសាលា។

### ២.១.៨. ការថែរក្សាចលនវត្ថុដែលត្រូវបានរឹបអូស

អាជ្ញាសាលា ជាអ្នកត្រូវថែរក្សាចលនវត្ថុដែលថាកម្មវត្ថុនៃការរឹបអូស[129] មានតែអាជ្ញាសាលាកាន់កាប់ចលនវត្ថុដែលត្រូវបានរឹបអូសតែប៉ុណ្ណោះ ទើបធ្វើឲ្យមានអានុភាពនៃការរឹបអូសនោះកើតមានឡើង។ ការកាន់កាប់ដោយអាជ្ញាសាលានៅទីនេះ គឺសំដៅដល់ការកាន់កាប់ដោយផ្ទាល់ ដោយអាជ្ញាសាលាពោល គឺការកាន់កាប់មិនអាចត្រូវបានបកស្រាយ រហូតដល់ការកាន់កាប់ដោយប្រយោលដល់អាជ្ញាសាលានោះទេ។ ទោះបីជាការរឹបអូសចំពោះចលនវត្ថុ នឹងមានអានុភាពតាមរយៈការកាន់កាប់ដោយអាជ្ញាសាលាក៏ដោយក៏អាជ្ញាសាលាអាចប្រគល់ចលនវត្ថុនោះទៅឲ្យកូនបំណុលនៃការអនុវត្ត ឬម្ចាស់បំណុលនៃការអនុវត្ត ឬតតិយជនធ្វើការកាប់បានដែរ ប្រសិនបើអាជ្ញាសាលាយល់ថាសមរម្យ។[130] នៅក្នុងករណីនេះ អាជ្ញាសាលា អាចអនុញ្ញាតឲ្យកូនបំណុលថែរក្សា ឬ ប្រើប្រាស់ចលនវត្ថុរឹបអូសនោះបាន ប៉ុន្តែចលនវត្ថុនោះ ត្រូវបិតស្លាកឬដាក់សញ្ញារឹបអូស។

### ២.១.៩. អានុភាពនៃការរឹបអូសចលនវត្ថុ

ក្រោយពីការរឹបអូសកូនបំណុល មិនអាចចាត់ចែងលើចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសនោះបានទេ។ ហើយបើចលនវត្ថុនោះ បានបង្កើតផលក្រោយការរឹបអូស ផលនោះក៏ត្រូវបានរឹបអូសដោយស្វ័យប្រវត្តិដែរ។ ជាគោលការណ៍ដូចដែលយើងបានដឹងស្រាប់មកហើយថា ការរឹបអូសចលនវត្ថុ ត្រូវធ្វើឡើងតាមរយៈការកាន់កាប់ដោយអាជ្ញាសាលា។[131] ក្នុងករណីនេះជាលក្ខខ័ណ្ឌតតាំងមួយ ដែលមិនអនុញ្ញាតិឲ្យកូនបំណុលនៃការអនុ

---

[127] មាត្រា៣៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[128] មាត្រា៣៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[129] មាត្រា៣៨៥ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[130] មាត្រា៣៨៥ កថាខណ្ឌទី៤ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[131] មាត្រា៣៨៤ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

វត្ថុមានលទ្ធភាពក្នុងការចាត់ចែងចលនវត្ថុដែលត្រូវបានរឹបអូសនោះបានឡើយ។ ការរឹបអូសចលនវត្ថុ មានអានុភាពទៅលើផលធម្មជាតិ ដែលកើតចេញពីចលនវត្ថុដែលត្រូវរឹបអូសនោះផងដែរ។[132] នៅក្នុងករណីនេះ វិសាលភាពនៃការរឹបអូស នឹងត្រូវកើតមានលើផលធម្មជាតិនោះ ដោយម្ចាស់បំណុលពុំចាំបាច់ធ្វើការរឹបអូសចលនវត្ថុដែលជាធម្មជាតិនេះជាថ្មីទេ។ មូលហេតុ ដែលកំណត់បែបនេះដោយយថាហេតុថា គឺមិនចង់ឲ្យមាននីតិវិធីនៃការសុំរឹបអូសជាថ្មីចំពោះផលដែលកើតពីវត្ថុដើមនោះឡើយ។ នៅក្នុងករណីដែលមានម្ចាស់បំណុលថ្មីសុំអនុវត្តចំពោះចលនវត្ថុរបស់កូនបំណុលដែលបានរឹបអូសរួចហើយ បើមានចលនវត្ថុដែលមិនទាន់រឹបអូសនៅឡើយ អាជ្ញាសាលាត្រូវបានរឹបអូសចលនវត្ថុនោះ។ ប្រសិនបើ គ្មានចលនវត្ថុដែលរឹបអូសបានទេ អាជ្ញាសាលាត្រូវបញ្ជាក់ច្បាស់លាស់អំពីហេតុការណ៍នេះហើយ ត្រូវបញ្ចូលរឿងក្តីអនុវត្តថ្មីនេះ ទៅក្នុងរឿងក្តីមុនជាមួយគ្នា។[133] ការរួមបញ្ចូលរឿង នាំឲ្យមានអានុភាពជាការទាមទារឲ្យចែកចំណែក។[134]

## ២.១.១០. ការលក់ចលនវត្ថុដែលត្រូវបានរឹបអូស

អាជ្ញាសាលាអាចលក់អចលនវត្ថុដែលត្រូវបានរឹបអូសនោះ តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់។ អាជ្ញាសាលា ត្រូវជំណឹងជាសាធារណៈអំពីចលនវត្ថុដែលត្រូវបានដាក់លក់ និងវិធីលក់ចលនវត្ថុនោះ។ អ្នកដែលបានទិញចលនវត្ថុនោះក្នុងតម្លៃខ្ពស់ជាងគេ ត្រូវបង់ប្រាក់ភ្លាម បន្ទាប់ពីការអនុញ្ញាតឲ្យទិញពីអាជ្ញាសាលា។ ការលក់ចលនវត្ថុដែលត្រូវបានរឹបអូស ត្រូវធ្វើការបែងចែកជា ២ប្រភេទគឺៈ

- ការលក់ចលនវត្ថុតាមលំហូរនីតិវិធី
- ការលក់ចលនវត្ថុដែលត្រូវបានរឹបអូសក្នុងពេលដែលការអនុវត្តត្រូវបានផ្អាក។

### ក. វិធីលក់

ជាទូទៅ ការលក់ចលនវត្ថុដែលត្រូវបានរឹបអូសគឺត្រូវធ្វើតាមវិធីលក់ឡាយឡុងដោយផ្ទាល់មាត់ ឬដោយដាក់ស្រោមសំបុត្រដែលក្នុងករណីនេះ អ្នកដឹកនាំនីតិវិធីលក់នោះ គឺជាអាជ្ញាសាលា។[135]

### ក.១.ការលក់ឡាយឡុងដោយផ្ទាល់មាត់

ការលក់ឡាយឡុងដោយផ្ទាល់មាត់ ធ្វើឡើងដោយការស្នើចំនួនទឹកប្រាក់ថ្លៃទិញ ហើយអាជ្ញាសាលានឹងប្រកាសអំពីអនុវត្តឲ្យទិញ ចំពោះអ្នកស្នើទិញដែលហ៊ានថ្លៃខ្ពស់ជាងគេ។ក្នុងចំណោមវិធីលក់ចលនវត្ថុ ការលក់ឡាយឡុងដោយផ្ទាល់មាត់ គឺជាវិធីដែលសមរម្យ និងងាយស្រួលក្នុងការអនុវត្ត។

[132] មាត្រា៣៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[133] មាត្រា៣៨៨ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[134] មាត្រា៣៨៨ កថាខណ្ឌទី២ ចំណុច១ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[135] មាត្រា៣៩៥ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

### ក.២. ការឡាយឡុងដោយស្រោមសំបុត្រ

ការឡាយឡុងដោយស្រោមសំបុត្រ គឺធ្វើឡើងតាមវិធីដែលអ្នកស្នើសុំទិញដាក់ពាក្យសុំទិញ ជាលាយលក្ខណ៍អក្សរ ហើយអាជ្ញាសាលានឹងធ្វើការបើកស្រោមសំបុត្រភ្លាមបន្ទាប់ពីដេញថ្លៃ រួចប្រកាសឈ្មោះ និងដេញថ្លៃរបស់បុគ្គលដែលហ៊ានថ្លៃជាងគេ ព្រមទាំងអនុញ្ញាតឲ្យបុគ្គលនោះទិញ។ វិធីលក់ឡាយដោយស្រោមសំបុត្រនេះ គេច្រើនយកមកអនុវត្តនៅក្នុងការលក់ចលនវត្ថុដែមានតម្លៃខ្ពស់ ហើយដែលអាចកំណត់តម្លៃអប្បបរមា តាមរយៈការវាយតម្លៃរបស់អ្នកវាយតម្លៃរបស់អ្នកវាយតម្លៃ។

### ក.៣. វិធីលក់ផ្សេងៗទៀត

ប្រសិនបើអាជ្ញាសាលាយល់ថាសមរម្យ ដោយគិតពិចារណាអំពីប្រភេទ និងចំនួនចលនវត្ថុជាអាទិ៍ អាជ្ញាសាលាអាចអនុវត្តការលក់ចលនវត្ថុដែលត្រូវបានរឹបអូសតាមវិធីផ្សេងពីវិធីលក់ខាងលើ ឬឲ្យបុគ្គលផ្សេងពីអាជ្ញាសាលាអនុវត្តការលក់អចលវត្ថុដែលត្រូវបានរឹបអូស ដោយទទួលការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថិតនៅបាន។[136] វិធីផ្សេងនោះមានដូចជា ការលក់ចលនវត្ថុនៅក្នុងពិធីតាំងពិពណ៌ ឬការយកចលនវត្ថុដែលត្រូវបានរឹបអូសទៅលក់នៅទីកន្លែងដែលងាយ ឬការអនុញ្ញាតឲ្យបុគ្គលដែលមានបទពិសោធន៍ខ្លាំងក្នុងការលក់ចលនវត្ថុ ដែលមានប្រភេទដូចគ្នាទៅនឹងចលនវត្ថុដែលត្រូវបានរឹបអូស....។ល។

### ខ. បុគ្គលដែលមិនអនុញ្ញាតិឲ្យដាក់សំណើទិញ

នៅក្នុងដំណើរការនៃការដាក់សំណើទិញចលនវត្ថុដែលបានរឹបអូស មិនមែនបុគ្គលគ្រប់រូបសុទ្ធតែមានសមត្ថភាពក្នុងការដាក់សំណើទិញទាំងអស់នោះទេ ពីព្រោះច្បាប់នៃព្រះរាជាណាចក្រកម្ពុជាក៏បានកំណត់យ៉ាងច្បាស់លាស់ពីបុគ្គលមួយចំនួន ដែលអសមត្ថភាពក្នុងដំណើរការលក់-ទិញ។ ខាងក្រោមនេះ ជាបុគ្គលដែលពុំអាចមានសមត្ថភាពក្នុងការដាក់សំណើទិញចលនវត្ថុ៖

- បុគ្គលដែលអសមត្ថភាព ក្នុងការធ្វើសកម្មភាពដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី ដូចជា ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភកៈ[137] និងបុគ្គលដែលខ្វះសមត្ថភាពក្នុងកាបង្ហាញឆន្ទៈ[138]
- បុគ្គលដែលមិនអាចក្លាយជាអ្នកទិញបាន[139]
- កូនបំណុលនៃការអនុវត្ត[140]

---

[136] មាត្រា៣៩៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[137] មាត្រា១៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[138] មាត្រា១៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[139] មាត្រា៥២៥ និងមាត្រា៥២៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[140] មាត្រា៣៩៥ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

- អ្នកទិញដែលមិនបានបង់ថ្លៃទិញចលនវត្ថុក្នុងពេលលក់លើកមុន មិនអាចដាក់សំណើទិញជាថ្មី នៅក្នុងការលក់ចលនវត្ថុដោយបង្ខំម្តងទៀតបានទេ[141]
- បុគ្គលដែលអាជ្ញាសាលាមិនអនុញ្ញាតឲ្យដាក់សំណើទិញ ដោយសារធ្វើសកម្មភាពរំខានកុំឲ្យការអនុវត្តលក់ធ្វើឡើងដោយត្រឹមត្រូវ។[142]

**គ. ការលក់**

ការលក់ចលនវត្ថុដែលត្រូវបានរឹបអូស អាចមានលក្ខណៈប្រែប្រួលអាស្រ័យទៅតាមវិធីលក់ និងប្រភេទវត្ថុដែលនឹងត្រូវលក់។ ចំពោះចលនវត្ថុ ដែលត្រូវលក់អាចកំណត់តម្លៃដោយអាជ្ញាសាលាបាន និងចលនវត្ថុដែលនឹងត្រូវលក់ទាមទារឲ្យមានការវាយតម្លៃពីអ្នកវាយតម្លៃ។ ប្រសិនបើ ការអនុវត្តដោយបង្ខំចលនវត្ថុ ត្រូវបានផ្អាកដោយសារការដាក់ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេច ដែលកំណត់ការបង្គាប់ឲ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ ឬឯកសារដែលសរសេរថាម្ចាស់បំណុលទទួលចលនវត្ថុដែលត្រូវបានរឹបអូស ប្រសិនបើមានការបារម្ភថា តម្លៃចលនវត្ថុដែលត្រូវបានរឹបអូសនឹងចុះថោកខ្លាំង និងសោហ៊ុយចំណាយ សម្រាប់រក្សាទុកចលនវត្ថុដែលត្រូវរឹបអូសនឹងមានចំនួនច្រើនមិនសមរម្យ។ នៅពេលអាជ្ញាសាលា លក់បានប្រាក់ហើយនោះ អាជ្ញាសាលាត្រូវផ្ញើរប្រាក់នោះទុកនៅសាលាដំបូងដែលខ្លួនស្ថិតនៅ។[143] ប្រសិនបើ ល័ក្ខខ័ណ្ឌនៃការលក់ចលនវត្ថុក្នុងពេលផ្អាកការអនុវត្តត្រូវបានបំពេញនោះនីតិវិធីនៃការលក់អំឡុងពេលធម្មតា ត្រូវយកមកអនុវត្តដូចគ្នា ដូចជាវិធីលក់ដោយផ្ទាល់មាត់ ឬលក់ដោយស្រោមសំបុត្រ ការជូនដំណឹងចលនវត្ថុដែលមានតម្លៃខ្ពស់ដែលទាមទារឲ្យមានអ្នកវាយតម្លៃ។ល។

### ២.១.១១. ការចែកចំណែក

វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែកៈ

- ម្ចាស់បំណុលនៃការអនុវត្ត
- ម្ចាស់បំណុលដែលមានលិខិតអនុវត្ត ឬដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ឬមានឯកសិទ្ធិ ឬសិទ្ធិលើការបញ្ចាំ
- ម្ចាស់បំណុលដែលទាមទារឲ្យចែកចំណែកបានរហូតដល់ពេលអាជ្ញាសាលាបានទទួលការប្រគល់ប្រាក់ដែលបានមកពីការលក់(រឹបអូសវត្ថុ)

---

[141] មាត្រា៣៩៥ កថាខណ្ឌទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[142] មាត្រា៣៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[143] មាត្រា៣៩៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

- ម្ចាស់បំណុលដែលបានទាមទារឲ្យចែកចំណែករហូតដល់ពេលដែលបានរឹបអូសប្រាក់ចំពោះប្រាក់ដែលត្រូវបានរឹបអូស[144]

ការចែកចំណែកត្រូវធ្វើឡើងដោយអាជ្ញាសាលា ឬដោយសាលាដំបូងដែលអាជ្ញាសាលានោះបានស្ថិតនៅ។

### ក. ការបែងចែកដោយអាជ្ញាសាលា

បើមានម្ចាស់បំណុលម្នាក់ ឬច្រើននាក់ ហើយប្រាក់ដែលបានមកពីការលក់ឬរឹបអូសអាចសងបំណុល និងសោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន អាជ្ញាសាលា ត្រូវចែកចំណែកហើយប្រគល់ប្រាក់ដែលនៅសល់ទៅឲ្យកូនបំណុលនៃការអនុវត្តវិញ មានន័យថាអាជ្ញាសាលាធ្វើការចែកចំណែកបើប្រាក់មានចំនួនគ្រប់សម្រាប់សងសិទ្ធិលើបំណុលទាំងអស់ និងសោហ៊ុយសម្រាប់ការអនុវត្ត ហើយបើប្រាក់នៅសល់ត្រូវប្រគល់ឲ្យកូនបំណុល។[145] នៅក្នុងករណីផ្សេងពីនេះ អាជ្ញាសាលាត្រូវកំណត់ថ្ងៃក្នុងអំឡុងពេល ២សប្តាហ៍ ដែលជាថ្ងៃដែលត្រូវពិភាក្សាគ្នាអំពីការបែងចែកចំណែក។ បើម្ចាស់បំណុលទាំងអស់ បានព្រមព្រៀងគ្នាលើការចែកចំណែកនោះ អាជ្ញាសាលា ត្រូវធ្វើការបែងចែកទ្រព្យ ទៅតាមការព្រមព្រៀង។[146] បើគ្មានការព្រមព្រៀងទេ អាជ្ញាសាលាត្រូវរាយការណ៍ជូនតុលាការ។

### ខ. ការបែងចែកចំណែកដោយសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ

ប្រសិនបើ ម្ចាស់បំណុលមិនអាចព្រមព្រៀងគ្នាលើការចែកចំណែកនូវប្រាក់ដែលបានមកពីការលក់ ឬការរឹបអូសទេនោះ អាជ្ញាសាលាត្រូវរាយការណ៍អំពីហេតុការណ៍នោះទៅសាលាដំបូងដែលខ្លួនស្ថិតនៅ។[147] នៅពេលទទួលការរាយការណ៍អំពីហេតុការណ៍នោះ ពីអាជ្ញាសាលាហើយ សាលាដំបូង ត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការបែងចែកចំណែក រួចធ្វើការចែកចំណែក។

## ២.២. លំហូរនៃការអនុវត្តបង្ខំចំពោះអចលនវត្ថុ

ចំពោះការអនុវត្តបង្ខំចំពោះអចលនវត្ថុវិញ ក៏មិនមានភាពខុសគ្នាពីការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដែរ គឺក្រោយពីចរចាអស់លទ្ធភាពពុំទទួលបានជោគជ័យ ម្ចាស់បំណុលនៃការអនុវត្តអាចដាក់ពាក្យសុំទៅតុលាការដើម្បីធ្វើការអនុវត្តដោយបង្ខំបានដូចមានចែងនៅមាត្រា៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

---

[144] មាត្រា៣៩៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[145] មាត្រា៣៩៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[146] មាត្រា៣៩៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[147] មាត្រា៤០១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

អចលនវត្ថុមួយអាចធ្វើការអនុវត្តដោយបង្ខំបាន លុះត្រាតែមានការគោរពនូវល័ក្ខខ័ណ្ឌចាំបាច់បំផុត គឺការចុះបញ្ជីផ្ទុកផ្ដាក់មួយជាក់លាក់ និងមានការចូលរួមពីអ្នកពាក់ពន្ធ័ក៏ដូចជាស្ថាប័នរដ្ឋបាលដទៃទៀតនៃក្រសួង ឬមន្ទីររៀបចំដែនដីនិងនគររូបនីយកម្មជាដើម។

តួនាទីរបស់ស្ថាប័នមានសមត្ថកិច្ចអនុវត្តរួមមានដូចខាងក្រោមនេះ៖

តួនាទីរបស់ តុលាការអនុវត្ត ក្នុងការអនុវត្តដោយបង្ខំ៖ គឺការរឹបអូសអចលនវត្ថុ ការរឹបអូសនាវា ការរឹបអូសសិទ្ធិលើបំណុល និងរឿងដែលពាក់ព័ន្ធនឹងការចេញដីកា សម្រេចរក្សាការពារ។ តួនាទី និងភារកិច្ចរបស់អាជ្ញាសាលា ក្នុងការអនុវត្តដោយបង្ខំដែលច្បាប់បានផ្ដល់សិទ្ធិ និងសមត្ថកិច្ចឱ្យ គឺពាក់ព័ន្ធនីតិវិធីរឹបអូសចលនវត្ថុ ប្រគល់ចលនវត្ថុ ប្រគល់អចលនវត្ថុ និងការអនុវត្តរក្សាការពារមានដូចជា៖ ការរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ ចំពោះអចលនវត្ថុ និងការអនុវត្តដីការក្សាការពារនៅក្នុងប្រភេទ នៃការឱ្យធ្វើសកម្មភាពណាមួយ។

### ២.២.១. ល័ក្ខខ័ណ្ឌនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

- ពាក្យសុំអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ[148]
- លិខិតអនុវត្ត[149]
- រូបមន្តអនុវត្ត[150]
- ការបង់សាហ៊ុយសម្រាប់ការអនុវត្ត (មាត្រា៣៧២, មាត្រា៣៧១ មាត្រា៣៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ និងប្រការ១៥ នៃប្រកាសលេខ៣០ កយប្រក ០៧ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងយុត្តិធម៌ស្ដីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា។
- អំឡុងពេលនៃការអនុវត្តមានរយៈពេល ០៥ឆ្នាំ។[151]

#### ក. វិធីអនុវត្ត

ករណីកូនបំណុលនៃការអនុវត្តកាន់កាប់អចលនវត្ថុ អាជ្ញាសាលាត្រូវធ្វើការរំលាយការកាន់កាប់ដោយកូនបំណុលនៃការអនុវត្តរួចប្រគល់ការកាន់កាប់ឲ្យទៅម្ចាស់បំណុលនៃការអនុវត្ត (អ្នកទិញដែលបានបង់ថ្លៃរួច)។ នៅក្នុងករណីដែលអចលនវត្ថុត្រូវបានកាន់កាប់ដោយតតិយជន តតិយជននោះមិនអាចតតាំងជាមួយនឹងម្ចាស់

[148] មាត្រា៣៨៤ កថាខណ្ឌទី១,២ និងមាត្រា៣៤៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
[149] មាត្រា៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
[150] មាត្រា៣៥៤ និងមាត្រា៣៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
[151] មាត្រា៤៨៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

បំណុលនៃការអនុវត្តបានទេ។[152] តតិយជនទាំងនោះរួមមាន តតិយជនដែលកាន់កាប់សម្រាប់កូនបំណុលនៃការអនុវត្តដូចជាអ្នកបម្រើ សាច់ញាតិ។ តតិយជនក្រៅពីភាគីដែលត្រូវបានសរសេរក្នុងលិខិតអនុវត្ត ត្រូវបានយកធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុវត្ត។ តតិយជនដែលអាចតតាំងជាមួយ នឹងម្ចាស់បំណុលនៃការអនុវត្ត ត្រូវមានលិខិតអនុវត្តដែលអាចអនុវត្តចំពោះតតិយជនបាន។

### ខ. យន្តការនៃការចុះបញ្ជីរឹបអូសអចលនវត្ថុ

ដើម្បីអាចចុះបញ្ជីរឹបអូសអចលនវត្ថុតាមច្បាប់ តម្រូវឲ្យគោរពលក្ខខ័ណ្ឌជាច្រើនដើម្បីឲ្យមានភាពច្បាស់លាស់ និងចៀសវាងហានិភ័យនានា មុនឈានដល់ការចាប់ផ្តើមបន្តនីតិវិធី បន្តបន្ទាប់នៃការអនុវត្តដោយបង្ខំ។ ការចុះបញ្ជីរឹបអូសអចលនវត្ថុសំដៅទៅលើអចលនវត្ថុដែលចុះបញ្ជី និងអចលនវត្ថុមិនទាន់បានចុះបញ្ជីនៅរដ្ឋបាលសុរិយោដី។ ដើម្បីអាចចុះបញ្ជីបានត្រឹមត្រូវទាមទារឲ្យបំពេញនូវល័ក្ខខ័ណ្ឌខ្លះៗដូចខាងក្រោមនេះ៖

### គ. ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ

ដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ គឺជាដីកាសម្រេចដំបូងដែលតុលាការក្នុងការអនុវត្តចេញក្នុងការចាប់ផ្តើមនីតិវិធីលក់ដោយបង្ខំនិងឈានទៅរកការចុះបញ្ជីរឹបអូសអចលនវត្ថុបាន។ យ៉ាងណាក៏ដោយតុលាការអនុវត្តមិនអាចចាប់ផ្តើមការលក់ដោយបង្ខំបាននោះទេ ប្រសិនបើមិនមានពាក្យសុំឲ្យលក់ដោយបង្ខំរបស់ម្ចាស់បំណុលនៃការអនុវត្តជាមុនសិន។

### ឃ. ការដាក់ពាក្យសុំឲ្យលក់ដោយបង្ខំ

ការកំណត់ពីចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ ពិតជាមានសារៈសំខាន់ណាស់ ពីព្រោះថាវាផ្តល់ប្រយោជន៍សម្រាប់តុលាការក្នុងការយល់ដឹងច្បាស់ពីកម្មវត្ថុ និងខ្លឹមសារនៃពាក្យសុំក៏ដូចជាចំណុចពាក់ពន្ធ័ដែលបានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។ ជាពិសេសទៅទៀតនោះ ម្ចាស់បំណុលនៃការអនុវត្តមិនចាំបាច់ត្រូវការកែតម្រូវឡើងវិញដែលនាំឲ្យខាតពេលវេលានោះទេ។ តុលាការដែលមានសមត្ថកិច្ចគឺ សាលាដំបូងមានសមត្ថកិច្ចលើទីកន្លែងដែលអចលនវត្ថុតាំងនៅ។[153]

### ង. ការបញ្ជូនពាក្យសុំទៅក្រឡាបញ្ជី

ម្ចាស់បំណុលត្រូវយកពាក្យសុំលក់ដោយបង្ខំ ទៅដាក់នៅការិយាល័យរដ្ឋបាលតុលាការ ដែលទទួលបន្ទុកទទួលពាក្យសុំអនុវត្តដោយបង្ខំដែលអចលនវត្ថុតាំងនៅ។

[152] មាត្រា៥២៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[153] មាត្រា៤១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

### ២.២.២. ករណីអចលនវត្ថុចុះបញ្ជី

អចលនវត្ថុសំដៅទៅលើដី អាគារដែលត្រូវបានចុះបញ្ជី ចំណែកកម្មសិទ្ធិអវិភាគលើដី ឬអាគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍និងផលុបភោគដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួម។ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវធ្វើតាមនីតិវិធីលក់ដោយបង្ខំ។ ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ត្រូវភ្ជាប់ជាមួយឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត និងឯកសារខាងក្រោមនេះ៖

- ចំពោះអចលនវត្ថុដែលត្រូវបានចុះបញ្ជី ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជី និងក្នុងករណីដែលជនដទៃក្រៅពីកូនបំណុលនៃការអនុវត្ត ត្រូវបានចុះនៅក្នុងសៀវភៅចុះបញ្ជី ថាជាកម្មសិទ្ធិករ ឯកសារដែលបញ្ជាក់ថា អចលនវត្ថុនោះជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត។
- ចំពោះដី ដែលមិនបានចុះបញ្ជីឯកសារដែលបញ្ជាក់ថាដីនោះជាកម្មសិទ្ធិ របស់កូនបំណុលនៃការអនុវត្ត។

### ២.២.៣. ការរឹបអូសអចលនវត្ថុ

នៅពេលដែលមានពាក្យសុំអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុរបស់ម្ចាស់បំណុលនៃការអនុវត្តមកកាន់អាជ្ញាសាលា។ អាជ្ញាសាលា ត្រូវអនុវត្តនីតិវិធីដោយរំលាយការកាន់កាប់អចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត រួចប្រគល់ការកាន់កាប់ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ។ ហេតុដូច្នេះហើយ បានជានីតិវិធីនៃការអនុវត្តប្រភេទនេះ តម្រូវឱ្យមានវត្តមានរបស់ម្ចាស់បំណុលនៃការអនុវត្ត ឬ អ្នកតំណាង។ ការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ ឬនាវាផ្ទុក ឬវត្ថុផ្សេងទៀត ដែលមនុស្សរស់នៅក្នុងនោះ ត្រូវធ្វើតាមនីតិវិធីដែលអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅ រំលាយការកាន់កាប់វត្ថុ ដែលជាវត្ថុរបស់កូនបំណុលនៃការអនុវត្ត ហើយធ្វើឲ្យម្ចាស់បំណុលនៃការអនុវត្តទទួលបាន នៅការកាន់កាប់នោះ។ ការអនុវត្តដោយបង្ខំនេះ អាចធ្វើទៅបានលុះត្រាតែម្ចាស់បំណុលនៃការអនុវត្ត ឬអ្នកតំណាង របស់ម្ចាស់បំណុលនៃការអនុវត្តនោះ បានបង្ហាញខ្លួននៅកន្លែងអនុវត្ត។ ហើយអាជ្ញាសាលាអាចចូលទៅក្នុងអចលនវត្ថុ នាវា ឬវត្ថុផ្សេងទៀតដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត ហើយចាំបាច់សម្រាប់ធ្វើការចាត់ចែងដើម្បីបើកទ្វារ ដែលបិទនោះបាន។[154]

ក្នុងការអនុវត្តខាងលើនេះ អាជ្ញាសាលាត្រូវដកចេញនូវវត្ថុដែលមិនមែនជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ហើយត្រូវប្រគល់វត្ថុនោះទៅឲ្យកូនបំណុលនៃការអនុវត្ត ឬអ្នកតំណាងរបស់កូនបំណុលនោះ ឬញាតិនៅជាមួយ ឬអ្នកបំរើឬអ្នកផ្សេងទៀត ដែលធ្វើការនៅទីនោះដែលមានការយល់ដឹងសមរម្យ។ ក្នុងករណីនេះ ប្រសិនបើពុំអាចប្រគល់ចលនវត្ថុនោះទៅឲ្យជនទាំងឡាយដែលរៀបរាប់ខាងលើទេ អាជ្ញាសាលាត្រូវថែរក្សាគ្រប់គ្រងវត្ថុនោះ ចំណែកឯការថែរក្សានេះ ត្រូវចាត់ជាសោហ៊ុយសម្រាប់ការអនុវត្ត។ ផ្ទុយមកវិញបើនៅតែមិនអាចប្រគល់

[154] មាត្រា៥២៤ កថាខណ្ឌទី១-៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ចលនវត្ថុនេះទៅឲ្យជនទាំងអស់ខាងលើនេះទេ អាជ្ញាសាលាអាចលក់វត្ថុនោះ តាមនីតិវិធីលក់នៃការអនុវត្ត ចំពោះចលនវត្ថុបាន ហើយប្រាក់ដែលបានពីការលក់នេះ អាជ្ញាសាលាត្រូវដកចេញនូវ ចំនួនទឹកប្រាក់ដែលមកពីការលក់នេះ សម្រាប់សោហ៊ុយនៃការថែរក្សា ហើយប្រាក់ដែលសេសសល់ត្រូវផ្ញើទៅសាលា ដំបូងដែលខ្លួនស្ថិតនៅ។[155] បើបានបញ្ចប់ការអនុវត្តដោយបង្ខំដូចខាងលើហើយ អាជ្ញាសាលាត្រូវជូនដំណឹងទាំងនោះ ទៅកូនបំណុលនៃការអនុវត្ត។[156]

លិខិតអនុវត្ត គឺជាដីការសម្រេចបង្គាប់ឲ្យប្រគល់អចលនវត្ថុ។ លិខិតអនុវត្ត គឺជា ឯកសារដែលបញ្ជាក់អំពីអត្ថិភាព និងទំហំនៃសិទ្ធិទាមទារ ដែលត្រូវអនុវត្តដោយបង្ខំ។ ម្ចាស់បំណុលនៃការអនុវត្តត្រូវដាក់នូវឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត រួមជាមួយនឹងពាក្យសុំឲ្យផ្តល់រូបមន្តអនុវត្តទៅឲ្យតុលាការដែលមានសំណុំរឿង ឬសារការីដែលជាអ្នករក្សាទុកនូវច្បាប់ដើមនៃលិខិតយថាភូត។[157] ក្រឡាបញ្ជី ឬសារការីធ្វើការផ្ទៀងផ្ទាត់លើច្បាប់ដើមនៃលិខិតអនុវត្ត និងសំណុំរឿងជាអាទិ៍ ហើយធ្វើការត្រួតពិនិត្យថាតើបានសរសេរអំពីអត្ថិភាពនៃប្រាតិភោគ ឬអត់ និងធ្វើការពិនិត្យសាលក្រមថាបានចូលជាស្ថាពរហើយឬនៅ។ ប្រសិនបើ យល់ឃើញថាត្រឹមត្រូវ ក្រឡាបញ្ជី ឬសារការី នឹងផ្តល់រូបមន្តអនុវត្តលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត។ ផ្អែកតាមបញ្ញត្តិដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណីមាត្រា៣៥៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ រូបមន្តអនុវត្តត្រូវសរសេរភ្ជាប់ បន្ថែមនៅផ្នែកខាងក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ហើយក្រឡាបញ្ជី ឬសារការីត្រូវចុះហត្ថលេខាលើរូបមន្តអនុវត្តដោយសរសេរ ថ្ងៃ ខែ ឆ្នាំ នៃការផ្តល់រូបមន្តអនុវត្ត ។ ជាធម្មតាប្រសិនបើខ្លឹមសារនៃរូបមន្តអនុវត្តសរសេរថា «ម្ចាស់បំណុលនៃការអនុវត្ត X អាចអនុវត្តហ៊ីប៉ុន្តែក ចំពោះកូនបំណុលនៃការអនុវត្ត Y បានដោយផ្អែកតាមលិខិត អនុវត្តនេះ។ ហត្ថលេខារបស់ក្រឡាបញ្ជី ឬសារការី ថ្ងៃទី ខែ ឆ្នាំ» នោះវាមានលក្ខណៈគ្រប់គ្រាន់ហើយ។ ប៉ុន្តែ វាមានភាពចាំបាច់ក្នុងការសរសេរបន្ថែមនូវចំណុចមួយចំនួនថែមទៀត ប្រសិនបើមានស្ថានភាពបែបនោះ។[158]

នៅពេលផ្តល់រូបមន្តអនុវត្ត ក្រឡាបញ្ជី ឬ សារការី ត្រូវសរសេរនូវចំណុចដែលបានកំណត់នៅក្នុងមាត្រា ៣៥៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ នៅលើច្បាប់ដើមនៃលិខិតអនុវត្តដែលមានចែងនៅក្នុងមាត្រា៣៥៩ កថាខណ្ឌ័ទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។ ម្យ៉ាងទៀត ក្នុងករណីដែលបានផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ និង ច្រើនដង ក្រឡាបញ្ជី ឬ សារការី ត្រូវជូនដំណឹងទៅកូនបំណុលនៃការអនុវត្តអំពីហេតុការណ៍ និងមូលហេតុនោះ និងចំនួននៃឯកសារចម្លងយថាភូតដែលត្រូវបានផ្តល់រូបមន្តអនុវត្ត។[159]

---

155 មាត្រា៥២៤ កថាខណ្ឌទី៤-៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

156 មាត្រា៥២៤ កថាខណ្ឌទី៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

157 មាត្រា៣៥៤ កថាខណ្ឌទី២ និងមាត្រា៣៥៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

158 មាត្រា ៣៥៧ កថាខណ្ឌទី១. ចំណុច (ខ, គ, ឃ) នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

159 មាត្រា៣៥៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

### ២.២.៤. ការលក់ដោយបង្ខំនូវអចលនវត្ថុ

#### ក. សមត្ថកិច្ចអនុវត្តការលក់

យោងតាមមាត្រា៤៣៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី សមត្ថកិច្ចក្នុងការលក់អចលនវត្ថុត្រូវធ្វើឡើងដោយ អាជ្ញាសាលា។

#### ខ. វិធីលក់

ការលក់អចលនវត្ថុ ត្រូវអនុវត្តតាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់។[160] តុលាការអនុវត្តអាចកំណត់វិធីលក់ ផ្សេងពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ រឺដោយផ្ទាល់មាត់ តែក្នុងករណីដែលពុំអាចលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់។[161] ការលក់ដោយឡាយឡុងដោយស្រោមសំបុត្រ រឺដោយផ្ទាល់មាត់ តុលាការអនុវត្តត្រូវកំណត់កាលបរិច្ឆេទ និង ទីកន្លែងលក់ឱ្យបានច្បាស់លាស់ហើយត្រូវអោយអាជ្ញាសាលាអនុវត្តការលក់នោះ។ ហើយម្យ៉ាងវិញទៀត ក្រឡាបញ្ជីត្រូវផ្សាយជាសាធារណៈនូវសញ្ញាណអចលនវត្ថុ ដែលត្រូវលក់តម្លៃលក់អប្បបរមា ព្រមទាំងកាល បរិច្ឆេទ និងទីកន្លែងលក់អោយបានច្បាស់លាស់ ។

ការលក់តាមពីររបៀបនេះអាជ្ញាសាលាអនុវត្តត្រូវរក្សាសណ្តាប់ធ្នាប់ នៅកន្លែងលក់ឱ្យមានរបៀបរៀបរយដែលមានចែងនៅក្នុងមាត្រា៣៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ថា " *ចំពោះជនណាដែលធ្វើសកម្មភាពរំខានកុំអោយការ អនុវត្តការលក់ធ្វើឡើងដោយត្រឹមត្រូវដូចជាបានធ្វើអោយរំខានដល់ជនដទៃទៀតក្នុងការធ្វើសំណើរទិញ ឬចំពោះជនដែលបានប្រើអោយធ្វើសកម្មភាពនោះអាជ្ញាសាលាអាចកម្រិតមិនអោយជននោះចូលកន្លែងលក់ រឺ អាចដេញជននោះចេញពីកន្លែងលក់ ឬអាចមិនអោយស្នើសុំទិញបាន* " ។

#### គ. ការកំណត់អ្នកស្នើរទិញក្នុងតម្លៃអតិបរមា

បើការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់បានបញ្ចប់អាជ្ញាសាលាត្រូវប្រកាសការបញ្ចប់ កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្រោយពេលបានកំណត់អ្នកស្នើ សុំទិញក្នុងតម្លៃអតិបរមា និងបានប្រកាសនូវនាម ឬ នាមករណ៏របស់អ្នកទិញ និងថ្លៃលក់ឡាយឡុងនោះ។ បើអ្នកដេញថ្លៃដោយស្រោមសំបុត្រ ដែលបានធ្វើសំណើទិញក្នុងតម្លៃអតិបរមាមានច្រើននាក់ អាជ្ញាសាលា ត្រូវកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមាដោយឱ្យអ្នកទាំងនោះដេញថ្លៃដោយស្រោមសំបុត្រម្តងទៀត។ នៅក្នុងករណីអ្នកដេញថ្លៃមិនអាចដេញថ្លៃដោយតម្លៃតិចជាងតម្លៃដែលខ្លួនដេញមុនបានឡើយ ។

---

[160] មាត្រា៣៩៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[161] មាត្រា៤៣៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

បើសិនអ្នកដេញថ្លៃមិនបានធ្វើការធ្វើការដេញថ្លៃម្តងទៀតទេនោះ អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ត្រូវបានកំណត់ដោយការចាប់ឆ្នោត។ នៅពេលការលក់ឡាយឡុងធ្វើតាមពីររបៀបនោះរួចរាល់ហើយ អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុដែលបាន សរសេរដូចខាងក្រោមដាក់ជូនទៅតុលាការអនុវត្តភ្លាមៈ

- សញ្ញាណនៃអចលនវត្ថុ
- កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ផ្ទាល់មាត់
- សញ្ញាណរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា
- ហេតុការណ៍នោះ និងស្ថានភាពបើមិនអាចកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា
- មូលហេតុ និងវិធានការដែលបានចាត់ធ្វើដែលបានចាត់វិធានការដែលបានកំណត់ក្នុងមាត្រា៣៩៦ ស្តីពីការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
- អាជ្ញាសាលា ត្រូវអោយអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬអ្នកតំណាងចុះហត្ថលេខាលើកំណត់ហេតុនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ ។
- អាជ្ញាសាលាត្រូវអោយអ្នកស្នើទិញធ្វើការធានាលើសំណើរទិញ ដោយអោយជនដែលបម្រុងនឹងធ្វើសំណើ ទិញអចលនវត្ថុត្រូវដាក់ប្រាក់ធានាដែលមានចំនួនស្មើនឹងចំនួន ១ ភាគ ១០ ( មួយភាគដប់) នៃតម្លៃលក់អប្បបរមា។ ប៉ុន្តែ បើយល់ឃើញថាសមរម្យ តុលាកាអនុវត្តអាចកំណត់ចំនួននៃប្រាក់ធានាលើសពីចំនួននេះបាន។ ប្រសិនបើ មានសំណើទិញពីបុគ្គលក្រៅពីអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា តុលាកាអនុវត្តត្រូវសងភ្លាមនូវ ប្រាក់ធានាដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៤៣៦នៃក្រមនីតិវិធីរដ្ឋប្បវេណីចែងពី វិធីលក់ជាអាទិ៍។

### ឃ. អានុភាពនៃការលក់

បើដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរ អ្នកទិញត្រូវបង់ថ្លៃលក់ទៅតុលាការអនុវត្ត នៅមុនពេលដែលតុលាការអនុវត្តបានកំណត់។ ពេលកំណត់នេះ ត្រូវស្ថិតនៅក្នុងអំឡុងពេល ១ (មួយ) ខែចាប់ពីថ្ងៃដែលដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរ។[162] ចំពោះដីកាសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឱ្យលក់ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍អាចប្តឹងជំទាស់បាន ក្នុងករណីដែលដីកាសម្រេចនោះបណ្តាលឱ្យមានការខូចខាតដល់សិទ្ធិរបស់ខ្លួន។[163] ចំនួនទឹកប្រាក់ដែលអ្នកទិញបានដាក់ដើម្បីធានាលើសំណើទិញ ត្រូវគិតបញ្ចូលក្នុងថ្លៃលក់។ ប្រសិនបើអ្នកទិញ គឺជាម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែកពីប្រាក់លក់ អ្នកទិញនោះអាចបង់ថ្លៃលក់ដោយដកនូវចំនួនទឹកប្រាក់ដែលខ្លួនត្រូវទទួលពីការបែងចែកចំណែកនៅកាលបរិច្ឆេទនៃការចែកចំណែកបានដោយស្នើសុំទៅតុលាការអនុវត្តនៅមុនពេលបញ្ចប់កាលបរិច្ឆេទដើម្បីដីកាសម្រេចការលក់។[164] នៅ

[162] មាត្រា៤៤៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[163] មាត្រា៤៤៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[164] មាត្រា៤៤៧ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ក្នុងករណីនេះ បើមានសេចក្តីថ្លែងតវ៉ាអំពីចំនួនទឹកប្រាក់នៃការចែកចំណែកដែលអ្នកទិញត្រូវទទួល អ្នកទិញត្រូវបង់ចំនួនទឹកប្រាក់ដែលស្មើនឹងភាគដែលមានការតវ៉ានោះជាបន្ទាន់។ អ្នកទិញធ្វើលទ្ធកម្មនូវអចលនវត្ថុ នៅពេលដែលខ្លួនបានបង់ថ្លៃលក់ហើយ។[165] ប្រសិនបើអ្នកទិញបានបង់ថ្លៃលក់ហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី និងលុបការចុះបញ្ជីនូវចំណុចមួយចំនួនដូចបានកំណត់ខាងក្រោមនេះ[166]៖

- ការចុះបញ្ជីអំពីការផ្ទេរសិទ្ធិដែលអ្នកទិញបានធ្វើលទ្ធកម្ម
- ការលុបការចុះបញ្ជី អំពីលទ្ធកម្មនូវសិទ្ធិដែលបានរលត់ដោយការលក់ ឬសិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់
- ការលុបការចុះបញ្ជី អំពីការចាត់ចែងជាបណ្តោះអាសន្នដែលបានបាត់បង់អានុភាពដោយការលក់
- ការលុបការចុះបញ្ជី អំពីការរឹបអូស ឬរឹបអូសជាបណ្តោះអាសន្ន។

### ២.២.៥. នីតិវិធីចែកចំណែក

នៅក្នុងករណីដែលអានុភាពនៃការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ បានកើតឡើង តុលាការអនុវត្តត្រូវកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ដោយគិតពិចារណានូវអំឡុងពេលចាំបាច់ដើម្បីផ្ញើឯកសារលំអិតអំពីវត្ថុលើកលែងករណីដែលបានចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំត្រួតគ្នា ដោយយោងតាមមាត្រា៤២៤ កថាខណ្ឌទី១ ស្តីពីដីកាសម្រេចចាប់ផ្តើមត្រួតគ្នា នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

នៅពេលដែលពេលចុងក្រោយសម្រាប់ការទាមទារ ឱ្យចែកចំណែកត្រូវបានកំណត់តុលាការអនុវត្ត ត្រូវប្រកាសជាសាធារណៈអំពីការណ៍ដែលដីកាសម្រេចចាប់ផ្តើមត្រូវបានចេញ និងអំពីពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ហើយត្រូវដាស់តឿនឱ្យជនដែលបានកំណត់ខាងក្រោមនេះ រាយការណ៍ទៅតុលាការអនុវត្ត អំពីអត្ថិភាព ឬនត្ថិភាព នៃសិទ្ធិលើបំណុល និងមូលហេតុនិងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនោះ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក៖

- ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន នៅមុនការចុះបញ្ជីអំពីការរឹបអូសដោយផ្អែកលើដីការសម្រេចចាប់ផ្តើមការលក់ដោយបង្ខំដំបូងចំពោះអចលនវត្ថុនោះ។
- ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគដែលត្រូវបានចុះបញ្ជី នៅមុនការចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំដំបូង ចំពោះអចលនវត្ថុនោះ។
- ស្ថាប័នដែលមានសមត្ថកិច្ចលើពន្ធដារ ឬអាករសាធារណៈផ្សេងទៀត។

165 មាត្រា៤៤៧ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

166 មាត្រា៤៤៨ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

តុលាការអនុវត្តត្រូវដាស់តឿនចំពោះជនដែលបានកំណត់ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ចំណុចខ នៃកថាខណ្ឌទី២ មាត្រា៤២២ ស្តីពីការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និងការផ្លាស់ប្តូររបស់ពេលកំណត់នោះ អំពីចំណុចដែលបានកំណត់នៅក្នុងចំណុចនីមួយៗដូចខាងក្រោមនេះ៖

- ការរាយការណ៍អំពីអត្ថិភាព ឬនត្ថិភាពនៃឆន្ទៈអនុវត្តសិទ្ធិប្រាតិភោគ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក
- កិច្ចដែលត្រូវដាក់ពាក្យសុំឱ្យ អនុវត្តសិទ្ធិប្រាតិភោគ នៅមុនពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ក្នុងករណីដែលមានឆន្ទៈអនុវត្តសិទ្ធិប្រាតិភោគ។

ប្រសិនបើមិនបានចេញដីកាសម្រេចអនុវត្តឱ្យលក់ នៅក្នុងអំឡុងពេល ៣ខែ គិតចាប់ពីពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកទេ តុលាការអនុវត្តអាចផ្លាស់ប្តូរពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកបាន។ ប្រសិនបើ បានផ្លាស់ប្តូរពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក តុលាការអនុវត្តត្រូវប្រកាសជាសាធារណៈ អំពីការផ្លាស់ប្តូរនេះ។[167]

## សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវលើប្រធានបទ «**ការអនុវត្តដោយបង្ខំ**» រួចមក យើងឃើញថាការអនុវត្តដោយបង្ខំ គឺជាប្រព័ន្ធមួយដែលមានលក្ខណៈបង្ខំពីសំណាក់រដ្ឋ ដើម្បីជួយសម្រេចសិទ្ធិរបស់បុគ្គលណាដែលមានសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគ ដែលមានកំណត់ក្នុងលិខិតអនុវត្ត។ ការអនុវត្តដោយបង្ខំនេះ គឺមានចែងក្នុងគន្ថីទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ចាប់ពីមាត្រា៣៣៤ ដល់មាត្រា៥២៩ ដែលស្មើនឹង១៩៥មាត្រា។ តាមការសិក្សាឈ្វេងយល់កន្លងមក យើងយល់ថាប្រធានបទខាងលើនេះមានការអនុវត្តច្រើនដំណាក់កាល មុនឈានដល់ការទាមទារផលប្រយោជន៍ជូនម្ចាស់បំណុលនៃការអនុវត្ត។ ការអនុវត្តដោយបង្ខំ មានទាំងគោលបំណងឱ្យសងជាប្រាក់ និងមិនសងជាប្រាក់ផងដែរ។ មួយទៀត ក្នុងសារណានេះយើងក៏បានលើកឡើងពីការអនុវត្តដោយបង្ខំលើចលនវត្ថុ និងការអនុវត្តដោយបង្ខំលើអចលនវត្ថុ ដែលការបង្ខំទាំងពីរនេះ មានលក្ខណៈដូចគ្នាមួយចំនួនទាក់ទងនឹងនីតិវិធីនៃការដាក់ពាក្យសុំទៅស្ថាប័នអនុវត្ត។

មុននឹងឈានដល់ម្ចាស់បំណុលដាក់ពាក្យស្នើសុំ ឱ្យធ្វើការអនុវត្តដោយបង្ខំទៅលើកូនបំណុលនៃការអនុវត្ត គឺមានត្រូវឆ្លងកាត់ការចរចាដោយសន្តិវិធីជាមុនសិន។ ប៉ុន្តែប្រសិនបើការចរចានោះ មិនអាចធ្វើឱ្យកូនបំណុលនៃការអនុវត្ត យល់ព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនទេ នោះម្ចាស់បំណុលនសការអនុវត្ត អាចស្នើសុំឱ្យស្ថាប័នអនុវត្ត ធ្វើការអនុវត្តដោយបង្ខំលើកូនបំណុលនៃការអនុវត្តបាន តាមពាក្យសុំឱ្យអនុវត្តដោយបង្ខំ។ ស្ថាប័ន

[167] មាត្រា៤៣៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

អនុវត្តរួមមាន តុលាការអនុវត្ត និងអាជ្ញាសាលា។ អាជ្ញាសាលា ជាស្ថាប័នអនុវត្តដែលមានសមត្ថកិច្ច ស្ថាប័នអនុវត្តរួមមានតុលាការអនុវត្ត និងអាជ្ញាសាលា។ ដោយឡែកការអនុវត្តដោយបង្ខំចំពោះចលនវត្ថុគឺស្ថិតក្រោមសមត្ថកិច្ចរបស់អាជ្ញាសាលានៃសាលាដំបូង ដែលចលនវត្ថុនៃការអនុវត្តដោយបង្ខំនោះស្ថិតនៅ។ សិទ្ធិអំណាច របស់អាជ្ញាសាលានៅក្នុងការអនុវត្តដោយបង្ខំមានដូចជា សិទ្ធិប្រើប្រាស់កម្លាំងឬនគរបាល សិទ្ធិឆែកឆេរ សិទ្ធិអ្នកសង្កេតការណ៍ សិទ្ធិរកអ្នកវាយតម្លៃ និងសិទ្ធិជ្រើសរើសវត្ថុដែលត្រូវរឹបអូសជាដើម។ នៅពេលអាជ្ញាសាលាធ្វើការរឹបអូសវត្ថុ អាជ្ញាសារត្រូវតែមើលថែរក្សាវត្ថុដែលបានរឹបអូសជាបណ្តោះអាសន្ននោះ តាមដីការសម្រេចរក្សាការពារ ដែលមានចែងនៅក្នុងគន្លទី៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

ដើម្បីឱ្យការអនុវត្តដោយបង្ខំមានប្រសិទ្ធភាពខ្ពស់ និងមានដំណើរការប្រកបដោយភាពយុត្តធម៌ គឺត្រូវតែផ្តល់សិទ្ធិ និងអំណាចឱ្យអាជ្ញាសាលា ក្នុងការមានសិទ្ធិប្រើប្រាស់កម្លាំងសាធារណៈ ដូចជាកម្លាំងនគរបាល កងរាជអាវុធហត្ថ និងកម្លាំងផ្សេងៗទៀត ដើម្បីលុបបំបាត់ការរារាំង ឬការប្រឆាំង នឹងការអនុវត្ត។ ម្យ៉ាងវិញទៀត អាជ្ញាធរមានសមត្ថកិច្ច មានដូចជាមេឃុំ ចៅសង្កាត់ មេភូមិ អភិបាលស្រុក/ក្រុង ក្រសួង ស្ថាប័ន និងមន្ទីរពាក់ព័ន្ធទាំងអស់ ត្រូវចូលរួមក្នុងការអនុវត្តដោយបង្ខំនេះ គឺជាកាតព្វកិច្ចដែលកំណត់នៅក្នុងច្បាប់។ ចំពោះការមិនចូលរួមពីសំណាក់កងកម្លាំងសាធារណៈ និងអាជ្ញាធរមានសមត្ថកិច្ច ក្នុងនីតិវិធីការអនុវត្តដោយបង្ខំដែលដឹកនាំដោយអាជ្ញាសាលា គឺជាបទល្មើសព្រហ្មទណ្ឌ។

ការចូលរួមរបស់កងកម្លាំងសាធារណៈ និងអាជ្ញាធរមានសមត្ថកិច្ច ក្រោមការដឹកនាំរបស់អាជ្ញាសាលា គឺជាការទទួលខុសត្រូវរបស់អាជ្ញាសាលា ដូចនេះពួកគាត់ត្រូវតែគោរពទៅតាមបទបញ្ជា ឬការណែនាំរបស់អាជ្ញាសាលា ហើយត្រូវសហការជាមួយ អាជ្ញាសាលា ដើម្បីធ្វើការអនុវត្តដោយបង្ខំ ឱ្យបានត្រឹមត្រូវ និងពេញលេញទៅតាមខ្លឹមសារ នៃសេចក្តីសម្រេចផ្សេងៗរបស់តុលាការ ដូចជា សាលក្រម សាលដីកា ដីកាសម្រេចកំណត់ហេតុស្តីពីការសះជាជាដើម និងលិខិតយថាភូតដែលធ្វើដោយសាការី។ ការអនុវត្តដោយបង្ខំ គឺជានីតិវិធីតាមផ្លូវតុលាការ ក្នុងការសម្រេចនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគ ដែលបានកំណត់ នៅក្នុងនីតិឯកជន ដោយប្រើអំណាចរបស់រដ្ឋ។ ប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីមានគោលបំណងផ្តល់ ទៅឱ្យភាគីឯកជនដែលមានសិទ្ធិ ហើយដែលបានកំណត់ដោយច្បាប់នូវការការពារសិទ្ធិទាំងនោះ ឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណី ដោយផ្អែកទៅលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន ដើម្បីការពារដល់សិទ្ធិទាមទារ និងសិទ្ធិប្រាតិភោគដែលបានកំណត់ នៅក្នុងនីតិឯកជននោះ ត្រឹមតែការកំណត់ដោយតុលាការ អំពីអត្ថិភាពនៃសិទ្ធិទាំងនោះ ទៅក្នុងសាលក្រម ឬសាលដីកានៅមិនទាន់គ្រប់គ្រាន់ទេ។

បន្ថែមពីលើនេះ ត្រូវមានការផ្តល់តាវកាលិកជាអាទិ៍ ដែលជាកម្មវត្ថុនៃសិទ្ធិទាមទារ តាមរយៈការអនុវត្តដោយបង្ខំ។ ហេតុនេះហើយ ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់សិទ្ធិទៅក្នុងប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី ដែលមានគោលបំណងការពារសិទ្ធិរបស់បុគ្គលឯកជន ចាំបាច់ត្រូវមានការរៀបចំនូវនីតិវិធីសម្រាប់ការអនុវត្តដោយបង្ខំ ក្នុងករណីដែលបុគ្គលជាប់កាតព្វកិច្ចផ្តល់តាវកាលិក ឬកូនបំណុលមិនព្រមអនុវត្តកាតព្វកិច្ច របស់ខ្លួន

ដោយស្ម័គ្រចិត្ត ក្នុងគោលដៅសម្រេចឲ្យបាននូវការអនុវត្តកាតព្វកិច្ចដែលជាកម្មវត្ថុនៃសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគ តាមរយៈការប្រើប្រាស់អំណាច អាជ្ញាបញ្ញារបស់រដ្ឋ អ្វីដែលត្រូវបានរៀបចំឡើង ដើម្បីបំពេញភាពចាំបាច់នេះ។

ជាចុងក្រោយ យើងយល់ឃើញថា ការអនុវត្តដោយបង្ខំពិតជាមានសារសំខាន់ណាស់ ក្នុងការស្វែងរកយុត្តិធម៌ជូនដល់ម្ចាស់បមណុលនៃការអនុវត្ត និងធ្វើឱ្យមានសណ្តាប់ធ្នាប់សាធារណៈតាមរយៈការអនុវត្តច្បាប់។ ជាក់ស្តែងយើងឃើញថា ស្ថាប័នអនុវត្តដែលមានតុលាការអនុវត្ត និងអាជ្ញាសាលា បានដើរតួនាទីសំខាន់មែនទែន ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ក្នុងនាមជាអ្នកអនុវត្តច្បាប់ ដើម្បីដោះស្រាយបញ្ហាដែលកើតមានឡើងនៅក្នុងសង្គម។ ការគោរពច្បាប់ គឺជារឿងមួយដែលប្រជាពលរដ្ឋគ្រប់គ្នា ត្រូវតែអនុវត្តតាម។ ប្រសិនបើពួកគេមិនគោរពច្បាប់ នោះច្បាប់ក៏នឹងដាក់ទោសពួកគេវិញដែរ។ ប៉ុន្តែរាល់ការដាក់ទោសទៅលើជនណាម្នាក់ ស្ថាប័នអនុវត្តច្បាប់ត្រូវប្រាកដចិត្តថា ការដាក់ទោសមានភាពត្រឹមត្រូវ មិនលំអៀងទៅខាងណាមួយឡើយ។

## អនុសាសន៍

១. សូមសំណូមពរដល់តុលាការត្រូវតែធ្វើការស្រាវជ្រាវ រួមទាំងពិនិត្យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃនៃសាលក្រម ឬសាលដីការបស់តុលាការឱ្យបានច្បាស់លាស់ ព្រោះដើម្បីឱ្យប្រាកដថា ការអនុវត្តដោយបង្ខំនីមួយៗមានលក្ខណៈត្រឹមត្រូវ យុត្តិធម៌ និងស្មើភាព។

២. សូមសំណូមពរដល់តុលាការត្រូវតែត្រួតពិនិត្យ និងសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅស្តីអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសេចក្តីសម្រេចមជ្ឈត្តករ គឺក្នុងន័យធ្វើឱ្យការអនុវត្តដោយបង្ខំ មិនបង្កឱ្យបាត់បង់ផលប្រយោជន៍របស់ភាគីណាម្ខាង។

៣. សូមសំណូមពរដល់អាជ្ញាសាលានៃសាលាដំបូង ក៏ត្រូវធ្វើការពិនិត្យឲ្យបានច្បាស់នូវពាក្យសុំឱ្យអនុវត្តចំពោះចលនវត្ថុដោយបង្ខំ មុននឹងចាប់ផ្តើមរឹបអូសចលនវត្ថុដែលជាកម្មវត្ថុនោះ ដើម្បីឲ្យការអនុវត្តដោយបង្ខំនោះមានភាពត្រឹមត្រូវ យុត្តិធម៌ និង មិនបំពានទៅលើភាគីដែលជាកូនបំណុល។

៤. សូមសំណូមពរ ចំពោះការសុំឲ្យផ្តល់រូបមន្តអនុវត្ត ក្រឡាបញ្ជី ឬសារការីធ្វើការផ្ទៀងផ្ទាត់លើច្បាប់ដើមនៃលិខិតអនុវត្ត និងសំណុំរឿងជាអាទិ៍ ហើយធ្វើការត្រួតពិនិត្យថាតើបានសរសេរអំពីអត្ថិភាពនៃប្រាតិភោគ ឬអត់ និងធ្វើការពិនិត្យសាលក្រមថាបានចូលជាស្ថាពរហើយឬនៅ ប្រសិនបើឃើញថាត្រឹមត្រូវហើយ ក្រឡាបញ្ជី ឬសារការី នឹងផ្តល់រូបមន្តអនុវត្តលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត។

៥. សូមសំណូមពរដល់សាស្ត្រាចារ្យដែលបានបង្រៀននិស្សិតតាមអនឡាញ ចូល និងពិនិត្យមើលនូវចម្លើយ (កិច្ចការប្រលង)ដែលនិស្សិតបានដាក់បញ្ជូនទៅឱ្យផង មុននឹងធ្វើការដាក់ពិន្ទុឱ្យនិស្សិត។ ចំពោះនិស្សិតវិញ ត្រូវតែយកចិត្តទុកដាក់រៀនសូត្រឱ្យបានច្រើន និងក្រេបយកចំណេះដឹងពីសាស្ត្រាចារ្យ ដើម្បីអាចក្លាយជាបុគ្គលម្នាក់ដែលប្រកបដោយចំណេះដឹង និងជាធនធានល្អសម្រាប់សង្គមជាតិ។

៦. សូមសំណូមពរដល់ថ្នាក់ដឹកនាំសាលា មេត្តាពិនិត្យមើលទៅលើនិស្សិតមួយចំនួនតូចដែលគាត់ពុំមានលទ្ធភាពក្នុងការបង់ថ្លៃសាលាពិតប្រាកដ ដោយផ្តល់ជាឱកាស ឬជាការបន្ធូរបន្ថយឱ្យពួកគាត់បានខ្លះ ក្នុងការបន្តការសិក្សា និងបញ្ចប់ការសិក្សានៅថ្នាក់ឧត្តមផង ព្រោះថាក្នុងបរិបទកូវីដ-១៩ នេះមាននិស្សិតមួយចំនួនដែលគាត់ពិតជាពុំមានលទ្ធភាពក្នុងការបង់ថ្លៃសាលាទេ ដែលជាហេតុធ្វើឱ្យផ្អាក នឹងអាចឈានដល់គាត់បោះបង់ការសិក្សាចោលក៏មាន។

៧. ជាចុងក្រោយ សូមសំណូមពរដល់ មិនថាស្ថាប័នអ្នកបង្កើតច្បាប់ ប្រជាពលរដ្ឋទាំងអស់ទេ ត្រូវតែនាំគ្នាគោរពច្បាប់ ឱ្យបានខ្ជាប់ខ្ជួន ដើម្បីធ្វើឱ្យប្រទេសកម្ពុជាយើងក្លាយជាប្រទេសនីតិរដ្ឋក្នុងពេលបច្ចុប្បន្ន និងជាប្រទេសនីតិរដ្ឋពេញលេញនាពេលអនាគត។

# ឯកសារយោង

## ១. បទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
- ក្រមរដ្ឋប្បវេណី២០០៧
- ប្រកាសអន្តរក្រសួងស្តីពី ការចុះបញ្ជីអចលនវត្ថុទាក់ទង់នឹងក្រមនីតិវិធីរដ្ឋប្បវេណី.រាជធានីភ្នំពេញ.ថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០១១

## ២. សេចក្តីពន្យល់ក្រមនីតិវិធី

- សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី.ភាគ២: ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ. រៀបរៀងដោយ ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

## ៣. ឯកសារផ្សេងទៀត

- សៀវភៅស្តីពី នីតិវិធីនៃការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ (បោះពុម្ពលើកទី១).នៅខែមីនា ឆ្នាំ២០០៩
- សៀវភៅ ស្តីពី ការពន្យល់អំពីនីតិវិធីលក់ ដោយបង្ខំចំពោះអចលនវត្ថុ.បោះពុម្ពលើកទី១.មករា ២០១២
- ការរឹបអូសជាបណ្តោះអាសន្ននូវចលនវត្ថុ.ក្រសួងយុត្តិធម៌ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិវិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់ សាស្ត្រាចារ្យ Yukawa Ryo (Slide)
- ព្រឹត្តិបត្រមេធាវី.លេខ១៩. ខែតុលា-ធ្នូ ឆ្នាំ២០១៨
- សេចក្តីព្រាងស្តីពីអាជ្ញាសាលា

# ឧបសម្ព័ន្ធ

១. គន្ថីទី៦ ការអនុវត្តដោយបង្ខំ.នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦.ទំព័រ១៣១ ដល់ ២៣៧

២. សៀវភៅ ស្តីពី ការពន្យល់អំពីនីតិវិធីលក់ ដោយបង្ខំចំពោះអចលនវត្ថុ.បោះពុម្ពលើកទី១.មករា ២០១២. ទំព័រទី១ ដល់ទំព័រទី៦៨ (រក្សាសិទ្ធិគ្រប់បែបយ៉ាងដោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ)

# ឧបសម្ព័ន្ធ១

## គន្លឹះទី៦ ការអនុវត្តដោយបង្ខំនៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ ទំព័រ១៣១ ដល់ ២៣៧

# ឧបសម្ព័ន្ធ២

**សៀវភៅ ស្តីពី ការពន្យល់អំពីនីតិវិធីលក់ ដោយបង្ខំចំពោះអចលនវត្ថុ.បោះពុម្ពលើកទី១.មករា ២០១២. ទំព័រទី១ ដល់ទំព័រទី៦៨ (រក្សាសិទ្ធិគ្រប់បែបយ៉ាងដោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ)**